ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

MINISTRY OF WOMEN'S AFFAIRS

# យុទ្ធសាស្ត្រ

# ស្តីពី

# ការចិញ្ចឹមកូនបែបវិជ្ជមាន

២០១៧-២០២១

រចនាទំព័រដោយ៖ © UNICEF Cambodia/2017/Youra Soeum and Graphic Roots

**ស្នាដៃថតរូប៖**

| | |
|---|---|
| ទំព័រទី១ | © UNICEF Cambodia/ 2016/Antoine Raab/ UNICEF Canada |
| ទំព័រទី៣ | © UNICEF Cambodia/ 2015/Giacomo Pirozzi |
| ទំព័រទី៥ | © UNICEF Cambodia/ 2015/ Giacomo Pirozzi |
| ទំព័រទី២០ | © UNICEF Cambodia/ 2015/ Giacomo Pirozzi |

រាល់ការផលិតឡើងវិញនូវផ្នែកណាមួយនៃយុទ្ធសាស្រ្តស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាននេះចាំបាច់ត្រូវមានការអនុញ្ញាត។

**សូមទំនាក់ទំនង៖**
ក្រុមការងារបច្ចេកទេសស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាននៃក្រសួងកិច្ចការនារី

**អាសយដ្ឋាន៖**
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥) ២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨

រាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០១៧

# អារម្ភកថា

យុទ្ធសាស្ត្រស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ជាសមិទ្ធផលថ្មីមួយទៀតរបស់ក្រសួងកិច្ចការនារីក្នុងការអប់រំកុមារប្រកបដោយសមធម៌យេនឌ័រ ដើម្បីរួមចំណែកផ្ដល់ការយល់ដឹងបន្ថែមដល់ លោកជំទាវ ឯកឧត្តម លោកស្រី លោក បាន និងកំពុងអនុវត្តការងារទំនាក់ទំនងផ្នែកអភិវឌ្ឍន៍សង្គម ក្នុងនោះក៏មានការវិនិយោគទៅលើកុមារផងដែរ ។ ឯកសារនេះមានឈ្មោះថា យុទ្ធសាស្ត្រស្ដីពី***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។ នៅប្រទេសកម្ពុជាកន្លងមក កុមារដែលមានអាយុចាប់ពី 0 ទៅអាយុក្រោម ១៨ឆ្នាំ ត្រូវបានទទួលរងផលអវិជ្ជមានជាច្រើនពីសំណាក់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងពីអ្នកដែលរស់នៅជុំវិញខ្លួន ដូចជា ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើ ឬការមិនយកចិត្តទុកដាក់។ ទង្វើទាំងអស់នេះអាចបណ្ដាលមកពីមូលហេតុជាច្រើនជាអាទិ៍ ទម្លាប់ ឥរិយាបថ និងការប្រព្រឹត្តិ ដែលត្រូវបានអនុវត្តតៗគ្នាជាយូរយារាស់មកហើយ ដោយសារកង្វះខាតការយល់ដឹងអំពីសិទ្ធិកុមារ និងភាពក្រីក្រ។ កត្តាទាំងនេះ អាចញ៉ាំងឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួនធំដែលធ្លាប់សម្ដែងឡើងនូវសកម្មភាពមិនសមរម្យទៅលើកុមារដូចជា ការគំរាមកំហែង ការមិនអើពើ ឬមិនយកចិត្តទុកដាក់ ការមិនឱ្យតម្លៃ និងការមិនផ្ដល់ភាពកក់ក្ដៅលើកុមារ។

យុទ្ធសាស្ត្រនេះ មានគោលបំណងបង្កើនចំណេះដឹង ការយល់ដឹង និងជំនាញទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមាន នៅក្នុងចំណោមឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ ដើម្បីកសាងគ្រួសារ បរិយាកាស ប្រកបដោយសុវត្ថិភាព សមធម៌យេនឌ័រ និងអហិង្សា ។

ជាមួយគ្នានេះដែរ ក៏នៅមានមន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្ត គ្រប់លំដាប់ថ្នាក់ ដែលធ្វើការងារពាក់ព័ន្ធនឹងកុមារ ដើម្បីចូលរួមបង្កើនចំណេះដឹងមូលដ្ឋានលើគុណតម្លៃនៃ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ក្នុងនោះនៅមានក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដែលត្រូវអនុវត្តប្រកបដោយសមភាពសម្រាប់ទំនាក់ទំនង ដើម្បីលើកកម្ពស់កម្មវិធី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ឱ្យមាននិរន្តរភាព និងជោគជ័យ ។

ទន្ទឹមនេះ ការសិក្សាស្រាវជ្រាវក៏បានបង្ហាញពីផលប៉ះពាល់ចំពោះកុមារ និងការរកឃើញនូវអនុសាសន៍សំខាន់ៗមួយចំនួនសម្រាប់គាំទ្រ ដើម្បីជំរុញ និងលើកកម្ពស់កម្មវិធី ដែលមានការលើកកម្ពស់ការប្រាស្រ័យទាក់ទងឱ្យមានកាយវិការជិតស្និទ្ធរវាងកុមារ និងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ការកែលម្អនូវទម្លាប់មិនសមរម្យ ដែលអាចបង្កឱ្យមានអំពើហិង្សាលើកុមារ រួមទាំងការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ និងការបង្កើនការយល់ដឹងអំពីសិទ្ធិ និងការអភិវឌ្ឍរបស់កុមារ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ហ៊ូ សាមិត្ត**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មូលនិធិសហប្រជាជាតិដើម្បីកុមារ ( UNICEF ) និងអង្គការសង្គ្រោះកុមារ (Save the Children) ចំពោះកិច្ចគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដ៏ថ្លៃថ្លា តាមរយៈដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នេះ។ សូមថ្លែងអំណរគុណចំពោះជំនួយហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកាណាដា តាមរយៈ Global Affairs Canada និង Together for Girls និងជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នវេស្ស៍ តាមរយៈអង្គការ Save the Children Norway ដែលបានគាំទ្រកម្មវិធីនេះ។

ក្រសួងកិច្ចការនារី ក៏សូមថ្លែងអំណរគុណផងដែរ ចំពោះកិច្ចគាំទ្របច្ចេកទេសរបស់អង្គការបុគ្គាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា (ICS-SP) អង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) និងការសិក្សាដែលធ្វើឡើងដោយដេប៉ាតឺម៉ង់ចិត្តវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ស្តីពី កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនក្នុងប្រទេសកម្ពុជា ដែលបានផ្តល់ព័ត៌មានសម្រាប់ការរៀបចំយុទ្ធសាស្ត្រស្តីពី***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

សូមថ្លែងអំណរគុណជាពិសេសចំពោះនាយកដ្ឋានស្ត្រី និងការអប់រំ នៃក្រសួងកិច្ចការនារី ដែលបានខិតខំក្នុងការសម្របសម្រួលដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រនេះ ហើយក៏សូមថ្លែងអំណរគុណផងដែរចំពោះក្រុមការងារបច្ចេកទេសថ្នាក់ជាតិស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដែលបានចូលរួមផ្តល់ព័ត៌មានដ៏មានតម្លៃចំពោះសេចក្តីព្រាងកន្លងមក។

ជាចុងក្រោយ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំដ៏ធំធេងរបស់លោកស្រី Pia van den Boom ដែលជាទីប្រឹក្សាមកពីអង្គការ ICS-SP ដែលបានអភិវឌ្ឍយុទ្ធសាស្ត្រនេះឡើង ផ្អែកលើមតិយោបល់ត្រឡប់ពីអ្នកពាក់ព័ន្ធទាំងអស់ដែលបានផ្តល់កិច្ចគាំទ្រ។

# មាតិកា

**អារម្ភកថា** ........................................................................................................................

**សេចក្តីថ្លែងអំណរគុណ** ........................................................................................................

**សេចក្តីផ្តើម** ...................................................................................................................... ១

**ផ្នែកទី១ ៖ គោលបំណងនៃយុទ្ធសាស្ត្រ** ........................................................................................ ៣

១.១. ទស្សនវិស័យ ........................................................................................................ ៣

១.២. គោលដៅ ................................................................................................................. ៣

១.៣. គោលបំណង ............................................................................................................ ៤

គោលការណ៍ណែនាំ ........................................................................................................ ៤

**ផ្នែកទី២ ៖ សាវតា និងបរិបទ** ................................................................................................... ៥

២.១. និយមន័យ និងពាក្យបច្ចេកទេស .................................................................................. ៥

២.២. ការវិភាគស្ថានភាព .................................................................................................. ៧

២.៣. បរិបទច្បាប់ និងគោលនយោបាយ ................................................................................. ១២

២.៤. ភស្តុតាង៖ តើយើងដឹងអ្វីខ្លះពីកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូន? ......................................... ១៦

**ផ្នែកទី៣ ៖ យុទ្ធសាស្ត្រ** .......................................................................................................... ២០

៣.១. កម្រិតទី១៖ កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនជាសកល "កម្រិតស្រាល" សម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមាន ..................................................................................... ២២

៣.២. កម្រិតទី២៖ កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនតាមក្រុមដោយមានកំណត់គោលដៅ .................... ២៥

៣.៣. កម្រិតទី៣៖ កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន .......................................................... ២៨

៣.៤. ការធានាគុណភាពក្នុងកិច្ចគាំទ្រចំពោះការចិញ្ចឹមកូនបែបវិជ្ជមាន ........................................ ២៩

**ផ្នែកទី៤ ៖ ផែនការសកម្មភាព** ................................................................................................ ៣៥

៤.១. ពេលវេលា ............................................................................................................. ៣៥

៤.២. ការពិចារណាចុងក្រោយក្នុងការបោះជំហានទៅមុខ .............................................................. ៣៦

**ឧបសម្ព័ន្ធ១ ៖ អក្សរកាត់** ........................................................................................................ ៣៧

**ឧបសម្ព័ន្ធ២ ៖ សន្ទានុក្រម** ....................................................................................................... ៣៨

**ឯកសារយោង** ........................................................................................................................ ៤១



# សេចក្តីផ្តើម

មូលហេតុចម្បងមួយនៃវិសមភាពយេនឌ័រនៅក្នុងសង្គមបច្ចុប្បន្ន បានកើតឡើងពីផ្នត់គំនិតជាអវិជ្ជមាននៅក្នុងគ្រួសារ សហគមន៍ និងសង្គមដែលបានអប់រំ ផ្តល់ឱកាស និងក្តីស្រឡាញ់ដល់កូនប្រុស កូនស្រីខុសៗគ្នា។

អំពើហិង្សាលើកុមារគឺជាការរំលោភសិទ្ធិមនុស្សមួយដ៏ធ្ងន់ធ្ងរ និងជាកង្វល់ផ្នែកសង្គម និងសុខភាពសាធារណៈ។ នៅក្នុងប្រទេសកម្ពុជា មានកុមារចំនួនមួយនាក់ក្នុងចំណោមកុមារពីរនាក់បានទទួលរងអំពើហិង្សាផ្លូវកាយខណៈពេលដែលពួកគេកំពុងចម្រើនវ័យ[១]។ បទពិសោធន៍នេះមានផលប៉ះពាល់យ៉ាងខ្លាំង និងជ្រាលជ្រៅទៅលើជីវិតរស់នៅ និងក្តីសង្ឃឹមរបស់ពួកគេសម្រាប់អនាគត ព្រមទាំងប៉ះពាល់ទៅលើគ្រួសារ សហគមន៍ និងសង្គមរបស់ពួកគេទាំងមូល។ ពុំមានហេតុផលណាមួយដែលអាចដោះសារបានចំពោះអំពើហិង្សាលើកុមារបានឡើយ ហើយវាក៏មិនមែនជារឿងដែលមិនអាចជៀសវាងបាននោះដែរ។ ប្រសិនបើ មូលហេតុឫសគល់របស់វាត្រូវបានកំណត់រកឃើញ និងដោះស្រាយ គេអាចទប់ស្កាត់បានទាំងស្រុងចំពោះអំពើហិង្សាលើកុមារ។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ មានសក្តានុពលធំធេងបំផុតក្នុងការការពារកុមារ និងផ្តល់ឱ្យពួកគេនូវសុវត្ថិភាព ទាំងផ្លូវកាយ និងផ្លូវចិត្ត។ ជាអកុសល ដូចគ្នាទៅនឹងប្រទេសដទៃទៀតផងដែរ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាច្រើននៅក្នុងប្រទេសកម្ពុជា មានការលំបាកក្នុងការផ្តល់ឱ្យកូននូវបរិយាកាសរស់នៅមួយដែលមានសុវត្ថិភាព និងសុខុមាលភាព ហេតុនេះហើយ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួននៅតែបន្តការប្រព្រឹត្តអំពើហិង្សាដោយអចេតនា។ ជាទូទៅគឺជាបុគ្គលដែលបានប្រព្រឹត្តអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងការមិនអើពើ ហើយខ្វះសមត្ថភាព និងធនធានក្នុងការការពារ កូនពីអំពើហិង្សាដែលប្រព្រឹត្តដោយអ្នកដទៃក្នុងនោះរួមមានអំពើហិង្សាផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ បើទោះបីជាគ្រួសារជាកន្លែងសុវត្ថិភាពចម្បងក៏នៅតែមាន ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមួយចំនួនយល់ថា កូនរស់នៅក្នុងមណ្ឌលប្រសើរជាង។

---

១. របកគំហើញនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣

ក្រសួងកិច្ចការនារី (MoWA) ក៏ដូចជាស្ថាប័នអនុវត្ត និងក្រសួងពាក់ព័ន្ធ ទទួលស្គាល់អំពីសារៈសំខាន់នៃការគាំទ្រដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ក្នុងការទប់ស្កាត់ និងកាត់បន្ថយអំពើហិង្សា ព្រមទាំងរក្សាគ្រួសារឱ្យនៅជួបជុំគ្នា។ ដូច្នេះ ក្រសួងប្តេជ្ញាលើកកម្ពស់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដែលផ្តល់នូវទំនាក់ទំនង និងបរិយាកាសប្រកបដោយសុវត្ថិភាព ស្នេហភាព និងបង្កលក្ខណៈអំណោយផលដល់ការលូតលាស់ និងអភិវឌ្ឍរបស់កូន ដើម្បីឱ្យពួកគេក្លាយទៅជាមនុស្សពេញវ័យដែលមានសុខភាពល្អ មានការគោរព និងមានផលិតភាពខ្ពស់។

យុទ្ធសាស្ត្រនេះមានគោលបំណងលើកកម្ពស់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** តាមរយៈការបង្កើនលទ្ធភាពទទួលបានកិច្ចគាំទ្រសមស្រប និងឆ្លើយតបទាន់ពេលវេលាចំពោះការចិញ្ចឹមកូន ព្រមទាំងការលុបបំបាត់ផ្នត់គំនិតអវិជ្ជមាន ឬលំអៀងមកលើកូនដោយសារតែភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទ។ យុទ្ធសាស្ត្រនេះ គឺជាយុទ្ធសាស្ត្ររយៈពេលវែងមួយសម្រាប់ក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ និងជាមូលដ្ឋានគ្រឹះមួយនៃកម្មវិធី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ឆ្នាំ២០១៧-២០២១។ ព្រមទាំងជាសេចក្តីណែនាំសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលធ្វើការងារជាមួយកុមារ និងគ្រួសាររបស់ពួកគេ សំដៅសម្រេចឱ្យបាននូវកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនដែលមានការសម្របសម្រួល និងគុណភាពកាន់តែប្រសើរជាងមុន ប្រកបដោយសមភាព និងសមធម៌ ។

បើទោះជាយុទ្ធសាស្ត្រនេះបានបង្ហាញពីការដោះស្រាយបញ្ហា ការចិញ្ចឹមកូនបែបអវិជ្ជមាន ដែលប្រើអំពើហិង្សាធ្ងន់ធ្ងរនៃការចិញ្ចឹមកូនក៏ដោយ យុទ្ធសាស្ត្រនេះក៏ទទួលស្គាល់ផងដែរថា មានឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាច្រើនក្នុងប្រទេសកម្ពុជាបានចិញ្ចឹមកូនបែបវិជ្ជមាន ទោះបីពួកគេរស់នៅក្នុងស្ថានភាពលំបាកក៏ដោយ។

***ការចិញ្ចឹមកូនបែបវិជ្ជមាន*** គឺជាវិធីសាស្ត្រមួយដ៏សំខាន់ ដើម្បីទប់ស្កាត់ និងកាត់បន្ថយគម្លាតយេនឌ័រ និងអំពើហិង្សាលើកុមារ។ តែនៅមានកត្តាមួយចំនួនពុំអាចដោះស្រាយបានតាមរយៈវិធីសាស្ត្រនេះ ដែលទាមទារឱ្យអនុវត្តក្របខ័ណ្ឌទូលំទូលាយជាងនេះ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។

យុទ្ធសាស្ត្រនេះ រួមមាន៤ផ្នែក ៖

**ផ្នែកទី១ ៖** ពន្យល់អំពីទស្សនវិស័យ គោលដៅ គោលបំណង និងគោលការណ៍ណែនាំ។

**ផ្នែកទី២ ៖** ផ្តល់នូវសារតាមួយដែលណែនាំជូនដល់អ្នកអានអំពីគោលគំនិតសំខាន់ៗ និងពាក្យបច្ចេកទេស យោងតាមបរិបទប្រទេសកម្ពុជា និងភស្តុតាងដែលមាន ដើម្បីបង្ហាញឱ្យឃើញនូវវិចារណភាពច្បាស់លាស់មួយសម្រាប់យុទ្ធសាស្ត្រការចិញ្ចឹមកូនបែបវិជ្ជមានក្នុងប្រទេសកម្ពុជា។

**ផ្នែកទី៣ ៖** គូសបញ្ជាក់អំពីយុទ្ធសាស្ត្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

**ផ្នែកទី៤ ៖** ធ្វើការបូកសរុបជាមួយនឹងផែនការសកម្មភាពកម្រិតខ្ពស់មួយ សម្រាប់ឆ្នាំ២០១៧-២០២១ និងការពិចារណាចុងក្រោយក្នុងការបោះជំហានទៅមុខ។



# ផ្នែកទី១ ៖ គោលបំណងនៃយុទ្ធសាស្ត្រ

ដើម្បីឆ្លើយតបទៅនឹងគំហើញដែលទទួលបានពីការអង្កេត ស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា (CVACS) ក្រសួងកិច្ចការនារី ស្ថាប័នអនុវត្ត និងក្រសួងពាក់ព័ន្ធ បានប្តេជ្ញារួមចំណែកក្នុងការអនុវត្តកម្មវិធី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដើម្បីលើកកម្ពស់ទម្រង់អហិង្សាដោយអនុវត្តវិន័យបែបវិជ្ជមានទៅលើកុមារ ការការពារកុមារពីអំពើហិង្សា និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ ព្រមទាំងមធ្យោបាយនានា ដែលផ្តល់ឱកាស និងលទ្ធភាពក្នុងការអភិវឌ្ឍកុមារប្រកបដោយសមភាព និងសមធម៌។ យុទ្ធសាស្ត្រនេះផ្តល់នូវមូលដ្ឋានសម្រាប់ក្រសួងកិច្ចការនារី ស្ថាប័នអនុវត្ត និងក្រសួងពាក់ព័ន្ធដទៃទៀត ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តនេះទៅជាសកម្មភាពក្នុងអំឡុងឆ្នាំ២០១៧-២០២១ និងរយៈពេលវែងតទៅមុខទៀត។

## ១.១. ទស្សនវិស័យ

ធានាឱ្យទំនាក់ទំនងរវាងកុមារជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ព្រមទាំងបរិយាកាសក្នុងគ្រួសារប្រកបដោយសុវត្ថិភាព ស្ថេរភាព និងអំណោយផលដល់ការលូតលាស់របស់កុមារគ្រប់រូបក្នុងប្រទេសកម្ពុជា ដើម្បីលូតលាស់ និងអភិវឌ្ឍខ្លួនឱ្យក្លាយជាមនុស្សពេញវ័យ ដែលមានសុខភាពល្អ មានការគោរព និងមានផលិតភាពខ្ពស់។

## ១.២. គោលដៅ

គាំទ្រ និងពង្រឹងចំណេះដឹង ជំនាញ និងទំនុកចិត្តរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ រួមទាំងអ្នកដែលនឹងក្លាយជាឪពុកម្តាយនាអនាគតក្នុង***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ចាប់តាំងពីករកំណើតរហូតដល់អាយុក្រោម ១៨ឆ្នាំ សំដៅលើកកម្ពស់ ៖

- ទំនាក់ទំនងរវាងកុមារជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំប្រកបដោយសុវត្ថិភាព ស្ថេរភាព និងអំណោយផលដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ

- របៀបនៃការចិញ្ចឹមកូន និងវិធីសាស្ត្រអនុវត្តវិន័យបែបវិជ្ជមាន អហិង្សា និងប្រកបដោយសមធម៌
- សុវត្ថិភាព និងកិច្ចការពារកុមារនៅក្នុងផ្ទះ និងក្រៅផ្ទះ
- ទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។

## ១.៣. គោលបំណង

១. ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារទទួលបាននូវកិច្ចគាំទ្រសមស្រប និងទាន់ពេលវេលាសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

២. អ្នកជំនាញវិជ្ជាជីវៈ អ្នកពាក់កណ្ដាលជំនាញវិជ្ជាជីវៈ និងអ្នកស្ម័គ្រចិត្តសហគមន៍ដែលធ្វើការផ្ទាល់ជាមួយកុមារ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ មានចំណេះដឹងមូលដ្ឋាន យល់ដឹងអំពីគុណតម្លៃ និងវិធីគាំទ្រដល់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

៣. ស្ថាប័នអនុវត្ត ក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សហការ និងសម្របសម្រួលដើម្បីលើកកម្ពស់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

## គោលការណ៍ណែនាំ

ការរៀបចំយុទ្ធសាស្ត្រនេះ ផ្អែកលើភស្តុតាងល្អដែលមានស្រាប់ និងប្រាកដនិយម ដោយពិចារណាទៅលើរចនាសម្ព័ន្ធ សមត្ថភាព និងធនធានដែលមានស្រាប់សម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ក្នុងប្រទេសកម្ពុជា។ ជាចម្បង គោលការណ៍ណែនាំនេះផ្អែកលើរចនាសម្ព័ន្ធដែលមានស្រាប់របស់រាជរដ្ឋាភិបាលសម្រាប់គាំទ្រយុទ្ធសាស្ត្រ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងមានបំណងបញ្ចូលក្នុងថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាល។

គោលការណ៍ណែនាំសំខាន់ៗ រួមមាន៖

- **អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ** (UNCRC) កំណត់ទៅលើ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ថា សិទ្ធិមនុស្ស ជាសិទ្ធិមូលដ្ឋានរបស់កុមារគ្រប់រូប និងជាសិទ្ធិរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការទទួលបានការគាំទ្រអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។
- **វិធីសាស្ត្របែបវិជ្ជមាន** សម្រាប់គាំទ្រឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ នូវសក្ដានុពលរបស់ពួកគេ ក្នុងការការពារ ផ្ដល់នូវសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តដល់កុមារ ដោយជំនួសឱ្យវិធីសាស្ត្រដែលធ្វើការវិនិច្ឆ័យ រិះគន់ ឬបង្ក្រាបបញ្ហា។
- **វិធីសាស្ត្រពេញមួយជីវិតរបស់កុមារ** ដែលពិចារណាទៅលើគ្រប់ដំណាក់កាលនៃជីវិតរស់នៅរបស់កុមារ និងកិច្ចគាំទ្រដែលកុមារា កុមារី និងកុមារពិការត្រូវការទៅតាមដំណាក់កាលផ្សេងៗនៃការលូតលាស់ និងអភិវឌ្ឍ។
- ***សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ*** គឺផ្ដោតទៅលើការយកចិត្តទុកដាក់ជាក់លាក់ពីតម្រូវការ អារម្មណ៍ សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ ក្នុងអំឡុងពេលរៀបចំ និងផ្ដល់នូវកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន ។
- **ទស្សនវិស័យផ្អែកសង្គម និងបរិស្ថាន** សំដៅទៅលើការស្វែងយល់អំពីរបៀបនៃការចិញ្ចឹមកូនដែលទទួលរងឥទ្ធិពលពីកត្តានានានៅកម្រិតបុគ្គល ទំនាក់ទំនងដៃគូ គ្រួសារ សហគមន៍ និងសង្គម ។
- **ភាពផ្សេងៗគ្នា** ការរៀបចំ ការអន្តរាគមក្នុងការចិញ្ចឹមកូនដោយឆ្លើយតប និងគិតគូរអំពីសេចក្ដីត្រូវការរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងគ្រួសារផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា។



# ផ្នែកទី២ ៖ សាវតា និងបរិបទ

## ២.១. និយមន័យ និងពាក្យបច្ចេកទេស

និយមន័យ និងពាក្យបច្ចេកទេស មានសារៈសំខាន់ដើម្បីឱ្យមានការយល់ជារួមមួយអំពីយុទ្ធសាស្ត្រ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** រវាងគ្រប់ដៃគូទាំងអស់។ ដើម្បីបង្កលក្ខណៈឱ្យមានការយល់ដឹងច្បាស់លាស់អំពីយុទ្ធសាស្ត្រនេះ ត្រូវបានបញ្ចូលពាក្យបំព្រួញនៅក្នុងឧបសម្ព័ន្ធ១ និងសន្ទានុក្រមដែលរាយនាមអំពីពាក្យបច្ចេកទេសសំខាន់ៗមួយចំនួនដូចនៅក្នុងឧបសម្ព័ន្ធ២។

- ពាក្យថា “**ឪពុកម្តាយ**” “**អាណាព្យាបាល**” និង “**អ្នកថែទាំ**” សំដៅចំពោះអ្នកថែទាំចម្បងរបស់កុមារ (ដោយមិនកំណត់ថាជា សាច់ញាតិបង្កើត ឬបុគ្គលណាមួយឡើយ) ដូចជា ឪពុកម្តាយ ជីដូនជីតា និងអ្នកថែទាំដទៃទៀត ដោយរាប់បញ្ចូលទាំងអ្នកដែលនឹងក្លាយជាឪពុកម្តាយក្នុងពេលឆាប់ៗ (ស្ត្រីមានផ្ទៃពោះ និងដៃគូ) និងអនាគតនឹងក្លាយជាឪពុកម្តាយ (យុវវ័យ)។
- **អំពើហិង្សាលើកុមារ** រាប់បញ្ចូលគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ការមិនអើពើ ឬមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ចផ្សេងៗ។ យុទ្ធសាស្ត្រស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** មានគោលដៅចម្បងទៅលើការទប់ស្កាត់អំពើហិង្សាដែលប្រព្រឹត្តដោយ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងការមិនយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍសមត្ថភាព និងការការពារពួកគេពីអំពើហិង្សា ដែលប្រព្រឹត្តដោយអ្នកដទៃ ដោយរាប់បញ្ចូលអំពើរំលោភបំពានផ្លូវភេទ និងអំពើកេងប្រវ័ញ្ចកំលាំងពលកម្ម។
- **ការចិញ្ចឹមកូនបែបវិជ្ជមាន ៖**

១). ជាការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សារួមទាំងការមិនអើពើ ដោយផ្តោតទៅលើគោលដៅយូរអង្វែង ការផ្តល់ភាពកក់ក្តៅ និងដែនកំណត់ ការយល់អំពីការគិត និងអារម្មណ៍ និងការដោះស្រាយបញ្ហារបស់កូនៗ។

២). សង្កត់ធ្ងន់ទៅលើកិច្ចគាំទ្រ ភាពកក់ក្ដៅ និងការឆ្លើយតបដ៏ខ្លាំងក្លា ព្រមទាំងលើកកម្ពស់ឱ្យមានការយល់ដឹងស៊ីជម្រៅអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់កុមារដោយមិនមានការរើសអើងដោយសារតែភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទ។ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ជាវិធីសាស្ត្រអនុវត្តវិន័យបែបវិជ្ជមាន និងអហិង្សា ដោយរំពឹងឱ្យកុមារអនុវត្តតាមវិន័យនានា ដោយសារតែពួកគេយល់អំពីវិន័យទាំងនោះ និងពុំមែនដើម្បីគ្រប់គ្រងទៅលើការប្រព្រឹត្តរបស់កុមារឡើយ។ ការចិញ្ចឹមកូនបែបវិជ្ជមាន លើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទង និងកិច្ចសន្ទនាទ្វេវិធាន ព្រមទាំងការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។ ជាចុងក្រោយ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** មានមូលដ្ឋានផ្អែកលើការគោរព និងឱ្យតម្លៃដែលមនុស្សពេញវ័យទទួលស្គាល់ចំពោះកុមារ និងធ្វើការកែសម្រួលទៅតាមភាពជាក់ស្ដែង ព្រមទាំងទទួលយកការទទួលខុសត្រូវទាំងស្រុង សម្រាប់គុណភាពនៃទំនាក់ទំនងជាមួយកុមារ ។

យុទ្ធសាស្ត្រនេះទទួលស្គាល់ និងគោរពចំពោះភាពផ្សេងៗគ្នាក្នុងការចិញ្ចឹមកូន ក៏ដូចជារបៀបដែលមនុស្ស និងវប្បធម៌ផ្សេងៗគ្នាអនុវត្តក្នុងការចិញ្ចឹមកូនរបស់ពួកគេ។ ការចិញ្ចឹមកូនរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារនឹងរងឥទ្ធិពលយ៉ាងខ្លាំងក្លាពីវប្បធម៌ ប្រវត្តិសាស្ត្រ និងកត្តាដទៃទៀត ហើយការចិញ្ចឹមកូនរបស់ប្រជាពលរដ្ឋ ដោយផ្អែកទៅតាមសមត្ថភាព ជំនឿ និងគុណតម្លៃផ្សេងៗគ្នាផងដែរ។ ទោះបីជាមានការគោរពទៅលើភាពផ្សេងៗគ្នានៃរបៀបចិញ្ចឹមកូនក៏ដោយ ប៉ុន្តែកាតព្វកិច្ចរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំទាំងអស់គឺត្រូវការពារ និងបង្កលក្ខណៈអំណោយផលសម្រាប់ការលូតលាស់ និងអភិវឌ្ឍ ផ្ដល់ការណែនាំ និងការចង្អុលទិសដល់កុមារ។

- **កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន** គឺជាគោលគំនិតមួយដ៏ទូលំទូលាយ ដែលត្រូវបានកំណត់និយមន័យ និងបែងចែកប្រភេទផ្សេងៗគ្នាទៅតាមវិស័យ និងអ្នកពាក់ព័ន្ធនានា។ កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនត្រូវបានគេយល់ថា ជាទិដ្ឋភាពមួយនៃគោលគំនិតទូលំទូលាយសម្រាប់កិច្ចគាំទ្រគ្រួសារ (សូមមើលរូបភាពទី១)។ កិច្ចគាំទ្រគ្រួសារត្រូវបានផ្ដោតសំដៅកែលម្អដំណើរការប្រព្រឹត្តទៅរបស់គ្រួសារ។ កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនស្ថិតនៅក្នុងកម្រងសកម្មភាពមួយចំនួនដែលកើតមាននៅក្នុងសេវាសម្រាប់កុមារ និងគ្រួសារ។ ការអន្តរាគមជាក់លាក់ គឺជាផ្នែកមួយនៃកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនប្រសិនបើ៖
  - ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គឺជាគោលដៅដែលផ្ដោតទៅលើរបៀបដែលពួកគេយល់ឃើញ និងអនុវត្តកាតព្វកិច្ចរបស់ពួកគេក្នុងនាមជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ជាពិសេសទាក់ទងទៅនឹងរបៀបនៃការប្រាស្រ័យទាក់ទងជាមួយកូនៗ។
  - ផ្ដោតការយកចិត្តទុកដាក់ទៅលើការបង្កើនការទទួលព័ត៌មាន ចំណេះដឹង ជំនាញ ធនធានផ្ទាល់ខ្លួន និងសង្គម ធនធានសម្ភារៈ និងការចិញ្ចឹមកូនរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។

***រូបភាពទី ១. កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនក្នុងលក្ខណៈជាផ្នែកមួយនៃកិច្ចគាំទ្រគ្រួសារ***



*កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនត្រូវបានកំណត់និយមន័យថា ជា "កម្រងសេវា ឬសកម្មភាពដែលផ្តោតលើការកែលម្អរបៀបដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ យល់ឃើញ និងអនុវត្តកាតព្វកិច្ចរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កូន (ផ្លូវកាយ ផ្លូវចិត្ត បញ្ញា និងស្មារតី)"។*

កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន គ្របដណ្តប់ទៅលើអន្តរាគមន៍ ឬសេវាជាច្រើន ដែលសុទ្ធសឹងតែផ្តល់នូវព័ត៌មាន ការអប់រំជំនាញ និងកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន។ គេអាចបែងចែកបានរវាងអន្តរាគមន៍ទាក់ទងនឹងផ្នែកសុខភាព និងកិច្ចគាំទ្រទូទៅសម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនដែលទាក់ទងនឹងសុខភាព ត្រូវបានផ្តល់ជូនជាចម្បងតាមរយៈ ការចុះសួរសុខទុក្ខតាមផ្ទះក្នុងលក្ខណៈជាផ្នែកមួយនៃសេវាគាំពារសុខភាពមាតា និងទារក សម្រាប់ឪពុកម្តាយ (ជាពិសេសគឺម្តាយ) ដែលមានទារក និងកុមារតូចៗដែលទើបតែចេះវារ និងតោងឈរ។ កិច្ចគាំទ្រនេះអាចរួមមានការអប់រំសុខភាព និងសុខុមាលភាពរបស់ទារក និងកុមារ។ កិច្ចគាំទ្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** មានវិសាលភាពគ្របដណ្តប់លើសពីផ្នែកសុខភាព ព្រមទាំងផ្តោតលើការគ្រប់គ្រងទៅលើការប្រព្រឹត្តរបស់កុមារ ទំនាក់ទំនងរវាងកុមារជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងកិច្ចការពារកុមារ។

## ២.២. ការវិភាគអំពីស្ថានភាព

អំពើហិង្សាលើកុមារ កើតឡើងយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា[២]៖

- កុមារជាង ៥០% បានទទួលរងអំពើហិង្សាផ្លូវកាយ
- កុមារជាង ២៥% បានទទួលរងអំពើហិង្សាផ្លូវចិត្ត
- កុមារប្រមាណ ៥% បានទទួលរងអំពើរំលោភបំពានផ្លូវភេទយ៉ាងហោចណាស់ចំនួន១ដង
- កុមារប្រមាណ ៦០% យ៉ាងហោចណាស់បានទទួលរងអំពើហិង្សាចំនួនមួយទម្រង់ ដែលអាចជាអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ។

របកគំហើញដែលទទួលបានពីការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា បានគូសបញ្ជាក់អំពីតួនាទីមួយដ៏សំខាន់របស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំចំពោះការប្រើអំពើហិង្សា ហើយនៅតែបន្តកើតមានលើកុមារក្នុងប្រទេសកម្ពុជា។

- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គឺជាបុគ្គលទូទៅដែលបានប្រព្រឹត្តអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្តលើកុមារ។ ប្រមាណពាក់កណ្តាលនៃកុមារដែលមានអាយុចន្លោះពី ១៣-១៧ឆ្នាំ ដែលត្រូវបានអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាបានរងអំពើហិង្សាផ្លូវកាយ និងមួយភាគបួនបានរងអំពើហិង្សាផ្លូវចិត្តដែលប្រព្រឹត្តដោយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ រួមទាំងសាច់ញាតិដទៃទៀតដែលជាមនុស្សពេញវ័យ។
- កុមាររមែងតែងឃើញហេតុការណ៍នៃអំពើហិង្សារវាងមនុស្សពេញវ័យនៅផ្ទះ។ ក្នុងចំណោមកុមារអាយុចន្លោះពី ១៣-១៧ឆ្នាំ ដែលបាននិយាយថាពួកគេធ្លាប់បានឃើញអំពើហិង្សាផ្លូវកាយនៅផ្ទះ មានកុមារីចំនួន ៣៧.៤០% និងកុមារាចំនួន ៣៤.៧០% បានប្រាប់ឱ្យដឹងថាពួកគេបានឃើញអំពើហិង្សាបែបនេះក្នុងរយៈពេល ១២ ខែចុងក្រោយ[៣]។
- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ខិតខំការពារកូនរបស់ពួកគេពីអំពើហិង្សានៅកន្លែងជាច្រើនដែលកូនរបស់ពួកគេរស់នៅរាប់បញ្ចូលទាំងនៅផ្ទះ និងសាលារៀន។ ជាទូទៅ កុមារប្រឈមទៅនឹងអំពើហិង្សាផ្លូវកាយដែលប្រព្រឹត្តដោយគ្រូបង្រៀន និងអំពើរំលោភបំពានផ្លូវភេទពីអ្នកជិតខាង សមាជិកគ្រួសារ មិត្តភក្តិ និងដៃគូ ឬសង្សារ។ ការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា មិនបានធ្វើការវាស់វែងទៅលើការមិនអើពើ ឬការមិនយកចិត្តទុកដាក់ឡើយ ប៉ុន្តែអត្រាប្រេវ៉ាឡង់នៃការមិនអើពើ ឬការមិនយកចិត្តទុកដាក់ ត្រូវបានគេប៉ាន់ប្រមាណថា មានកម្រិតស្រដៀងគ្នា ឬខ្ពស់ជាងអំពើហិង្សាផ្លូវកាយ។

២. របកគំហើញនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣
៣. របកគំហើញនៃការសិក្សាស្រាវជ្រាវស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៣

របកគំហើញបែបគុណភាពនៃការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា បានបង្ហាញឱ្យឃើញអំពីកង្វះការប្រាស្រ័យទាក់ទងប្រកបដោយអត្ថន័យរវាងកុមារជាមួយមនុស្សពេញវ័យ រាប់បញ្ចូលកង្វះការប្រាស្រ័យទាក់ទងរវាងក្មេងជំទង់ជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំអំពីបញ្ហាផ្លូវភេទ និងការរួមភេទ។ បញ្ហានេះ ធ្វើឱ្យមានការព្រួយបារម្ភអាស្រ័យដោយភស្តុតាងសកលបង្ហាញឱ្យដឹងថា អំពើហិង្សាទំនងនឹងកើតឡើងច្រើនជាងនៅក្នុងគ្រួសារទាំងឡាយណា ដែលមានការលំបាកក្នុងអភិវឌ្ឍឱ្យមានទំនាក់ទំនងប្រកបដោយសុវត្ថិភាព ស្ថេរភាព និងអំណោយផលដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ មិនចំពោះថា តើកុមារម្នាក់កំពុងទទួលរងអំពើហិង្សា ឬយ៉ាងណានោះទេ ទំនាក់ទំនងដ៏ទន់ខ្សោយរវាងកុមារ ជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចបង្កើនហានិភ័យនៃការប្រព្រឹត្តកោងកាច និងហិង្សាដែលបង្ហាញឱ្យឃើញនៅក្នុងកុមារភាព ឬពេលក្រោយមកទៀតនៅក្នុងជីវិតរស់នៅរបស់ពួកគេ។

ប្រទេសកម្ពុជា មានកុមារជាច្រើនរស់នៅក្នុងមណ្ឌល (មានកុមារចំនួន ២៦,១៨៧ (កុមារី៤៨%) នាក់ រស់នៅក្នុងមណ្ឌលក្នុងឆ្នាំ២០១៤[៤]) ប៉ុន្តែភាគច្រើននៃកុមារទាំងនេះយ៉ាងហោចណាស់មានឪពុក ម្តាយ អាណាព្យាបាល ឬអ្នកថែទាំម្នាក់ដែលនៅរស់។ បញ្ហានេះនៅតែបន្តកើតមាន ទោះបីជាមានការទទួលស្គាល់ទូលំទូលាយថា ការថែទាំក្នុងមណ្ឌលមានផលវិបាក និងអវិជ្ជមានសម្រាប់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ និងបង្កឱ្យមានផលប៉ះពាល់ទៅលើជីវិតរស់នៅរបស់ពួកគេជាមនុស្សពេញវ័យ។

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប ចង់បាននូវអ្វីដែលប្រសើរបំផុតសម្រាប់កូនរបស់ពួកគេ ដូច្នេះអត្រាប្រេវ៉ាឡង់មួយដ៏ខ្ពស់នៃការចិញ្ចឹមកូនបែបអវិជ្ជមាន និងការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា គប្បីត្រូវយល់នៅក្នុងបរិបទនៃកត្តាជាច្រើនដែលជះឥទ្ធិពល និងធ្វើឱ្យធ្លាក់ចុះនូវសមត្ថភាពរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការចិញ្ចឹមកូនប្រកបដោយភាពវិជ្ជមាន។ កត្តាសំខាន់ៗមានដូចខាងក្រោម (និងដូចបង្ហាញនៅក្នុងរូបភាពទី២)។

- កុមារមានការប្រឈមកាន់តែខ្ពស់ទៅនឹងអំពើហិង្សា ប្រសិនបើឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំរបស់កុមារនោះ មានការរំពឹងទុកមិនសមស្របចំពោះការប្រព្រឹត្ត ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ ដើម្បីឆ្លើយតបឱ្យបានសមស្រប ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវដឹងអំពីអ្វីដែលពួកគេអាចរំពឹងថានឹងទទួលបានពីការប្រព្រឹត្តរបស់កុមារនៅដំណាក់កាលផ្សេងៗគ្នាក្នុងជីវិតរស់នៅ និងរបៀបគ្រប់គ្រងទៅលើការប្រព្រឹត្តទាំងនោះក្នុងលក្ខណៈមួយបែបវិជ្ជមាន។ ការរំពឹងទុកមិនសមស្របចំពោះការប្រព្រឹត្តរបស់កុមារ អាចបណ្តាលពីការយល់ដឹងមានកម្រិតទៅលើការលូតលាស់ និងអភិវឌ្ឍរបស់កុមារ ទម្លាប់ និងជំនឿជាក់លាក់មួយចំនួនអំពីការលូតលាស់ និងអភិវឌ្ឍទាំងនេះ ព្រមទាំងការអនុវត្តបែបប្រពៃណីដែលមានគ្រោះថ្នាក់។ ឧទាហរណ៍ ការជឿជាទូទៅថា ពួកគេមិនគួរសរសើរ ឬបង្ហាញក្តីស្រឡាញ់ចំពោះកុមារនោះទេ ដើម្បីកុំឱ្យពួកគេមានអាកប្បកិរិយាមិនសមរម្យ។
- អំពើហិង្សានឹងកើតឡើង ប្រសិនបើឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ មិនផ្តល់ភាពកក់ក្តៅ និងមិនសូវឆ្លើយតបចំពោះកុមារ ព្រមទាំងមានវិធីសាស្រ្តចិញ្ចឹមកូនដែលគ្រប់គ្រងខ្លាំងទៅលើកូន មានភាពកោងកាច ឬពុំមានការឯកភាពគ្នា។ សេចក្តីស្រឡាញ់ និងការឆ្លើយតបរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំចំពោះកូនអាចបណ្តាលមកពីកត្តាជាច្រើនរួមមាន បញ្ហាសុខភាពផ្លូវចិត្ត ការចូលរួមរបស់ឪពុកនៅមានកម្រិត ដែលជាទម្លាប់ និងជំនឿអំពីការចិញ្ចឹមកូន។ ឧទាហរណ៍ ការជឿថា ទណ្ឌកម្មលើរាងកាយ គឺជារឿងដែលអាចទទួលយកបាន (ឬសូម្បីតែជារឿងចាំបាច់ត្រូវអនុវត្ត) ក្នុងលក្ខណៈជាផ្នែកមួយនៃការចិញ្ចឹមកូន និងការជឿថាការថែទាំតាមមណ្ឌលមានសារៈប្រយោជន៍ចំពោះកុមារ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅជំនាន់បច្ចុប្បន្ន កំពុងទទួលរងនូវការថប់បារម្ភ ធ្លាក់ទឹកចិត្ត និងមានការបាក់ស្បាត (PTSD) ក្នុងកម្រិតមួយខ្ពស់ដោយសារតែរបបខ្មែរក្រហម ប៉ុន្តែវាក៏ដោយសារតែអំពើហិង្សាដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលក្នុងកម្រិតមួយខ្ពស់ផងដែរ។
- ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងប្រទេសកម្ពុជា ការចិញ្ចឹមកូនរបស់ពួកគេក្នុងបរិយាកាសដែលធ្វើឱ្យសុវត្ថិភាពកូនមានការប្រឈម ហើយស្របពេលជាមួយគ្នានោះ ពួកគេមានលទ្ធភាពតិចតួចក្នុងការទទួលបានចំណេះដឹង និងសេវាសម្រាប់កិច្ចការពារកុមារ។ ជាលទ្ធផល ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំខិតខំទាំងលំបាកក្នុងការការពារកូនពីអំពើហិង្សា និងខិតខំទាំងលំបាកក្នុងការទទួលស្គាល់ ព្រមទាំងគាំទ្រដល់កូន ប្រកបដោយប្រសិទ្ធភាព ប្រសិនបើអំពើហិង្សាកើតឡើង។
- ភាពក្រីក្រក្នុងប្រទេសកម្ពុជា បង្កឱ្យប៉ះពាល់ដល់ដំណើរការចិញ្ចឹមកូន ដែលភាគច្រើនគឺតាមរយៈផលប៉ះពាល់ទៅលើកត្តានានាដូចការលើកឡើងខាងលើ។ ទោះជាដូច្នេះក្តី ការចិញ្ចឹមកូនបែបអវិជ្ជមាន និងអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ក៏កើតឡើងទូទៅផងដែរនៅក្នុងគ្រួសារដែលមានជីវភាពមធ្យម និងគ្រួសារដែលមានជីវភាពខ្ពង់ខ្ពស់ក្នុងប្រទេសកម្ពុជា ដូច្នេះ ភាពក្រីក្រមិនត្រូវបានលើកឡើង ឬបង្ហាញឱ្យបានច្បាស់លាស់នៅក្នុងយុទ្ធសាស្រ្តនេះទេ។

៤. របាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារក្នុងរាជធានី-ខេត្តទាំង២៥នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៧

**ប្រអប់ទី ១. ការអនុវត្តវិន័យចំពោះកុមារ បែបប្រពៃណីក្នុងប្រទេសកម្ពុជា**

អំពើហិង្សាតែងកើតឡើងនៅក្នុងបរិបទនៃការចិញ្ចឹមកូនក្នុងទម្រង់ដោយអនុវត្តការដាក់ទណ្ឌកម្ម ឬ “ការអប់រំ”។ តាមរយៈការស្រាវជ្រាវបានបង្ហាញឱ្យឃើញអំពីវិធីសាស្ត្របែបប្រពៃណី ដើម្បីដោះស្រាយបញ្ហារបស់កុមារដែលមានដូចខាងក្រោម៖

១. នៅពេលដែលកូនធ្វើខុសលើកដំបូង ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំតែងណែនាំកូន ដោយប្រើប្រាស់ភាសាទន់ភ្លន់ និងបញ្ចុះបញ្ចូល ដើម្បីតម្រង់ទិសពួកគេឱ្យប្រព្រឹត្តត្រឹមត្រូវ

២. ប្រសិនបើកូនមិនស្ដាប់ និងធ្វើខុសដដែលម្ដងទៀត ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំនឹងស្ដីបន្ទោស គំរាម ឬជេរស្ដីកូន ដោយប្រើប្រាស់ភាសាធ្ងន់ៗ ដើម្បីបញ្ឈប់ការប្រព្រឹត្តនោះ

៣. ប្រសិនបើកូននៅតែបន្តមិនស្ដាប់បង្គាប់ទៀតនោះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំនឹងប្រើប្រាស់ទណ្ឌកម្មលើរាងកាយ អាស្រ័យទៅតាមកម្រិតនៃបញ្ហា និងកំហឹងរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។

ចំណុចទី២ និងចំណុចទី៣ខាងលើ គឺជាផ្នែកមួយនៃអំពើហិង្សាផ្លូវចិត្ត និងផ្លូវកាយ ព្រមទាំងមានផលវិបាកអវិជ្ជមានចំពោះកុមារ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងទំនាក់ទំនងរវាងពួកគេ។

**រូបភាពទី ២. ការវិភាគបញ្ហា[៥]**




៥. រូបភាពទី២ ផ្ដល់នូវការវិភាគបញ្ហាសង្ខេបមួយ ប៉ុន្តែមិនបានគ្របដណ្ដប់ទៅលើគ្រប់កត្តាទាំងអស់ដែលជះឥទ្ធិពលទៅលើការចិញ្ចឹមកូននៅកម្រិតផ្សេងៗគ្នានោះទេ ហើយក៏មិនបានគ្របដណ្ដប់ទៅលើអន្តរកម្មនៃកត្តាទាំងនោះដែរ។

ផលវិបាកនៃអំពើហិង្សាលើកុមារ រួមមានផលប៉ះពាល់ភ្លាមៗ (លក្ខណៈបុគ្គល) និងផលប៉ះពាល់ដែលបន្តកើតមាននៅក្នុងវ័យកុមារភាព វ័យជំទង់ និងជីវិតពេញវ័យ។ អំពើហិង្សាបង្កឱ្យប៉ះពាល់ដល់ការអភិវឌ្ឍផ្លូវកាយ ផ្លូវចិត្ត បញ្ញា និងស្មារតីរបស់កុមារ។ កុមារអាចបាត់បង់ការជឿទុកចិត្តទៅលើមនុស្សដទៃទៀត ពីព្រោះការជឿទុកចិត្តមានសារៈសំខាន់ចំពោះការលូតលាស់ និងអភិវឌ្ឍរបស់មនុស្ស និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសមត្ថភាពក្នុងការស្រឡាញ់ ការយល់ចិត្ត និងការអភិវឌ្ឍទំនាក់ទំនងល្អប្រសើរនៅពេលអនាគត។ ការបន្តប្រឈមទៅនឹងអំពើហិង្សា បង្កើតឱ្យមានវិបត្តិតានតឹង ដែលអាចបង្កគ្រោះថ្នាក់ដល់ការលូតលាស់ និងអភិវឌ្ឍខួរក្បាល និងអវយវៈដទៃទៀតរបស់កុមារតូច ព្រមទាំងបង្កើនការប្រឈមនៃជំងឺ ទាក់ទងនឹងវិបត្តិតប់ប្រមល់ និងកម្សោយចលករ (សមត្ថភាពក្នុងការគិតគូរពិចារណា រៀនសូត្រ និងយល់ដឹង)។

- អំពើហិង្សាអាចនាំឱ្យមានអាកប្បកិរិយាមួយចំនួនដែលប្រឈមចំពោះសុខភាពដូចជា ការជក់បារី ការទទួលទានគ្រឿងស្រវឹង និងការរួមភេទគ្មានសុវត្ថិភាព
- ការប្រព្រឹត្តទាំងនេះ គឺជាមូលហេតុចម្បងដែលនាំឱ្យមានជំងឺពិការភាព ឬស្លាប់
- ការទទួលរងអំពើហិង្សាតាំងពីកុមារ ធ្វើឱ្យមានការកើនឡើងនូវហានិភ័យដល់ខ្លួនឯង ក្លាយជាជនរងគ្រោះ ឬការប្រព្រឹត្តអំពើហិង្សា ព្រមទាំងការប្រើប្រាស់របៀបនៃការចិញ្ចឹមកូនបែបអវិជ្ជមាន ឬការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ នៅពេលដែលពួកគេក្លាយជាមនុស្សពេញវ័យ ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៣។

អំពើហិង្សាបង្កឱ្យមានបន្ទុកធ្ងន់ធ្ងរទៅលើសង្គមជារួម មានដូចជាថ្លៃចំណាយទាក់ទងនឹងការព្យាបាលបញ្ហាសុខភាពរបស់ជនរងគ្រោះ ថ្លៃចំណាយទៅលើសុខុមាលភាព និងបណ្តាលឱ្យមានការបាត់បង់ចំណូលនៅក្នុងគ្រួសារទៀតផង។

**រូបភាពទី ៣. វដ្តនៃអំពើហិង្សាពីជំនាន់មួយទៅជំនាន់មួយ**




***ការចិញ្ចឹមកូនបែបវិជ្ជមាន*** មានតួនាទីដ៏សំខាន់ក្នុងការទប់ស្កាត់អំពើហិង្សា និងជាចំណុចស្នូលនៃការអភិវឌ្ឍល្អប្រសើររបស់កុមារ។ ជីវិតគ្រួសារមួយប្រកបដោយស្នេហភាព និងសុវត្ថិភាព រាប់បញ្ចូលទំនាក់ទំនងបែបវិជ្ជមានជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឱ្យកុមារទទួលបានជោគជ័យនៅសាលារៀន មានទំនាក់ទំនងល្អជាមួយអ្នកដទៃ និងក្លាយជាមនុស្សពេញវ័យដែលមានផលិតភាពខ្ពស់ក្នុងសង្គមនៅពេលអនាគត។ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** អាចទប់ស្កាត់មិនឱ្យកុមារទទួលរងផលវិបាក និងភាពអវិជ្ជមានដទៃទៀតក្នុងជីវិត ដោយរាប់បញ្ចូលភាពក្រីក្រ និងអំពើហិង្សា។ ចំណុចនេះគូសបញ្ជាក់អំពីសារៈសំខាន់នៃការផ្តល់ឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនូវកិច្ចគាំទ្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន***។

យុទ្ធសាស្ត្រនេះ បញ្ជាក់អំពីសិទ្ធិកុមារដែលត្រូវទទួលបានការចិញ្ចឹមបីបាច់នៅក្នុងបរិយាកាសគ្រួសារមួយប្រកបដោយក្ដីស្រឡាញ់ និងដោយសមធម៌ ប៉ុន្តែក៏ទទួលស្គាល់ផងដែរថា ជួនកាលឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំអាចបង្កឱ្យមានគ្រោះថ្នាក់គួរឱ្យកត់សម្គាល់ទៅលើកុមារផងដែរ ដែលទាមទារឱ្យមានចំណាត់ការផ្ដល់កិច្ចការពារជាបន្ទាន់ ។ នៅក្នុងករណីទាំងនោះ ការថែទាំតាមគ្រួសារ និងតាមសហគមន៍ គឺជាជម្រើសដ៏ល្អប្រសើរសម្រាប់កុមារ។ ដោយឡែក ការថែទាំតាមមណ្ឌលគប្បីត្រូវបានចាត់ទុកថាជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្ដោះអាសន្នប៉ុណ្ណោះ។

### រូបភាពទី៤៖ ការវិភាគ នៃបញ្ហាយេនឌ័រ

| | |
|---|---|
| **ផ្នត់គំនិត របស់គ្រួសារ សហគមន៍ និងសង្គម** | • កូនស្រី ត្រូវបានគ្រួសារ និងសហគមន៍ទូន្មាន និងលើកទឹកចិត្តឱ្យធ្វើការងារផ្ទះសម្បែង សុភាពរាបសារ ទន់ភ្លន់ មិនសូវបានទទួលការអប់រំពេញលេញ ត្រៀមខ្លួនជាមេផ្ទះ និងភរិយាជាដើម។<br>• កូនប្រុសត្រូវបានគ្រួសារ និងសហគមន៍ ទូន្មាន លើកទឹកចិត្ត និងជំរុញឱ្យទទួលបានឱកាសអប់រំ រៀនសូត្រជ្រៅជ្រះ បំប៉នចំណីអាហារ និងពង្រឹងភាពក្លាហានជាដើម។ |
| **ផលប៉ះពាល់អវិជ្ជមាន** | • ស្ត្រី និងកុមារី ភាគច្រើនទទួលបានការអប់រំទាបជាងបុរស មិនសូវមានភាពក្លាហានងាយទទួលរងនូវការកេងប្រវ័ញ្ច និងរងអំពើហិង្សាផ្សេងៗ<br>• ស្ត្រី និងកុមារីមានការលំបាក និងមានឱកាសតិចតួច ក្នុងការចូលរួមក្នុងការងារអភិវឌ្ឍ សេដ្ឋកិច្ច សង្គម និងការធ្វើសេចក្ដីសម្រេចចិត្ត ។<br>• ស្ត្រីមានចំនួនតិចតួច ក្នុងការធ្វើសេចក្ដីសម្រេច ឬថ្នាក់ដឹកនាំ ក្នុងការងារសាធារណៈ ឯកជន និងនយោបាយ។ |

ជាទូទៅ សង្គម សហគមន៍ ជាពិសេសគ្រួសារ មិនមានបំណង និងរំពឹងថាស្ត្រី ឬកូនស្រីត្រូវតែមិនសូវមានភាពក្លាហាន ទទួលបានការអប់រំទាប ងាយរងគ្រោះដោយសារអំពើហិង្សា និងទទួលបានលទ្ធភាពតិចតួចក្នុងការចូលរួមប្រកបការងារចិញ្ចឹមជីវិតនោះទេ។ ប៉ុន្តែ ជាបទពិសោធន៍កន្លងមក យើងឃើញថា បញ្ហាដែលស្ត្រី និងកុមារីមិនសូវមានភាពក្លាហាន ទទួលបានការអប់រំទាបងាយរងគ្រោះដោយសារអំពើហិង្សានិងទទួលបាននូវលទ្ធភាពតិចតួច ក្នុងការចូលរួមប្រកបការងារចិញ្ចឹមជីវិតជាដើម គឺកើតចេញពីផ្នត់គំនិត និងការកំណត់ ដែលបែងចែក ឬរារាំងនូវសមភាព នៃការទទួលបានសិទ្ធិ និងឱកាសក្នុងការអភិវឌ្ឍមូលដ្ឋាន ជំនាញ និងជីវិតប្រចាំថ្ងៃរបស់ស្ត្រី និងកុមារី បើយើងប្រៀបធៀបជាទូទៅ។

យេនឌ័រ គឺតួនាទី ការងារ និងគុណតម្លៃរបស់បុរស ស្ត្រី ឬកុមារា កុមារី ដែលកំណត់ឡើងដោយសង្គម ឬគ្រួសារ និងអាចផ្លាស់ប្ដូរបាន។ មិនមែនរាល់ការកំណត់ និងផ្នត់គំនិតរបស់គ្រួសារ និងសង្គមដែលបែងចែក និងផ្ដល់ឱ្យខុសគ្នាទៅលើបុរស និងស្ត្រី កុមារា និងកុមារី សុទ្ធតែមានផលប៉ះពាល់អវិជ្ជមាននោះទេ ដូចនេះយើងធ្វើការងារកែប្រែ និងផ្លាស់ប្ដូរតែចំណុចណាដែលមានផលប៉ះពាល់ដល់ភាពស្មើគ្នា និងសមភាពនៃការទទួលបានសិទ្ធិ និងការចូលរួមពេញលេញក្នុងសង្គម និងការអភិវឌ្ឍនានា។ ឧទាហរណ៍ កន្លងមកគ្រួសារ និងសហគមន៍ភាគច្រើនបានរារាំង ឬហាមឃាត់មិនឱ្យកុមារីទទួលបានព័ត៌មាន និងការយល់ដឹងរឿងរ៉ាវពីការអប់រំ ថែទាំសុខភាព ទំនាក់ទំនងជាមួយនឹងមិត្តភក្តិ និងការបញ្ចេញយោបល់ច្រើន។ បើពិនិត្យលើចំណុចនេះ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ និងគ្រួសារពុំមានបំណងមិនល្អចំពោះកូនស្រីនោះទេ ប៉ុន្តែបើយើងវិភាគឱ្យស៊ីជម្រៅ កាលដែលស្ត្រី និងកុមារី មិនទទួលបាននូវព័ត៌មាន និងឱកាសទាំងនេះបានសមស្រប ដែលបណ្ដាលឱ្យពួកគេអាចជាជនងាយរងគ្រោះទៅវិញ។

**ការចិញ្ចឹមកូនតាមបែបវិជ្ជមានប្រកបដោយសមភាព និងសមធម៌** គឺជំរុញ និងលើកទឹកចិត្តឱ្យ *ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ* រួមគ្នាកែប្រែនូវឥរិយាបថ និងការប្រព្រឹត្តនានាដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមាន ជាពិសេសតាមរយៈការជំរុញ និងផ្ដល់ឱកាសឱ្យកុមារី និងកុមារា ទទួលបានស្មើគ្នាចំពោះការអប់រំ ការថែទាំ ទំនុកបម្រុងកិច្ចការពារផ្សេងៗ និងភាពអង់អាច ដើម្បីឱ្យពួកគេមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមការងារអភិវឌ្ឍ គ្រួសារ សហគមន៍ និងសង្គមជាតិ។

## ២.៣. បរិបទច្បាប់ និងគោលនយោបាយ

### បទប្បញ្ញត្តិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៧ បានចែងថា "មាតាបិតា" មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។

ក្របខ័ណ្ឌច្បាប់អន្តរជាតិសម្រាប់ផ្តល់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័ន ដោយប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២។ អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារតម្រូវឱ្យរដ្ឋភាគីផ្តល់ការគោរព ការពារ និងបំពេញសិទ្ធិរបស់កុមារតាមរយៈការគាំទ្រដល់កាតព្វកិច្ចឪពុកម្តាយក្នុងនាមជាអ្នកថែទាំបឋមរបស់កុមារ។ មតិយោបល់ទូទៅទី១៣ របស់គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារបញ្ជាក់ថា រដ្ឋសភា គឺត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារតាមរយៈ៖ *"ការគាំទ្រឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំឱ្យយល់ ទទួលយក និងអនុវត្តការចិញ្ចឹមកូនឱ្យបានល្អ ផ្អែកលើចំណេះដឹងអំពីសិទ្ធិកុមារ ការលូតលាស់ និងអភិវឌ្ឍកុមារ និងបច្ចេកទេសអនុវត្តវិន័យបែបវិជ្ជមាន ដើម្បីគាំទ្រដល់សមត្ថភាពគ្រួសារ ក្នុងការផ្តល់ឱ្យកុមារនូវការថែទាំក្នុងបរិយាកាសមួយប្រកបដោយសុវត្ថិភាព"។*

### គោលនយោបាយ និងកម្មវិធីរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់អំពីតួនាទីដ៏មានសារៈសំខាន់របស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ក្នុងការលើកកម្ពស់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ រាជរដ្ឋាភិបាលបានផ្តល់កម្រងនៃកិច្ចអន្តរាគមមួយចំនួនសម្រាប់គាំទ្រដល់ការចិញ្ចឹមកូន ជាពិសេសនៅក្នុងវិស័យគាំពារ និងអភិវឌ្ឍកុមារតូច (ECCD) ប៉ុន្តែការអនុវត្តជួបប្រទះការប្រឈមមួយចំនួន។

*គោលនយោបាយជាតិស្តីពី ការគាំពារ និងអភិវឌ្ឍកុមារតូច* (២០១០) គឺជាធាតុមួយសម្រាប់អន្តរាគមន៍អន្តរក្រសួង សំដៅកែលម្អការចិញ្ចឹមកូនក្នុងវ័យកុមារតូច (គិតចាប់ពីពេលកើតរហូតដល់អាយុ ៦ឆ្នាំ)។ ការអប់រំអំពីការចិញ្ចឹមកូនទាក់ទងនឹងសុខភាព ភាគច្រើនត្រូវបានផ្តល់ជូនដោយក្រសួងសុខាភិបាល ក្នុងលក្ខណៈជាផ្នែកមួយនៃសេវាសុខភាពមាតា និងទារកតាមមន្ទីរពេទ្យ មណ្ឌលសុខភាព និងនៅកម្រិតសហគមន៍ដែលផ្តល់ជូនដោយឆ្មប និងក្រុមទ្រទ្រង់សុខភាពភូមិ។ ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការងារជាមួយអ្នកស្ម័គ្រចិត្តសហគមន៍ (ឪពុកម្តាយបង្គោល) ដែលផ្តល់ការអប់រំអំពីការចិញ្ចឹមកូនទាក់ទងនឹងការថែទាំ និងការអភិវឌ្ឍកុមារតូច ជូនដល់ក្រុមឪពុកម្តាយ ដែលភាគច្រើនគឺជាម្តាយមានកូន អាយុចន្លោះពី 0-៦ឆ្នាំ។ បច្ចុប្បន្នកញ្ចប់ឯកសារអប់រំអំពីការចិញ្ចឹមកូនដែលត្រូវបានផ្តល់ជូនតាមរយៈអ្នកស្ម័គ្រចិត្តសហគមន៍ កំពុងត្រូវបានពិនិត្យកែសម្រួលឡើងវិញ។ ទោះបីជាអន្តរាគមន៍អប់រំអំពីការចិញ្ចឹមកូនរបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា បានជ្រាបទៅដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាច្រើនក៏ដោយ ក្រសួងទាំងពីរនេះនៅតែជួបប្រទះបញ្ហាប្រឈមអំពីសមត្ថភាពរបស់បុគ្គលិក ការធានាគុណភាព និងការចូលរួមរបស់ឪពុក ចំពោះបញ្ហាការការពារកុមារ កាគ្រប់គ្រងទៅលើការប្រព្រឹត្តរបស់កុមារ និងទំនាក់ទំនងរវាងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយនឹងកូននៅមានកម្រិតក្នុងការចិញ្ចឹមកូនបែបវិជ្ជមាន។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានអាណត្តិការងារគ្រប់គ្រងលើបញ្ហាសុខុមាលភាពសង្គម ដែលរាប់បញ្ចូលសុខុមាលភាពកុមារផងដែរ និងមានតួនាទីឈានមុខក្នុងការគាំទ្រគ្រួសារងាយរងគ្រោះ កែលម្អសមត្ថភាពចិញ្ចឹមកូនរបស់ពួកគេ ដែលនាំឱ្យកាត់បន្ថយបានចំពោះហានិភ័យការពារកុមារ។ *ក្របខ័ណ្ឌគោលនយោបាយ និងបទដ្ឋានព្រមទាំងគោលការណ៍ណែនាំស្តីពីការថែទាំជំនួសសម្រាប់ការថែទាំ គាំទ្រ និងការពារកុមារកំព្រា និងកុមាររងគ្រោះ* គឺជាមគ្គុទ្ទេសក៍ណែនាំដល់បុគ្គលិកសង្គមកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅកម្រិតថ្នាក់ស្រុក ក្នុង

ការផ្តល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនដល់គ្រួសារងាយរងគ្រោះ ដើម្បីថែរក្សា និងបង្រួបបង្រួមគ្រួសារ។ បទដ្ឋាន ៥.១០ មានការពាក់ព័ន្ធជាពិសេស ៖ *"កម្មវិធីគប្បីអប់រំគ្រួសារ និងសហគមន៍អំពីការអភិវឌ្ឍកុមារ និងបច្ចេកទេសចិញ្ចឹមកូន ដូចជា* ***ការអនុវត្តវិន័យបែបវិជ្ជមាន*** *និងការប្រាស្រ័យទាក់ទងដោយប្រុងប្រយ័ត្នជាមួយកុមារ"*។ បើទោះជាដូច្នេះក្តី សមត្ថភាព ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកម្រិត ព្រមទាំងកង្វះរចនាសម្ព័ន្ធផ្លូវការនៅកម្រិតថ្នាក់ឃុំ សង្កាត់ គឺជាឧបសគ្គដ៏ចម្បងចំពោះបុគ្គលិកសង្គមកិច្ច ក្នុងការអនុវត្តតួនាទីប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលជាច្រើន កំពុងគាំទ្រដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងការជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តសង្គមកិច្ចសហគមន៍ ដើម្បីដោះស្រាយភាពខ្វះចន្លោះទាំងនេះ។

ក្រសួងកិច្ចការនារីទទួលស្គាល់អំពីទំនាក់ទំនងរវាងអំពើហិង្សាលើស្ត្រី និងកុមារ និងសក្តានុពលនៃកម្មវិធីអប់រំអំពីការចិញ្ចឹមកូន ដើម្បីដោះស្រាយអំពើហិង្សា និងលើកកម្ពស់សមភាពយេនឌ័រ។ *ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ( ឆ្នាំ២០១៤-២០១៨ ) និងការប្តេជ្ញាចិត្តស្នូលរបស់ក្រសួងកិច្ចការនារីដើម្បីឆ្លើយតបទៅនឹងគំហើញដែលទទួលបានពីការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា* មានគោលបំណងលើកកម្ពស់ចំណេះដឹង ការយល់ដឹង និងជំនាញ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ក្នុងលក្ខណៈជាយុទ្ធសាស្ត្រមួយដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ និងលើកកម្ពស់សមភាពយេនឌ័រ។ ការអនុវត្តកិច្ចគាំទ្រចំពោះការចិញ្ចឹមកូន អាស្រ័យទៅលើកិច្ចសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធសំខាន់ៗដទៃទៀត។ ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីរាជធានី ខេត្តក្រុង ស្រុក ខណ្ឌផ្តល់ការផ្សព្វផ្សាយនៅសាលាមធ្យមសិក្សា និងសាកលវិទ្យាល័យ អំពីសីលធម៌ ជំនាញ និងបំណិនជីវិត។ កម្មវិធីបណ្តុះបណ្តាលទាំងនោះ រួមបញ្ចូលទាំងបញ្ហាដែលមានទំនាក់ទំនងដោយប្រយោលទៅនឹងការចិញ្ចឹមកូន។

កិច្ចគាំទ្រដទៃទៀតរបស់រាជរដ្ឋាភិបាលសម្រាប់ការចិញ្ចឹមកូនមិនសូវបង្ហាញឱ្យឃើញច្បាស់លាស់ ឬត្រូវបានផ្តល់ជូនតាមរយៈរចនាសម្ព័ន្ធក្រៅប្រព័ន្ធ។ គ្រូបង្រៀនមត្តេយ្យសិក្សា និងបឋមសិក្សា ប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អំពីសមិទ្ធិកម្ម និងសុខុមាលភាពរបស់កុមារនៅឯសាលារៀន ប៉ុន្តែពុំមានតួនាទីផ្លូវការនៅក្នុងកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនឡើយ។ មេដឹកនាំសាសនាដែលស្ថិតក្រោមក្រសួងធម្មការ និងសាសនា គឺជាប្រភពមួយដ៏សំខាន់សម្រាប់ផ្តល់កិច្ចគាំទ្រ និងដំបូន្មាន (ផ្នែកសីលធម៌) ជូនដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។

បើទោះបីជាក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សុទ្ធសឹងតែមានអាណត្តិការងារតាមវិស័យ ដែលមានទំនាក់ទំនងផ្ទាល់ទៅនឹងការផ្តល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនក៏ដោយ ប៉ុន្តែក្រសួងមហាផ្ទៃ មានសារៈសំខាន់ខ្លាំងណាស់ចំពោះរចនាសម្ព័ន្ធ សមត្ថភាព ថវិកា និងការអនុវត្តនៅថ្នាក់មូលដ្ឋាន។ ក្រសួងមហាផ្ទៃមានអាណត្តិការងារក្នុងការសម្របសម្រួលផ្តល់សេចក្តីណែនាំ និងគាំទ្របច្ចេកទេសទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះក្រសួងនេះទទួលខុសត្រូវចំពោះការកសាង និងពង្រឹងកិច្ចគាំទ្ររបស់ពួកគេ និងផ្តល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនតាមរយៈប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ ក្នុងនាមជាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គកនក) និងជាពិសេស គឺអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ដើរតួនាទីដ៏សំខាន់ក្នុងកិច្ចការពារកុមារ ធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការបែងចែកធនធានសម្រាប់សេវាសង្គម និងសេចក្តីសម្រេចទាក់ទងនឹងការដាក់កុមារក្នុងមណ្ឌល។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមាររបស់គកនក អាចផ្តល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន និងការបញ្ជូនប្រកបដោយសក្តានុពល ប៉ុន្តែដូចគ្នាទៅនឹងរចនាសម្ព័ន្ធដទៃទៀតដែរ សមត្ថភាព និងធនធានរបស់គកនកនៅមានកម្រិត។

ឆ្លើយតបទៅនឹងគំហើញ ដែលទទួលបានពីការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ក្រសួងស្ថាប័នរដ្ឋាភិបាលសំខាន់ៗ បានប្តេជ្ញាទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ក្នុងនោះមានក្រសួងស្ថាប័នដែលពាក់ព័ន្ធទៅនឹងការផ្តល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនដូចខាងក្រោម ៖

| | |
|---|---|
| **ក្រសួងកិច្ចការនារី** | ដឹកនាំ និងសម្របសម្រួលក្នុងការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រផ្លាស់ប្តូរការប្រព្រឹត្ត និង**សង្គមជាពហុវិស័យដែលគ្រប់ជ្រុងជ្រោយមួយ** ដើម្បីឆ្លើយតបទៅនឹងទម្លាប់សង្គម និង**វប្បធម៌**ដែលលើកកម្ពស់ និងចាត់ទុកអំពើហិង្សាលើកុមារថាជាអំពើស្របច្បាប់។ រួមចំណែកចំពោះកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន និងការអប់រំគ្រួសារ និងកុមារតូច ដើម្បីលើកកម្ពស់ទម្រង់អហិង្សានៃការអនុវត្តវិន័យលើកុមារ និងការពារកុមារពីអំពើហិង្សា និងអំពើរំលោភបំពានផ្សេងៗ។ |
| **ក្រសួងសុខាភិបាល** | ពង្រឹងការផ្តល់សេវាតាមសហគមន៍ រាប់បញ្ចូលកិច្ចគាំទ្រគ្រួសារ ការអប់រំអំពីការលូតលាស់ និងអភិវឌ្ឍខួរក្បាល និងរាងកាយកុមារ និងការលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃអំពើហិង្សាលើកុមារ និងការដាក់ទណ្ឌកម្មលើរាងកាយ ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងកុមារ ជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ឱ្យមានសុវត្ថិភាព ស្នេហភាព និងអំណោយផលដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | ធ្វើសមាហរណកម្មយុទ្ធសាស្ត្រ ***ការចិញ្ចឹមកូនបែបវិជ្ជមាន***និងភាពជាឪពុកបែបវិជ្ជមាន ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារ ទៅក្នុងគោលការណ៍ណែនាំសម្រាប់ការអប់រំឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ព្រមទាំងការបណ្តុះបណ្តាលអ្នកអប់រំ ក្នុងលក្ខណៈជាផ្នែកមួយនៃការងាររបស់ខ្លួន ទាក់ទងនឹងការអប់រំ ការលូតលាស់ និងអភិវឌ្ឍកុមារតូច។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | គាំទ្រដល់ការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រផ្លាស់ប្តូរការប្រព្រឹត្ត និងសង្គមពហុវិស័យគ្រប់ជ្រុងជ្រោយមួយ ដើម្បីដោះស្រាយទម្លាប់សង្គម និងវប្បធម៌ដែលលើកកម្ពស់ និងចាត់ទុកអំពើហិង្សាលើកុមារថាជាអំពើស្របច្បាប់។<br>វិនិយោគនៅក្នុងប្រព័ន្ធសុខុមាលភាពសង្គម និងសុខុមាលភាពកុមារ នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្កលក្ខណៈឱ្យមានការពង្រីក និងការបណ្តុះបណ្តាលធនធានមនុស្ស ការងារសង្គមកិច្ច និងបង្កើនថវិកាសម្រាប់សេវាគាំទ្រសង្គម។ |
| **ក្រសួងមហាផ្ទៃ** | សម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងមួយនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ទំនាក់ទំនងប្រកបដោយស្នេហភាព សុវត្ថិភាព និងអំណោយផលដល់ទំនាក់ទំនងរវាងកូនជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដោយអំពាវនាវមិនឱ្យមានការអធ្យាស្រ័យដាច់ខាតចំពោះអំពើហិង្សាលើរាងកាយ។ |
| **ក្រសួងធម្មការ និងសាសនា** | ផ្សព្វផ្សាយគោលការណ៍សាសនា ដើម្បីទប់ស្កាត់ទណ្ឌកម្មលើរាងកាយ និងអំពើហិង្សាផ្លូវចិត្តលើកុមារ និងដើម្បីលើកកម្ពស់គោលការណ៍សាសនាស្តីពីទម្រង់អហិង្សានៃការអនុវត្តវិន័យលើកុមារ ក្នុងការអប់រំកុមារ ដើម្បីធានាឱ្យមាននូវទំនាក់ទំនងប្រកបដោយស្នេហភាព សុវត្ថិភាព និងអំណោយផលដល់ទំនាក់ទំនងរវាងកូនជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ<br>លើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់នៃការលេងល្បែងស៊ីសង គ្រឿងញៀន និងគ្រឿងស្រវឹង ក្នុងចំណោម ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ កុមារ និងយុវជន ដោយលើកកម្ពស់យ៉ាងសកម្មចំពោះការប្រព្រឹត្តបែបវិជ្ជមាន និងសុចរិតភាព។ |

## កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនដោយអង្គការសង្គមស៊ីវិល

ប្រទេសកម្ពុជាមានកិច្ចគាំទ្រចំពោះការចិញ្ចឹមកូនជាច្រើនយ៉ាងទូលំទូលាយ ដែលផ្តល់ជូនដោយអង្គការសង្គមស៊ីវិលរាប់បញ្ចូល កិច្ចគាំទ្រដែលទាក់ទងនឹង***ការចិញ្ចឹមកូនបែបវិជ្ជមាន***ផងដែរ។ ការគណនាសន្ទស្សន៍មួយទៅលើកម្មវិធីអប់រំអំពីការចិញ្ចឹមកូន ដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៥ បានផ្តោតលើកម្មវិធីអប់រំអំពីការចិញ្ចឹមកូនចំនួន ១១ស្ថាប័ន ដែលមានគំរូជាច្រើនផ្សេងៗគ្នា (សូមមើលរូបភាពទី៤)។ កម្មវិធីស្ទើរតែទាំងអស់ត្រូវបានផ្តល់ជូននៅកម្រិតសកល ដែលកំណត់គោលដៅទៅលើឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប ដោយពុំមានវិធានការជាក់លាក់សម្រាប់កំណត់គោលដៅគ្រួសារប្រឈមទៅនឹងអំពើហិង្សា ឬការបំបែកកុមារពីគ្រួសារឡើយ។

គោលដៅនៃកិច្ចគាំទ្រចំពោះការចិញ្ចឹមកូនរបស់សង្គមស៊ីវិល សុទ្ធសឹងតែទាក់ទងទៅនឹងការលើកកម្ពស់ *"បរិយាកាសមួយប្រកបដោយសុវត្ថិភាព មានក្តីស្រឡាញ់ និងភាពកក់ក្តៅសម្រាប់កុមារ ដើម្បីធានាឱ្យបាននូវការលូតលាស់របស់មនុស្សជំនាន់ក្រោយឱ្យបានល្អប្រសើរ និងសមស្រប"*។ មិនមានស្ថាប័នណាមួយ ត្រូវបានរកឃើញថាមានកម្មវិធីអំពីរបៀបទប់ស្កាត់អំពើហិង្សាលើកុមារ និងការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ឡើយ។ ការគណនាសន្ទស្សន៍បានកំណត់រកឃើញអន្តរាគមន៍មួយចំនួនសម្រាប់ការចិញ្ចឹមកូននៅក្នុងប្រទេសកម្ពុជាដែលត្រូវបានវាយតម្លៃដោយអ្នកខាងក្រៅ (សូមមើលប្រអប់ទី២)។ បើទោះជាដូច្នេះក្តី ការវាយតម្លៃទាំងនេះ មិនទាន់មានភាពរឹងមាំគ្រប់គ្រាន់ដើម្បីកំណត់អំពីប្រសិទ្ធភាពរបស់វាក្នុងការលើកកម្ពស់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងមិនបានវាស់វែងទៅលើ អំពើហិង្សាជាក់ស្តែងថាជាលទ្ធផលមួយឡើយ។ ដូច្នេះ គេត្រូវការឱ្យមានការស្រាវជ្រាវគ្រប់ជ្រុងជ្រោយជាងនេះបន្ថែមទៀត ដើម្បីជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តថាតើអន្តរាគមន៍ ណាខ្លះមានសក្តានុពល ដើម្បីពង្រីកបន្ថែម។

**រូបភាពទី ៤. គំរូនៃកម្មវិធីអប់រំអំពីការចិញ្ចឹមកូនរបស់អង្គការសង្គមស៊ីវិល**




បន្ថែមពីលើអន្តរាគមន៍ ដែលត្រូវបានរកឃើញតាមរយៈការអនុវត្តគណនាសន្ទស្សន៍ មានអន្តរាគមន៍មួយទៀតប្រកបដោយសក្តានុពល គឺបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។ បណ្តាញទូរស័ព្ទជំនួយកុមារ ផ្តល់នូវការប្រឹក្សាយោបល់ និងកិច្ចគាំទ្រតាមទូរស័ព្ទដោយឥតគិតថ្លៃសម្រាប់កុមារ និងយុវជន។ គេប៉ាន់ប្រមាណថាមានការហៅទូរស័ព្ទចំនួន ១០% ពីឪពុកម្តាយវ័យក្មេង និងយុវវ័យ ដែលមានសំណួរអំពីការចិញ្ចឹមកូន។

មានកិច្ចគាំទ្រមួយចំនួនសម្រាប់ការចិញ្ចឹមកូន ប៉ុន្តែអន្តរាគមន៍មានភាពបែកខ្ញែកពីគ្នា និងមានភស្តុតាងតិចតួច ឬគ្មានភស្តុតាងបញ្ជាក់ទាល់តែសោះអំពីប្រសិទ្ធផល និងប្រសិទ្ធភាពនៃអន្តរាគមន៍ទាំងនោះ ហើយអន្តរាគមន៍ជាច្រើនរងផលប៉ះពាល់ដោយបញ្ហាធនធានមនុស្ស និងធនធានហិរញ្ញវត្ថុនៅមានកម្រិត។ រាជរដ្ឋាភិបាលបានផ្តល់កិច្ចគាំទ្រជាច្រើនសម្រាប់ការចិញ្ចឹមកូន ប៉ុន្តែជាទូទៅ គុណភាព និងធនធាននៃអន្តរាគមន៍នៅមានកម្រិត និងភាគច្រើនផ្តោតលើបញ្ហាសុខភាព និងអាហារូបត្ថម្ភ (ការអនុវត្តសំខាន់ៗរបស់គ្រួសារ) និងការចិញ្ចឹមកុមារតូច (ការរៀនសូត្រ និងការជំរុញពីដំបូង)។ កម្មវិធីអប់រំអំពីការចិញ្ចឹមកូនដែលផ្តល់ជូនដោយអង្គការសង្គមស៊ីវិល បានផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ប៉ុន្តែលទ្ធផលសម្រេចបាននៅមានកម្រិតនៅឡើយ ដូច្នេះមានការដឹងនូវព័ត៌មានអំពីប្រសិទ្ធភាពនៃកម្មវិធីទាំងនេះ ហើយអន្តរាគមន៍មានភាពបែកខ្ញែកពីគ្នា។

### ប្រអប់ទី ២. អន្តរាគមន៍ចំពោះការចិញ្ចឹមកូនប្រកបដោយសក្តានុពលក្នុងប្រទេសកម្ពុជា

**ការពង្រឹងប្រព័ន្ធសហគមន៍សម្រាប់កិច្ចការពារកុមារ**

កម្មវិធីអប់រំអំពីការចិញ្ចឹមកូនមួយរបស់អង្គការ Save the Children និងអង្គការសេវាសង្គមកិច្ចកម្ពុជា ត្រូវបានអនុវត្តក្រោមភាពជាដៃគូជាមួយអង្គការ WOMEN ក្នុងខេត្តព្រៃវែង។ អ្នកស្ម័គ្រចិត្តភូមិត្រូវបានបណ្តុះបណ្តាលលើជំនាញ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ហើយបន្តការបណ្តុះបណ្តាលនេះដល់ក្រុមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ ការវាយតម្លៃបែបគុណភាពមួយ បានរកឃើញផលប៉ះពាល់វិជ្ជមានទៅលើចំណេះដឹង និងការយល់ដឹងរបស់ឪពុកម្តាយអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងការប្រព្រឹត្តរបស់ឪពុកម្តាយនៅពេលចិញ្ចឹមកូន ប៉ុន្តែក្នុងកម្រិតមួយទាបនៅឡើយ។

**ការចិញ្ចឹមកូនប្រកបដោយជំនាញ**

កម្មវិធីអប់រំអំពីការចិញ្ចឹមកូនមួយរបស់អង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា ត្រូវបានអនុវត្តក្រោមភាពជាដៃគូជាមួយអង្គការពន្លឺកុមារ ក្នុងខេត្តឧត្តរមានជ័យ។ អ្នកសម្របសម្រួលត្រូវបានបណ្តុះបណ្តាលដោយអង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា ដើម្បីផ្តល់អន្តរាគមន៍ចំពោះការចិញ្ចឹមកូនរបស់ក្រុមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ ក្នុងករណីខ្លះ សកម្មភាពនេះត្រូវបានច្របាច់បញ្ចូលគ្នាជាមួយក្រុមសន្សំប្រាក់។ ការវាយតម្លៃមួយ (ការរៀបចំក្រោយពេលធ្វើតេស្ត បែបគុណភាព និងបរិមាណ) បានរកឃើញផលប៉ះពាល់វិជ្ជមានមួយទៅលើចំណេះដឹង ជំនាញ និងការប្រព្រឹត្តរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងការយល់ដឹងសាធារណៈអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន***។

**គម្រោងសម្លេងរបស់កុមារ**

គម្រោងនេះ ពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលដែលផ្តល់ជូនដោយអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់កម្ពុជា ដើម្បីពង្រឹងសមត្ថភាពរបស់មេដឹកនាំសាសនា និងបុគ្គលិកអង្គការសង្គមស៊ីវិល ដើម្បីផ្តល់អន្តរាគមន៍ចំពោះការចិញ្ចឹមកូនតាមក្រុមនៅក្នុងសហគមន៍។ ការវាយតម្លៃមួយក្នុងចំណោមអ្នកចូលរួម (មេដឹកនាំសាសនា បុគ្គលិកអង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍) ក្នុងខេត្តពោធិ៍សាត់ និងតាកែវបានរកឃើញថា មានការកើនឡើងនូវចំណេះដឹងអំពីការលូតលាស់ និងអភិវឌ្ឍរបស់កុមារ និង ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ព្រមទាំងភស្តុតាងមិនច្បាស់ការអំពីផលប៉ះពាល់វិជ្ជមានទៅលើជីវិតគ្រួសារ និងការងាររបស់អ្នកចូលរួម។

## ២.៤. ភស្តុតាង៖ តើយើងដឹងអ្វីខ្លះពីកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូន?

ផ្នែកនេះផ្តល់នូវទិដ្ឋភាពទូទៅមួយនៃភស្តុតាង ផ្អែកលើកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូន ដែលមានគោលបំណងទប់ស្កាត់អំពើហិង្សាលើកុមារ។ មូលដ្ឋានភស្តុតាងដ៏មានកម្រិតនៅក្នុងប្រទេសកម្ពុជា ទាមទារឱ្យយើងក្រឡេកមើលភស្តុតាងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ដទៃទៀត។ គេមិនអាចសន្និដ្ឋានថា កម្មវិធីដែលទទួលបានជោគជ័យនៅក្នុងបរិបទមួយនឹងមានប្រសិទ្ធភាពនៅពេលអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជាឡើយ ដោយសារតែភាពខុសគ្នាផ្នែកវប្បធម៌ និងបរិបទនៅក្នុងកត្តាហានិភ័យ និងកត្តាការពារដែលទាក់ទងទៅនឹងអំពើហិង្សា។ ភស្តុតាងដ៏រឹងមាំបំផុត មានប្រភពពីកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនប្រកប

ដោយបទដ្ឋានដែលត្រូវបានអភិវឌ្ឍនៅក្នុងប្រទេសមានប្រាក់ចំណូលខ្ពស់ដោយកំណត់ថ្លៃសោហ៊ុយខ្ពស់ សម្រាប់ការប្រើប្រាស់របស់ពួកគេ។ យុទ្ធសាស្ត្រនេះ មិនបានទាមទារឱ្យមានកម្មវិធីអប់រំអំពីការចិញ្ចឹមកូនប្រកបដោយបទដ្ឋានក្នុងប្រទេសកម្ពុជាបែបនេះទេ ប៉ុន្តែគេនឹងធ្វើការបញ្ចូលមេរៀនបទពិសោធន៍ដែលបានរៀនសូត្រ។

ក្នុងកម្រិតសកល កម្មវិធីអប់រំស្តីពីការចិញ្ចឹមកូន មានប្រសិទ្ធភាពក្នុងការកាត់បន្ថយកម្រិតនៃអំពើហិង្សាលើកុមារ និងលើកកម្ពស់លទ្ធផលវិជ្ជមានក្នុងការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ ការត្រួតពិនិត្យឡើងវិញក្នុងលក្ខណៈជាប្រព័ន្ធមួយទៅលើការសិក្សាស្រាវជ្រាវចំនួន ១២ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងប្រទេសមានប្រាក់ចំណូលមធ្យម បានរកឃើញផលប៉ះពាល់វិជ្ជមានទៅលើលទ្ធផលចិញ្ចឹមកូន ក្នុងនោះរួមមាន ការប្រាស្រ័យទាក់ទងរវាងកូនជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ព្រមទាំងឥរិយាបថ និងចំណេះដឹងរបស់ពួកគេ និងការចិញ្ចឹមកូនដោយអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។ គេបានបង្ហាញឱ្យឃើញថា កម្មវិធីអប់រំអំពីការចិញ្ចឹមកូនអាចកែលម្អ ការចិញ្ចឹមកូននៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និងប្រាក់ចំណូលមធ្យម បើទោះបីជាអាចមានលទ្ធភាពមួយចំនួនដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជួបប្រទះបញ្ហាប្រឈមជាច្រើនដទៃទៀតដូចជា ភាពក្រីក្រ និងបរិយាកាសរស់នៅលំបាក។

កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន តាមរយៈការចុះសួរសុខទុក្ខតាមផ្ទះ កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនតាមក្រុម និងការច្របាច់បញ្ចូលគ្នានូវប្រភេទកិច្ចគាំទ្រទាំងពីរនេះ គឺជាអន្តរាគមន៍ដែលមានសក្តានុពលបំផុត ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារ។

ការចុះសួរសុខទុក្ខតាមផ្ទះដោយផ្ទាល់ មានគោលបំណងផ្តល់កិច្ចគាំទ្រផ្នែកស្មារតី និងការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ចំណេះដឹង ជំនាញ និងការប្រព្រឹត្តបែបវិជ្ជមានរបស់ឪពុកម្តាយ ព្រមទាំងធ្វើការប៉ាន់ប្រមាណទៅលើស្ថានភាពគ្រួសារ ហើយក៏ផ្តល់ឱកាសដើម្បីភ្ជាប់ទំនាក់ទំនងគ្រួសារជាមួយសេវាសហគមន៍ដទៃទៀតទៅតាមភាពចាំបាច់ផងដែរ។ ឧទាហរណ៍ ការវាយតម្លៃប្រកបដោយគុណភាពខ្ពស់នៃកម្មវិធីចុះសួរសុខទុក្ខតាមផ្ទះនៅអាហ្វ្រិកខាងត្បូង និងប៉ាគីស្ថាន បានបង្ហាញឱ្យដឹងថា ការចុះសួរសុខទុក្ខតាមផ្ទះដោយអ្នកដែលមិនមានជំនាញវិជ្ជាជីវៈនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប អាចធ្វើឱ្យទំនាក់ទំនងរវាងកូនជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ មានភាពប្រសើរឡើង និងកាត់បន្ថយការអនុវត្តការចិញ្ចឹមកូនបែបអវិជ្ជមាន ហើយចំណុចទាំងពីរនេះ គឺជាកត្តាការពារដែលប្រឆាំងទៅនឹងអំពើហិង្សាលើកុមារ។

ការផ្តល់អន្តរាគមន៍តាមក្រុម ចំពោះការចិញ្ចឹមកូន ក៏មានគោលបំណងលើកកម្ពស់ចំណេះដឹង ជំនាញ និងការប្រព្រឹត្តបែបវិជ្ជមានរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំផងដែរ ប៉ុន្តែអន្តរាគមន៍បែបនេះ ត្រូវបានធ្វើឡើងតាមរយៈ វគ្គជំនួបជាក្រុមក្នុងការបណ្តុះបណ្តាល ឬការអប់រំ។ បើធៀបទៅនឹងការចុះសួរសុខទុក្ខតាមផ្ទះ គុណសម្បត្តិនៃកិច្ចគាំទ្រតាមក្រុមចំពោះការចិញ្ចឹមកូន គឺជាការផ្តល់ឱកាសដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំឱ្យធ្វើការចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមក។ ការអន្តរាគមតាមក្រុម អាចពង្រឹងបណ្តាញគាំទ្រសង្គមក្នុងអំឡុងពេល និងក្រោយពេលអន្តរាគមន៍ដែលជាកត្តាការពារមួយប្រឆាំងទៅនឹងអំពើហិង្សា។ ឧទាហរណ៍ ការអន្តរាគមតាមក្រុមចំពោះការចិញ្ចឹមកូន ដែលត្រូវបានអនុវត្តនៅឯព្រំដែនថៃ-ភូមា ដែលធ្វើឱ្យឃើញមានការកើនឡើងនូវ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងការប្រាស្រ័យទាក់ទងរវាងកុមារជាមួយនឹងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ហើយមានការថយចុះនូវឥរិយាបថការចិញ្ចឹមកូនបែបអវិជ្ជមាន (រាប់បញ្ចូលទម្រង់មួយចំនួននៃការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ) ដោយបង្កើននូវទំនាក់ទំនងស្និទ្ធស្នាលនៅក្នុងគ្រួសារ។

ប្រអប់ទី៣ ខាងក្រោមនឹងផ្តល់នូវសេចក្តីសង្ខេបអំពីសមាសធាតុសំខាន់ៗ នៃការចិញ្ចឹមកូនប្រកបដោយប្រសិទ្ធភាព។

មានភស្តុតាងតិចតួច ដែលបង្ហាញថាប្រសិទ្ធភាពនៃការផ្តល់អន្តរាគមន៍តាមប្រព័ន្ធផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើហិង្សានៅមានកម្រិតក្នុងតំបន់ដែលមានប្រាក់ចំណូលទាប។ ចំពោះអន្តរាគមន៍ដែលឈរតែឯង អន្តរាគមន៍ទាំងនេះមិនទំនងថានឹងអាចធ្វើការផ្លាស់ប្តូរឥរិយាបថចិញ្ចឹមកូនបានឡើយ ហើយក៏មិនប្រាកដថានឹងអាចកាត់បន្ថយកម្រិតនៃអំពើហិង្សាលើកុមារបានដែរ។ ភស្តុតាងដែលទទួលបានពីការអន្តរាគមតាមប្រព័ន្ធផ្សព្វផ្សាយនៅក្នុងវិស័យសុខាភិបាល បានគាំទ្រដល់ប្រសិទ្ធភាពនៃការអន្តរាគមតាមប្រព័ន្ធផ្សព្វផ្សាយដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្លាស់ប្តូរឥរិយាបថ និងការយល់ដឹងទាក់ទងនឹងសុខភាព ជាពិសេសនៅពេលច្របាច់បញ្ចូលគ្នានូវវិធីសាស្ត្រតាមសហគមន៍ និងគោលនយោបាយដែលផ្តល់កិច្ចគាំទ្រ។ ទោះបីជាយុទ្ធនាការនានា រមែងផ្តោតទៅលើផលវិបាកអវិជ្ជមាននៃអំពើហិង្សាក៏ដោយ ក៏យុទ្ធនាការទាំងនោះ អាចធ្វើការអំពាវនាវបែបវិជ្ជមានផងដែរ ក្នុងនោះរាប់បញ្ចូលពីសារៈសំខាន់នៃ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

ថ្មីៗនេះ អ្នកអភិវឌ្ឍន៍កម្មវិធីបានអនុវត្តសាកល្បងទៅលើវិធីសាស្ត្រថ្មីៗមួយចំនួន សម្រាប់ផ្តល់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន ដូចជាការផ្តល់ព័ត៌មានតាមអ៊ីនធឺណែត ឬការប្រើប្រាស់ "កម្មវិធី" ទូរស័ព្ទស្មាតហ្វូន។ វិធីសាស្ត្រផ្តល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនដែលមានភាពច្នៃប្រឌិតបែបនេះ មិនទាន់ត្រូវបានវាយតម្លៃនៅឡើយទេ ប៉ុន្តែវាហាក់បីដូចជាមានសក្តានុពលខ្ពស់ក្នុងការបង្កើនលទ្ធភាពទទួលបានកិច្ចគាំទ្រការចិញ្ចឹមកូនដោយបញ្ជាក់ឡើងវិញអំពីសារៈសំខាន់ និងរក្សាទំនាក់ទំនងជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ក្នុងអំឡុងពេល និងក្រោយពេលអន្តរាគមន៍។

ភាគច្រើននៃកម្មវិធីអប់រំអំពីការចិញ្ចឹមកូន ដែលបានវាយតម្លៃផ្តោតទៅលើតែឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារតូច ប៉ុន្តែកិច្ចគាំទ្រដល់ពួកគេសម្រាប់ក្មេងជំទង់វិញ មិនសូវមានការលើកឡើងនៅឡើយ។ ចំណុចនេះគួរឱ្យព្រួយបារម្ភព្រោះថា ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ គឺជាមនុស្សដ៏សំខាន់ក្នុងការទប់ស្កាត់ឥរិយាបថមិនល្អរបស់ក្មេងជំទង់។ លើសពីនេះទៅទៀត កម្មវិធីភាគច្រើនផ្តោតលើអ្នកថែទាំជាស្ត្រី ដែលជាហេតុនាំឱ្យមានការពង្រឹងបន្ថែមទៅលើតួនាទីយេនឌ័របែបប្រពៃណី។ បើទោះបីជាមានកិច្ចខិតខំមួយចំនួន ដើម្បីឱ្យមានការចូលរួមពីឪពុកក៏ដោយ ប៉ុន្តែភស្តុតាងដែលបញ្ជាក់អំពីប្រសិទ្ធភាពក្នុងការកាត់បន្ថយអំពើហិង្សានៅតិចតួចនៅឡើយ។

ការសិក្សាជាច្រើន បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការដោះស្រាយឫសគល់នៃវិបត្តិតានតឹងនៅក្នុងជីវិតរស់នៅរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំថា ជាទិដ្ឋភាពមួយដ៏សំខាន់នៃអន្តរាគមន៍គាំទ្រចំពោះការចិញ្ចឹមកូន។ ភាពក្រីក្រគឺជាកត្តាហានិភ័យមួយសម្រាប់អំពើហិង្សា ដោយសារតែវាពាក់ព័ន្ធទៅនឹងវិបត្តិតានតឹងក្នុងកម្រិតមួយដ៏ខ្ពស់។ គេត្រូវការឱ្យមានយន្តការ និងអន្តរាគមន៍គាំពារសង្គមបន្ថែមពីលើកិច្ចគាំទ្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដើម្បីជំនះទៅលើឧបសគ្គផ្នែករចនាសម្ព័ន្ធដែលរាំងស្ទះដល់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

### ប្រអប់ទី ៣. សមាសធាតុសំខាន់ៗនៃកម្មវិធី ចិញ្ចឹមកូនប្រកបដោយប្រសិទ្ធភាព

កម្មវិធីអប់រំអំពីការចិញ្ចឹមកូន គប្បី ៖

**មានទ្រឹស្តីកម្មវិធីមួយសមស្រប**

ទ្រឹស្តីសមស្របមួយដែលមានមូលដ្ឋានផ្អែកលើភស្តុតាង បញ្ជាក់អំពីអ្វីដែលមានដំណើរការប្រព្រឹត្តទៅបានទាក់ទងទៅនឹងការសន្និដ្ឋាន និងការរំពឹងទុកអំពីរបៀបដែលកម្មវិធីគប្បីត្រូវបានរៀបចំ និងផ្តល់ជូនដើម្បីឱ្យសម្រេចបានគោលបំណង។

**កំណត់ឱ្យបានច្បាស់លាស់អំពីក្រុមគោលដៅ**

កម្មវិធីប្រកបដោយប្រសិទ្ធភាព គប្បីមានការពិចារណាច្បាស់លាស់សម្រាប់កំណត់គោលដៅទៅលើក្រុមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាក់លាក់មួយដូចជា ស្ថានភាពសង្គមសេដ្ឋកិច្ចរបស់ពួកគេ។

**ត្រូវមានការពាក់ព័ន្ធ និងអាចទទួលយកបានចំពោះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ**

ការរៀបចំ និងផ្តល់ជូននូវកម្មវិធីមួយដែលសម្របទៅតាមសេចក្តីត្រូវការ និងសារវតារប្បធម៌របស់ក្រុមគោលដៅដែលត្រូវបានគេយល់ថា មានសារៈប្រយោជន៍ក្នុងការជួយកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ។

**ត្រូវមានរយៈពេលគ្រប់គ្រាន់**

រយៈពេលនៃអន្តរាគមន៍ អាស្រ័យទៅលើកម្រិតនៃហានិភ័យរបស់ក្រុមគោលដៅ។ អន្តរាគមន៍ដែលមានរយៈពេលកាន់តែវែង កាន់តែមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាធ្ងន់ធ្ងរ ចំពោះក្រុមដែលមានការប្រឈម។

**ត្រូវផ្តល់ជូនដោយបុគ្គលិកដែលមានការបណ្តុះបណ្តាល និងមានការត្រួតពិនិត្យត្រឹមត្រូវ**

ដើម្បីឱ្យក្លាយជាអ្នកមានជំនាញវិជ្ជាជីវៈ ឬប្រជាពលរដ្ឋសហគមន៍ដែលបានទទួលការបណ្តុះបណ្តាល គប្បីគ្រប ដណ្តប់ទៅលើមាតិកានៃកម្មវិធី និងជំនាញដែលគេត្រូវការដើម្បីបង្កលក្ខណៈឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ចូលរួមសកម្មបាននៅក្នុងដំណើរការនៃការផ្លាស់ប្តូរ ។

**ផ្តល់ការបញ្ជូន និងជំនួយក្នុងការទទួលបានសេវាដទៃទៀត**

វាមានសារៈសំខាន់ដែលកម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ត្រូវភ្ជាប់ទំនាក់ទំនង ឬបញ្ជូនឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជាមួយសេវា និងប្រភពជំនួយដទៃទៀតដូចជា អន្តរាគមន៍ពង្រឹងសេដ្ឋកិច្ច។

**បង្កើនកិច្ចគាំទ្រសង្គម**

កិច្ចគាំទ្រសង្គម មានផលប៉ះពាល់វិជ្ជមានទៅលើទិដ្ឋភាពនៃការចិញ្ចឹមកូនដ៏ទូលំទូលាយ រាប់បញ្ចូលទាំងការយល់ ឃើញចំពោះខ្លួនឯង ការសម្របខ្លួន និងសុខភាពផ្លូវចិត្ត។

**មានប្រព័ន្ធមួយដ៏ល្អសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃ**

នីតិវិធីពិនិត្យតាមដាន និងវាយតម្លៃ មានសារៈសំខាន់ដើម្បីធានាថា កម្មវិធីត្រូវបានអនុវត្តទៅតាមការគ្រោងទុក និងមានប្រសិទ្ធភាព ព្រមទាំងជាមូលដ្ឋានព័ត៌មានសម្រាប់ការរៀបចំកម្មវិធី ដើម្បីឱ្យមានភាពប្រសើរជាងមុន។

**លើកកម្ពស់ការឆ្លើយតប និងការចូលរួមរបស់ឪពុកនៅក្នុងការចិញ្ចឹមកូន**

ការចូលរួមក្នុងកម្រិតមួយដ៏ខ្ពស់របស់ឪពុក មានទំនាក់ទំនងទៅនឹងលទ្ធភាពវិជ្ជមានរបស់កុមារ និងជួយកាត់បន្ថយ កម្រិតនៃវិបត្តិតានតឹងក្នុងការចិញ្ចឹមកូនរបស់ម្តាយ និងអ្នកថែទាំដទៃទៀត។ សមាសធាតុមួយចំនួនបានបញ្ជាក់ថា មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់កម្មវិធីអប់រំអំពីការចិញ្ចឹមកូន ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារៈ

- ឱកាសសម្រាប់ឪពុក អនុវត្តជំនាញថ្មីៗ ក្នុងអំឡុងពេលវគ្គរៀនសូត្រ និងនៅផ្ទះ
- បង្រៀនអំពីគោលការណ៍នៃ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ជំនួសឱ្យការកំណត់ផ្តល់ជូននូវបច្ចេកទេស
- បង្រៀនអំពីយុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន រាប់បញ្ចូលការអនុវត្តវិន័យបែបវិជ្ជមានឱ្យបានសមស្របតាមអាយុ
- ពិចារណាអំពីការលំបាកនានានៅក្នុងទំនាក់ទំនងរវាងមនុស្សពេញវ័យក្នុងគ្រួសារ។



# ផ្នែកទី៣ ៖ យុទ្ធសាស្រ្ត

ដោយសារប្រេវ៉ាឡង់ខ្ពស់នៃការចិញ្ចឹមកូនបែបអវិជ្ជមាន ឬការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ និងប្រើអំពើហិង្សាលើកុមារ ជំរុញឱ្យមានកិច្ចគាំទ្រសម្រាប់***ការចិញ្ចឹមកូនបែបអវិជ្ជមាន*** ទូទាំងប្រទេស សម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប ដោយរាប់បញ្ចូលទាំងអ្នកដែលនឹងក្លាយជាឪពុកម្តាយក្នុងពេលឆាប់ៗ (ស្ត្រីមានផ្ទៃពោះ និងដៃគូ) និងអនាគតឪពុកម្តាយ( យុវវ័យ )។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ បានបង្ហាញនូវកម្រិតហានិភ័យផ្សេងៗគ្នា ក្នុង***ការចិញ្ចឹមកូនបែបអវិជ្ជមាន*** ឬការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។ យុទ្ធសាស្រ្តស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ត្រូវបានរៀបចំដើម្បីកិច្ចគាំទ្រដល់ការចិញ្ចឹមកូននៅកម្រិតផ្សេងៗគ្នាដែលកំពុងមានការកើនឡើង ( សូមមើលរូបភាពទី៥ )។

យុទ្ធសាស្រ្តស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** បានរៀបចំតាមពហុកម្រិតក្នុងកិច្ចគាំទ្រដល់ការចិញ្ចឹមកូន។ នៅពេលដែលមានហានិភ័យកាន់តែខ្ពស់ ការផ្តល់កិច្ចគាំទ្រសម្រាប់***ការចិញ្ចឹមកូនបែបវិជ្ជមាន*** មានកម្រិតកាន់តែខ្ពស់ផងដែរ ។

**កម្រិតទី១៖** “កិច្ចគាំទ្រជាសកលសម្រាប់ការចិញ្ចឹមកូន” គឺដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ក្នុងចំណោមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប។

**កម្រិតទី២៖** “កិច្ចគាំទ្រតាមក្រុមសម្រាប់ការចិញ្ចឹមកូន” គឺដើម្បីផ្លាស់ប្តូរឥរិយាបថចំពោះការចិញ្ចឹមកូន ក្នុងចំណោមក្រុមតូចៗនៃឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលប្រឈមទៅនឹងអំពើហិង្សា ឬការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។

**កម្រិតទី៣៖** “កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន” គឺដើម្បីឆ្លើយតបទៅនឹងអំពើហិង្សា និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។

យុទ្ធសាស្រ្តនេះ គប្បីមើលឃើញថា ជាវិធីមួយនៃការបែងចែកប្រភេទអន្តរាគមន៍សម្រាប់ការចិញ្ចឹមកូន ជាជាងការបែងចែកប្រភេទគ្រួសារ។ កិច្ចគាំទ្រដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អាចមានការវិវឌ្ឍឡើងចុះចំពោះការបន្តគាំទ្រនៅពេល

វេលាផ្សេងៗគ្នា។ កិច្ចគាំទ្រកម្រិតទី១ គប្បីបញ្ចូលយន្តការសម្រាប់ពិនិត្យតាមដាន និងបញ្ជូនគ្រួសារទៅកម្រិតទី២ និងកម្រិតទី៣។ កម្រិតទី២ និងកម្រិតទី៣ មានគោលបំណងផ្លាស់ប្តូរឥរិយាបថរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការចិញ្ចឹមកូន ដើម្បីឱ្យពួកគាត់អាចទទួលបានការគាំទ្រការអន្តរាគមនៅកម្រិតទី១ទាន់ពេលវេលាដោយមិនត្រូវការកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនតាមក្រុម ឬលក្ខណៈបុគ្គលដែលផ្តោតការយកចិត្តទុកដាក់ខ្លាំង និងចំណាយខ្ពស់ជាង។

***រូបភាពទី ៥. យុទ្ធសាស្ត្រពហុកម្រិតសម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមាន***




អន្តរាគមន៍សម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ជាច្រើនដែលនឹងត្រូវផ្តល់ជូនតាមកន្លែងផ្សេងៗគ្នា ដោយអ្នកពាក់ព័ន្ធផ្សេងៗគ្នា ជំរុញឱ្យមានប្រព័ន្ធសម្របសម្រួលមួយដែលត្រូវបានអភិវឌ្ឍឡើងយ៉ាងល្អ ជាពិសេស អាស្រ័យដោយយុទ្ធសាស្ត្រមានគោលបំណងធ្វើការបញ្ជ្រាបកិច្ចគាំទ្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ទៅក្នុងសេវាអន្តរាគមន៍ និងរចនាសម្ព័ន្ធដែលមានស្រាប់។ បើទោះបីជា ក្រសួងកិច្ចការនារី ជាអ្នកដឹកនាំយុទ្ធសាស្ត្រនៅកម្រិតទាំង៣នេះក៏ដោយ ប៉ុន្តែកិច្ចសហការអន្តរក្រសួង ស្ថាប័ន និងភាពជាដៃគូដ៏រឹងមាំជាមួយអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជោគជ័យនៃយុទ្ធសាស្ត្រនេះ។ យុទ្ធសាស្ត្រនេះ នឹងទទួលបានការគាំទ្រពីកញ្ចប់ឧបករណ៍ជាតិមួយស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដើម្បីជាមគ្គុទេសក៍សម្រាប់ផ្តល់ការណែនាំដល់ការងាររបស់អ្នកពាក់ព័ន្ធនៅកម្រិតផ្សេងៗគ្នា និងដើម្បីលើកកម្ពស់ឱ្យមានការផ្តល់សារប្រកបដោយសង្គតិភាពអំពី***ការចិញ្ចឹមកូនបែបវិជ្ជមាន***ទូទាំងបណ្តាញ និងកម្រិតអន្តរាគមន៍ផ្សេងៗគ្នា។

យុទ្ធសាស្ត្រនេះ នឹងអនុវត្តវិធីសាស្ត្រពេញមួយជីវិតជាមួយកុមារនៅកម្រិតទាំង៣ ដោយពិចារណាអំពីយេនឌ័ររបស់កុមារ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំជួបប្រទះហានិភ័យផ្សេងៗគ្នា នៅដំណាក់កាលខុសៗគ្នានៃជីវិតរបស់កុមារ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលកំពុងថែទាំក្មេងជំទង់អាចទាមទារឱ្យមានដំបូន្មាន ឬកិច្ចគាំទ្រដែលខុសគ្នាយ៉ាងខ្លាំងអំពីអ្នកដែលកំពុងថែទាំទារក ឬកុមារតូចដែលទើបចេះវារ ឬតោងឈរ។ កុមារប្រឈមទៅនឹងហានិភ័យ និងកត្តាការពារផ្សេងៗគ្នានៅដំណាក់កាលខុសៗគ្នានៃជីវិតរស់នៅរបស់ពួកគេ ហើយកិច្ចគាំទ្រដែលមានសម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កាត់បន្ថយជាអតិបរមាទៅលើហានិភ័យនោះ និងអភិវឌ្ឍឱ្យមានភាពរឹងមាំ។ គ្រួសារអាចត្រូវបានពិចារណាបែងចែកជាដំណាក់កាល ដោយគិតចាប់ពីការរៀបចំត្រៀមលក្ខណៈ និងការមានកូនតូចរហូតដល់ចុងបញ្ចប់នៃការថែទាំជីវិត។ រូបភាពទី៦ បង្ហាញអំពីក្រុមអាយុដែលត្រូវប្រើប្រាស់នៅក្នុងបរិបទនៃយុទ្ធសាស្ត្រនេះ។

រូបភាពទី ៦. កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនបែបវិជ្ជមាន ពេញមួយជីវិតជាមួយកុមារ

រយៈពេលមុន និងក្រោយពេលសម្រាលះ ពេលកើតរហូតដល់អាយុ ២ឆ្នាំ

រយៈពេលមត្តេយ្យសិក្សាៈ ៣ - ៥ ឆ្នាំ

រយៈពេលបឋមសិក្សាៈ ៦ - ១២ ឆ្នាំ

រយៈពេលមធ្យមសិក្សាៈ ១៣ - ១៨ ឆ្នាំ

ការរៀបចំ និងការផ្តល់កិច្ចគាំទ្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នៅគ្រប់កម្រិតទាំងអស់ គប្បីគិតគូរអំពីឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់ប្រភេទ ដែលមានបំណងចង់ទទួលបានកិច្ចគាំទ្រទាំងនោះដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះ ជីដូនជីតា ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលមានពិការភាព ក្រុមជនជាតិ និងសាសនាផ្សេងៗគ្នា។

ដូចមានបញ្ជាក់នៅក្នុងជំពូក៣ កម្មវិធីអប់រំស្តីពីការចិញ្ចឹមកូនក្នុងប្រទេសកម្ពុជា មានមូលដ្ឋានភស្តុតាងតិចតួច។ ក្រសួងកិច្ចការនារីនឹងពង្រឹងបន្ថែមទៅលើអន្តរាគមន៍នានាដែលប្រកបដោយសក្តានុពល ខណៈពេលកំពុងពង្រឹងមូលដ្ឋានភស្តុតាងនៃកម្មវិធីអប់រំអំពីការចិញ្ចឹមកូនប្រកបដោយសក្តានុពល។

## ៣.១. កម្រិតទី១៖ កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនជាសកល “កម្រិតស្រាល” សម្រាប់ការចិញ្ចឹមកូនបែបវិជ្ជមាន

| | | |
|---|---|---|
| **ក្រុមគោលដៅ** | ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទាំងអស់ រាប់បញ្ចូលអ្នកដែលនឹងក្លាយខ្លួនជាឪពុកម្តាយ (ស្ត្រីមានផ្ទៃពោះ និងដៃគូ) និងអនាគតឪពុកម្តាយ (យុវវ័យ) | |
| **យុទ្ធសាស្ត្រ** | យុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនងទូទាំងប្រទេសដើម្បីផ្សព្វផ្សាយពីសារៈសំខាន់នៃ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ដឹកនាំដោយ៖ ក្រសួងកិច្ចការនារី<br>គាំទ្រដោយ៖ ក្រសួងព័ត៌មាន |
| | កសាងសមត្ថភាពក្នុងចំណោមអ្នកដែលធ្វើការងារជាមួយកុមារ និងគ្រួសាររបស់ពួកគេ ដើម្បីឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទទួលនូវព័ត៌មាន និងដំបូន្មានអំពី **ការចិញ្ចឹមកូនបែបវិជ្ជមាន ប្រកបដោយសមធម៌** | ដឹកនាំដោយ៖ ក្រសួងកិច្ចការនារី<br>គាំទ្រដោយ៖ ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | |
|---|---|
| **គោលបំណង** | • លើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន***<br>• ផ្លាស់ប្តូរទម្លាប់ វប្បធម៌ និងសង្គម ដែលគាំទ្រដល់ការចិញ្ចឹមកូនដោយប្រើប្រាស់ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ និងអំពើហិង្សា<br>• លើកកម្ពស់ផ្នត់គំនិតវិជ្ជមានក្នុងគ្រួសារ ដោយមិនមានការរើសអើង និងមិនលម្អៀងក្នុងការបែងចែកការងារ ផ្តល់ឱកាស ក្តីស្រឡាញ់ និងលទ្ធភាពនានាដល់ កូនស្រី និងកូនប្រុស ជាពិសេសកូនដែលមានពិការភាព<br>• លើកកម្ពស់ឥរិយាបថស្វែងរកជំនួយ ឆន្ទៈ និងចំណាប់អារម្មណ៍ចំពោះកិច្ចគាំទ្រដល់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន***<br>• កំណត់រកឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលត្រូវការកិច្ចគាំទ្របន្ថែមសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។ |

## យុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនង

ទោះបីជាពុំមានភស្តុតាងបញ្ជាក់ថា យុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនងតែឯង ជាយុទ្ធសាស្ត្រអាចផ្លាស់ប្តូរឥរិយាបថចំពោះការចិញ្ចឹមកូនក៏ដោយ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ នឹងមានការលំបាកក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ពួកគេ ប្រសិនបើទម្លាប់ និងជំនឿក្នុងការចិញ្ចឹមកូននៅក្នុងសហគមន៍ទាំងមូលពុំមានការផ្លាស់ប្តូរ។ យុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនង គឺជាយុទ្ធសាស្ត្រដែលមានមូលដ្ឋានផ្អែកលើទំនាក់ទំនងដើម្បីការអភិវឌ្ឍ ឬគោលការណ៍ផ្លាស់ប្តូរការប្រព្រឹត្តដទៃទៀតដែលត្រូវបានគេទទួលស្គាល់ថា អាចលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងចំណេះដឹងអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងការលើកអំណះអំណាង ប្រឆាំងទម្លាប់ ឥរិយាបថ និងការប្រព្រឹត្តទាក់ទងទៅនឹងការចិញ្ចឹមកូន និងអំពើហិង្សា ព្រមទាំងអាចគាំទ្រដល់អន្តរាគមន៍ចំពោះការចិញ្ចឹមកូននៅកម្រិតទី២ និងកម្រិតទី៣ ដើម្បីសម្រេចឱ្យបាននូវការផ្លាស់ប្តូរជាវិជ្ជមានចំពោះឥរិយាបថរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការចិញ្ចឹមកូន។ យុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនង អាចត្រូវបានយកមកប្រើប្រាស់ដើម្បីលើកកម្ពស់ទម្លាប់នានា ដែលសង្កត់ធ្ងន់ថា កិច្ចការពារកុមារ គឺជាការទទួលខុសត្រូវរបស់មនុស្សគ្រប់រូប ហើយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំទាំងអស់អាចប្រើប្រាស់ជំនួយនៅពេលណាមួយក៏បាន។ ចំណុចដែលបានលើកឡើងទី១ នឹងសម្របសម្រួលឱ្យមានឥរិយាបថក្នុងការស្វែងរកជំនួយ និងបង្កើនការទទួលយករបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលស្វែងរកកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន។

## ការបណ្តុះបណ្តាលធនធានមនុស្ស មុនពេល និងក្នុងអំឡុងពេលបម្រើការងារ

យុទ្ធសាស្ត្រសកលទី២ ពាក់ព័ន្ធទៅនឹងធនធានដែលមានស្រាប់ ក្នុងការលើកកម្ពស់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ក្នុងចំណោមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានកូនក្នុងដំណាក់កាលអភិវឌ្ឍផ្សេងៗគ្នា។ ប្រទេសកម្ពុជាមានកម្រងសេវាមួយចំនួនសម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ អ្នកជំនាញវិជ្ជាជីវៈ អ្នកពាក់កណ្តាលជំនាញវិជ្ជាជីវៈ ឬប្រជាពលរដ្ឋធម្មតាដែលបម្រើ ការងារក្នុងសហគមន៍ទាំងអស់ ចូលរួមធ្វើការងារជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ និងគ្រួសារមានឱកាសលើកកម្ពស់ និងគាំទ្រដល់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន***តាមរយៈតួនាទីរបស់ពួកគេ។ ដូច្នេះពួកគេ គប្បីទទួលបានការបណ្តុះបណ្តាលមុនពេល និងក្នុងអំឡុងពេលបម្រើការងារ អំពីទិដ្ឋភាពសំខាន់ៗនៃ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។

អ្នកជំនាញវិជ្ជាជីវៈ អ្នកពាក់កណ្តាលជំនាញវិជ្ជាជីវៈ និងប្រជាពលរដ្ឋធម្មតាដែលបម្រើការងារក្នុងសហគមន៍ក្នុងប្រព័ន្ធរាជរដ្ឋាភិបាលដែលត្រូវបានកំណត់ថា ជាច្រកចូលបឋមដ៏សំខាន់ សម្រាប់ការផ្តល់ព័ត៌មាន និងដំបូន្មានអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ជូនដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ នៅកម្រិតទី១ រួមមាន៖

| | |
|---|---|
| **ក្រសួងអប់រំ យុវជន និងកីឡា** | ឪពុកម្ដាយបង្គោល<br>គ្រូបង្រៀននៅសាលាមត្តេយ្យ សាលាបឋមសិក្សា និង មធ្យមសិក្សា |
| **ក្រសួងសុខាភិបាល** | ឆ្មប និងគិលានុបដ្ឋាយិកា<br>ក្រុមទ្រទ្រង់សុខភាពភូមិ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | បុគ្គលិកសង្គមកិច្ចស្រុក |
| **ក្រសួងធម្មការ និងសាសនា** | អ្នកអប់រំផ្នែកសាសនា |
| **ក្រសួងមហាផ្ទៃ** | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ |
| **ក្រសួងកិច្ចការនារី** | មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌<br>មន្ត្រីមន្ទីរកិច្ចការនារី រាជធានី ខេត្ត និងការិយាល័យកិច្ចការនារី ក្រុង ស្រុក ខណ្ឌ<br>មន្ត្រីក្រសួងកិច្ចការនារីដែលធ្វើការងារជាមួយយុវជនលើផ្នែកសីលធម៌ និងជំនាញបំណិនជីវិត |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | មន្ត្រីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **ក្រសួងព័ត៌មាន** | មន្ត្រីមន្ទីរព័ត៌មាន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |

ក្រសួងកិច្ចការនារីនឹងធ្វើការងារជាមួយក្រសួងទាំងនេះ ដើម្បីអភិវឌ្ឍ និងអនុវត្តការបណ្តុះបណ្តាលអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** មុនពេល និងក្នុងអំឡុងពេលបម្រើការងារ (រូបភាពទី៧) ដោយប្រើប្រាស់កញ្ចប់ឧបករណ៍ស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** (សូមមើលចំណុច ៣.៤)។ មកទល់នឹងបច្ចុប្បន្ន ការបណ្តុះបណ្តាលទ្រង់ទ្រាយធំនៅក្នុងប្រព័ន្ធរដ្ឋាភិបាលបាននាំឱ្យមានលទ្ធផលចម្រុះ។ ដូច្នេះ ក្រសួងកិច្ចការនារីនឹងផ្តោតលើការបណ្តុះបណ្តាលមុនពេលចូលបម្រើការងារ៖ ដោយបញ្ចូល ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ទៅក្នុងកម្មវិធីសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលក្នុងអំឡុងពេលបម្រើការងារ នឹងចាប់ផ្តើមក្នុងទ្រង់ទ្រាយតូចនៅតាមតំបន់អាទិភាព ដោយមានការពិនិត្យតាមដាន និងឃ្លាំមើលដិតដល់ នូវវិធីសាស្រ្តតាមការគ្រោងទុក សម្រាប់ការបណ្តុះបណ្តាលក្នុងពេលកំពុងបម្រើការងារប្រកបដោយប្រសិទ្ធភាពក្នុងទ្រង់ទ្រាយធំជាងនេះ។

យុទ្ធសាស្រ្តប្រកបដោយសក្តានុពលដទៃទៀត សម្រាប់កិច្ចគាំទ្រ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ជាសកលរួមមាន បណ្តាញទូរស័ព្ទសម្រាប់ផ្តល់ជំនួយដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ការផ្តល់ព័ត៌មានអំពី***ការចិញ្ចឹមកូនបែបវិជ្ជមាន*** តាមប្រព័ន្ធអ៊ីនធឺណែត។ គេត្រូវការឱ្យមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីពិនិត្យមើលថា តើយុទ្ធសាស្រ្តបែបនេះស្របទៅនឹងបរិបទប្រទេសកម្ពុជាដែរឬទេ ដោយសំដៅចំពោះទាំងការទទួលបាន និងឆន្ទៈរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការប្រើប្រាស់កិច្ចគាំទ្របែបនេះ។

### រូបភាពទី ៧. រចនាសម្ព័ន្ធកម្រិតទី១




## ៣.២. កម្រិតទី២៖ កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនតាមក្រុមដោយមានកំណត់គោលដៅជាក់លាក់

<table>
<tr><td>ក្រុមគោលដៅ</td><td colspan="2">ក្រុមតូចៗដែលមានឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ប្រឈមទៅនឹងការប្រព្រឹត្តអំពើហិង្សា និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់</td></tr>
<tr><td rowspan="2">យុទ្ធសាស្ត្រ</td><td>ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ដើម្បីអនុវត្តអន្តរាគមន៍ សម្រាប់ការចិញ្ចឹមកូន ផ្តែកលើក្រុមដែលត្រូវបានរៀបចំរចនាសម្ព័ន្ធសមស្របតាមវប្បធម៌ដោយកំណត់គោលដៅ ក្រុមតូចៗដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ប្រឈមទៅនឹងអំពើហិង្សា</td><td rowspan="2">ដឹកនាំដោយ៖ ក្រសួងកិច្ចការនារី<br>គាំទ្រដោយ៖ អង្គការសង្គមស៊ីវិល</td></tr>
<tr><td>អនុវត្តសាកល្បងគំរូផ្តល់សេវាសាធារណៈថ្មី សម្រាប់កិច្ចគាំទ្រ ចំពោះការចិញ្ចឹមកូនដោយរាជរដ្ឋាភិបាលនៅកម្រិតសហគមន៍</td></tr>
<tr><td>គោលបំណង</td><td colspan="2">• លើកកម្ពស់ចំណេះដឹង ជំនាញក្នុង ការចិញ្ចឹមកូនបែបវិជ្ជមាន និងទំនុកចិត្តក្នុងការផ្លាស់ប្តូរការអនុវត្តចិញ្ចឹមកូនជាក់ស្តែង (ការផ្លាស់ប្តូរឥរិយាបថ) រួមទាំងផ្នត់គំនិតយេនឌ័រ<br>• ទប់ស្កាត់អំពើហិង្សា និងការរំលោភបំពានពីដំបូង ឬការកើតឡើងជាថ្មីម្តងទៀត<br>• ទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ និងការយកកុមារទៅដាក់ក្នុងមណ្ឌលដោយមិនចាំបាច់</td></tr>
</table>

ខណៈពេលដែលអន្តរាគមន៍កម្រិតទី១ ផ្តោតលើការលើកកម្ពស់ការយល់ដឹង និងចំណេះដឹង អន្តរាគមន៍កម្រិតទី២ មានគោលបំណងបង្កើនចំណេះដឹង ជំនាញ និងទំនុកចិត្តរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ចំពោះ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដើម្បីផ្លាស់ប្តូរឥរិយាបថរបស់ពួកគាត់ក្នុងការចិញ្ចឹមកូនជាក់ស្តែង។ គេទាមទារឱ្យមានការផ្លាស់ប្តូរចំពោះឥរិយាបថរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ក្នុងការចិញ្ចឹមកូនដើម្បីទប់ស្កាត់ (ពីដំបូង) នៃអំពើហិង្សាលើកុមារ និងរក្សាគ្រួសារឱ្យនៅជួបជុំគ្នា និងផ្ទត់គំនិត ឥរិយាបថអវិជ្ជមាននានា ដែលបែងចែករវាងកូនប្រុស និងកូនស្រី ដែលរាំងដល់សមភាពនៃការទទួលបានឱកាស និងលទ្ធភាពនៃការអភិវឌ្ឍ។

អន្តរាគមន៍តាមក្រុម មានប្រសិទ្ធភាពបំផុតក្នុងការបង្កើនចំណេះដឹង ជំនាញ និងទំនុកចិត្តសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន***។ អន្តរាគមន៍នេះ អាចបង្កើតបរិយាកាសមួយ ដែលអាចផ្តល់កិច្ចគាំទ្រសម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំឱ្យទទួលបាន និងពិភាក្សាអំពីព័ត៌មាន និងដំបូន្មានអំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងអនុវត្តជំនាញថ្មីៗទាក់ទងនឹងការចិញ្ចឹមកូន។ អន្តរាគមន៍បែបនេះ អនុញ្ញាតឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ធ្វើការចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមក ព្រមទាំងជួយពង្រឹងបណ្តាញគាំទ្រសង្គមរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងអំឡុងពេល និងក្រោយពេលអន្តរាគមន៍។ អន្តរាគមន៍តាមក្រុម អាចធ្វើឡើងដោយអ្នកជំនាញវិជ្ជាជីវៈ អ្នកពាក់កណ្តាលជំនាញវិជ្ជាជីវៈ ឬអ្នកបម្រើការងារធម្មតានៅកម្រិតថ្នាក់ឃុំដែលបានទទួលការបណ្តុះបណ្តាល។ ការទទួលបានអន្តរាគមន៍កម្រិតទី២ អាចផ្តល់ជូនដោយផ្ទាល់ ឬតាមរយៈការពិនិត្យតាមដាន និងការបញ្ជូនដោយអ្នកដែលធ្វើការងារនៅកម្រិតទី១។

លទ្ធភាពអន្តរាគមន៍តាមក្រុមមានកម្រិត ដោយសារតែត្រូវការឱ្យមានកិច្ចខិតខំខ្លាំងក្លា និងធនធានច្រើន ដើម្បីផ្តល់អន្តរាគមន៍បែបនេះ ដូច្នេះអន្តរាគមន៍ប្រភេទនេះ គប្បីកំណត់គោលដៅចំពោះក្រុមឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំណាដែលមានហានិភ័យ។ សម្រាប់គោលបំណងនៃយុទ្ធសាស្ត្រនេះ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវបានចាត់ទុកថា "មានហានិភ័យ" ប្រសិនបើពួកគេប្រព្រឹត្តអំពើហិង្សា និងបំបែកកុមារចេញពីគ្រួសារ។

អំពើហិង្សា និងការបំបែកកុមារចេញពីគ្រួសារ អាចកើតមាននៅក្នុងគ្រប់គ្រួសារទាំងអស់ ប៉ុន្តែចរិកលក្ខណៈជាក់លាក់មួយចំនួនដែលគេហៅថា កត្តាហានិភ័យ អាចធ្វើឱ្យការប្រឈមនេះមានការកើនឡើង។ ម្យ៉ាងវិញទៀត កត្តាការពារ គឺជារបាំងមួយដែលជួយឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលអាចមានហានិភ័យ មានលទ្ធភាពក្នុងការស្វែងរកធនធានកិច្ចគាំទ្រ ឬយុទ្ធសាស្ត្រសម្របខ្លួន ដែលអនុញ្ញាតឱ្យពួកគេចិញ្ចឹមកូនប្រកបដោយភាពវិជ្ជមាន បើទោះបីជាស្ថិតក្រោមវិបត្តិតានតឹងក៏ដោយ។ ការចិញ្ចឹមកូនបែបអវិជ្ជមាន និងការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ គឺជាកត្តាហានិភ័យមួយសម្រាប់អំពើហិង្សា ប៉ុន្តែអំពើហិង្សា ការចិញ្ចឹមកូនបែបអវិជ្ជមាន និងការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ មានកត្តាហានិភ័យជាក់លាក់ដូចគ្នាមួយចំនួន ទាំងនៅក្នុងផ្ទះ និងក្រៅផ្ទះ។

បើទោះបីជាមានភស្តុតាងសកលបញ្ជាក់អំពីកត្តាហានិភ័យនៃអំពើហិង្សា ការចិញ្ចឹមកូនបែបអវិជ្ជមាន និងការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរក៏ដោយ (សូមមើលរូបភាពទី៨) ប៉ុន្តែជោគជ័យនៃអន្តរាគមន៍កម្រិតទី២អាស្រ័យទៅលើការកំណត់អត្តសញ្ញាណហានិភ័យ និងកត្តាការពារដែលមានភាពជាក់លាក់ទៅនឹងបរិបទប្រទេសកម្ពុជា។ ការវិភាគកម្រិតមធ្យមទៅលើទិន្នន័យដែលទទួលបានពីការអង្កេតស្តីពី អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា អាចអនុញ្ញាតឱ្យគេអាចកំណត់អត្តសញ្ញាណហានិភ័យ និងកត្តាការពារបាន ប៉ុន្តែគេត្រូវការឱ្យមានការស្រាវជ្រាវ (បែបគុណភាព) បន្ថែមទៀត ដើម្បីយល់អំពីទម្លាប់សង្គមដែលបង្កឱ្យមានគ្រោះថ្នាក់។ ឧទាហរណ៍ កត្តាការពារផ្អែកលើភស្តុតាងសកលរួមមាន បច្ចេកទេសអនុវត្តវិន័យបែបវិជ្ជមានដែលមិនប៉ះពាល់ទៅលើរាងកាយ និងកិច្ចគាំទ្រសង្គម។

## រូបភាពទី ៨. កត្តាហានិភ័យសម្រាប់អំពើហិង្សា ការចិញ្ចឹមកូនបែបអវិជ្ជមាន និងការអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ នៅកម្រិតផ្សេងៗគ្នា

### សង្គម វប្បធម៌ រចនាសម្ព័ន្ធ

ជម្លោះ អំពើហិង្សាដែលកើតឡើងជាទម្លាប់ វិសមភាពយេនឌ័រ វិសមភាពផ្នែកសេដ្ឋកិច្ច កង្វះកិច្ចគាំទ្រសម្រាប់គ្រួសារ ការផ្លាស់ប្តូរដ៏ឆាប់រហ័សនៃសេដ្ឋកិច្ចសង្គម កង្វះគោលនយោបាយ អស្ថេរភាព និងការមិនឱ្យតម្លៃកុមារ។

### សហគមន៍ សាលារៀន

ការទទួលយកការដាក់ទណ្ឌកម្មធ្ងន់ធ្ងរលើរាងកាយ ការទ្រាំទៅនឹងអំពើហិង្សា លំនៅដ្ឋានមិនល្អ ភាពគ្មានការងារធ្វើ កង្វះកិច្ចគាំទ្រសង្គម និងការបំពុលបរិស្ថាន។

### ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ

ភាពក្រីក្រ ការអប់រំ សុខភាពផ្លូវចិត្ត ការប្រើប្រាស់គ្រឿងញៀន ការចិញ្ចឹមកូន ការទទួលរងអំពើរំលោភបំពានតាំងពីកុមារភាព វិបត្តិសង្គម ការបែកបាក់គ្រួសារ តួនាទីយេនឌ័រ និងការរើសអើង។

### កូន

មិនតាមបំណងប្រាថ្នា មានសេចក្តីត្រូវការខ្ពស់ (ផ្លូវកាយ និង ផ្លូវចិត្ត) មានបងប្អូនបង្កើតច្រើន សុខភាព ភេទ រូបរាង ឬកពារ និង អាកប្បកិរិយា។

នៅកម្រិតទី២ ក្រសួងកិច្ចការនារីនឹងផ្តល់ការឃ្លាំមើល និងការសម្របសម្រួលជាចម្បងចំពោះការអនុវត្តកិច្ចគាំទ្រសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដោយអង្គការសង្គមស៊ីវិល។ អាស្រ័យដោយមាតិកា ការផ្តល់ជូន និងធនធាននៃអន្តរាគមន៍តាមក្រុម ពឹងផ្អែកទៅលើក្រុមគោលដៅជាក់លាក់ ក្រសួងកិច្ចការនារីមិនទាមទារឱ្យមានវិធីសាស្ត្រណាតែមួយ ដែលតម្រូវឱ្យក្រុមគោលដៅគ្រប់ប្រភេទនៅកម្រិតទី២ឡើយ។ ទោះជាដូច្នេះក្តី ក្រសួងកិច្ចការនារីនឹងតែងតាំងមន្ត្រី ឬដៃគូបច្ចេកទេសរបស់អង្គការសង្គមស៊ីវិល ឱ្យធ្វើការប៉ាន់ប្រមាណទៅលើគុណភាពនៃអន្តរាគមន៍ចំពោះការចិញ្ចឹមកូនដែលត្រូវបានផ្តល់ជូននៅកម្រិតទី២ ដោយផ្អែកលើបទដ្ឋានអប្បបរមាដែលត្រូវបានកំណត់ក្នុងលក្ខណៈជាផ្នែកមួយនៃកញ្ចប់ឧបករណ៍ស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងរយៈពេលវែងអន្តរាគមន៍កម្រិតទី២ គប្បីត្រូវបានផ្តល់ជូនដោយរាជរដ្ឋាភិបាល។ ដូច្នេះ ក្រសួងកិច្ចការនារីនឹងសហការជាមួយអង្គការសង្គមស៊ីវិលដើម្បីអភិវឌ្ឍ និងអនុវត្តន៍សាកល្បងនូវគំរូថ្មីៗសម្រាប់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន ក្នុងលក្ខណៈជាផ្នែកមួយនៃការផ្តល់សេវាសាធារណៈ។

## ៣.៣. កម្រិតទី៣៖ កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន

| | | |
|---|---|---|
| **ក្រុមគោលដៅ** | • ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានកូនទទួលរងអំពើហិង្សាធ្ងន់ធ្ងរ<br>• ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានកូនកំពុងធ្វើសមាហរណកម្មពីការថែទាំតាមមណ្ឌល | |
| **យុទ្ធសាស្ត្រ** | កិច្ចគាំទ្រ ឯកទេសសម្រាប់ការចិញ្ចឹមកូនដែលអាចជាកិច្ចគាំទ្រដែលផ្តល់ជូនក្នុងលក្ខណៈមួយទល់មួយ ឬតាមក្រុមក្នុងលក្ខណៈជាផ្នែកមួយនៃយន្តការឆ្លើយតប ចំពោះកិច្ចការពារកុមារដែលផ្តល់ជូនដោយបុគ្គលិកសង្គមកិច្ចស្រុករបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការសង្គមស៊ីវិល។ | ដឹកនាំដោយ៖ ក្រសួងកិច្ចការនារី និងក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br><br>គាំទ្រដោយ៖ អង្គការសង្គមស៊ីវិល |
| **គោលបំណង** | • គាំទ្រដល់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលកុមារទទួលរងអំពើហិង្សា និងការរំលោភបំពាន ដើម្បីសម្របខ្លួនទៅនឹងផលវិបាកនានា<br>• លើកកម្ពស់សមាហរណកម្មកុមារពីមណ្ឌលទៅក្នុងគ្រួសារដោយភាពវិជ្ជមាន | |

នៅកម្រិតទី២ អន្តរាគមន៍ចំពោះការចិញ្ចឹមកូនតាមក្រុម អាចមានភាពគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានភាពខុសប្លែកគ្នាចំពោះឥរិយាបថរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ចំពោះគ្រួសារដែលមានហានិភ័យ។ ប៉ុន្តែកាលណាគ្រួសារជួបប្រទះការលំបាកកាន់តែធ្ងន់ធ្ងរ គេនឹងត្រូវការឱ្យមានអន្តរាគមន៍ឯកទេសសម្រាប់ការចិញ្ចឹមកូនបន្ថែមផងដែរ។ ដូច្នេះកិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន គឺជាវិធានការមួយដ៏សំខាន់សម្រាប់ការទប់ស្កាត់កម្រិតខ្ពស់ចំពោះអំពើហិង្សា។ ទោះបីជាកិច្ចគាំទ្រចំពោះការចិញ្ចឹមកូនកម្រិតទី៣ ផ្តោតលើឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក៏ដោយ ប៉ុន្តែសុវត្ថិភាព និងសុខុមាលភាពរបស់កូនគប្បីជាការព្រួយបារម្ភចម្បងបំផុត។

នៅក្នុងបរិបទប្រទេសកម្ពុជា កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន នឹងផ្តោតជាបឋមចំពោះគ្រួសារដែលមានកូនកំពុងត្រូវបានធ្វើសមាហរណកម្មពីមណ្ឌល។ ជាញឹកញាប់ ចំណងទំនាក់ទំនងរវាងកូនដែលត្រូវបានយកទៅដាក់ក្នុងមណ្ឌល និងឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ព្រមទាំងសាច់ញាតិរបស់ពួកគេមានភាពចុះខ្សោយ ឬធ្លាក់ក្នុងស្ថានភាពធ្ងន់ធ្ងរ។ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវការឱ្យមានការគាំទ្រ ដើម្បីដោះស្រាយបញ្ហាកង្វល់ដែលបានកើតមានកន្លងមកក្នុងការថែទាំ ដើម្បីសម្របសម្រួលដំណើរការបង្រួបបង្រួមគ្រួសារឡើងវិញ។ ក្នុងករណីដែលការបង្រួបបង្រួមគ្រួសារ មិនត្រូវបាន

ចាត់ទុកថាជាឧត្តមប្រយោជន៍របស់កុមារ ប៉ុន្តែការសម្របសម្រួលទំនាក់ទំនងកំពុងត្រូវបានធ្វើឡើង ដូច្នេះឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំនៅតែត្រូវការឱ្យមានកិច្ចគាំទ្រដើម្បីចូលរួមនៅក្នុងការប្រាស្រ័យទាក់ទង និងកសាងឱ្យមាននូវទំនាក់ទំនងវិជ្ជមានមួយជាមួយកូនរបស់ពួកគេដែលស្ថិតនៅក្នុងមណ្ឌល។

ទម្រង់មួយទៀតនៃកិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន នឹងផ្តោតលើគ្រួសារដែលមានកូនទទួលរងអំពើហិង្សា និងការរំលោភបំពាន។ អំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់ទាំងអស់ មានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើសុខភាព ការលូតលាស់ និងអភិវឌ្ឍផ្នែកស្មារតីរបស់កុមារ ហើយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំដែលផ្តល់ការគាំទ្រ និងមិនបង្កការឈឺចាប់ដល់កុមារ គឺជាអ្នកសម្របសម្រួលមួយដ៏សំខាន់ក្នុងការធ្វើឱ្យកុមារមានភាពធូរស្រាលឡើងវិញ។ ដូច្នេះ អន្តរាគមន៍សុខភាពផ្លូវចិត្តដែលមានប្រសិទ្ធភាពខ្ពស់បំផុត នឹងត្រូវធ្វើការងារជាមួយកុមារ ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំកុមារ។

កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន មិនចំពោះថាជាកិច្ចគាំទ្រលក្ខណៈបុគ្គល ឬតាមក្រុមនោះទេ គប្បីត្រូវបានអនុវត្តក្នុងលក្ខណៈជាផ្នែកមួយនៃប្រព័ន្ធការពារកុមារថ្នាក់ជាតិនៃប្រទេសកម្ពុជា និងគប្បីមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយស្តីពីការថែទាំជំនួស។ ដូច្នេះក្រសួងកិច្ចការនារីមានគោលបំណងអនុវត្តយុទ្ធសាស្ត្រកម្រិតទី៣នេះរួមគ្នាជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

បុគ្គលិកសង្គមកិច្ចនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានមូលដ្ឋានប្រសើរបំផុតក្នុងការផ្តល់កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន ប៉ុន្តែសមត្ថភាព និងចំនួនបុគ្គលិកមានកម្រិត ព្រមទាំងកង្វះវត្តមាននៅកម្រិតសហគមន៍ បានធ្វើឱ្យរាំងស្ទះដល់លទ្ធភាពរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការអនុវត្តការទទួលខុសត្រូវនេះឱ្យបានពេញលេញក្នុងឆ្នាំ ២០១៧-២០២១។ ការអភិវឌ្ឍបច្ចុប្បន្នទៅលើអ្នកស្ម័គ្រចិត្តសង្គមកិច្ច មានសក្តានុពល ចំពោះធនធានមនុស្សបន្ថែមសម្រាប់ការងារសង្គមកិច្ច ព្រមទាំងជាឱកាសមួយ ដើម្បីធ្វើសមាហរណកម្មបទដ្ឋានអប្បបរមាសម្រាប់កិច្ចគាំទ្រឯកទេសចំពោះការចិញ្ចឹមកូននៅក្នុងអាណត្តិការងាររបស់ខ្លួន។ ទោះជាដូច្នេះក្តី បុគ្គលិកសង្គមកិច្ចដែលប្រកបដោយជំនាញ និងគុណវុឌ្ឍិការងារបន្ថែមពីលើអ្នកពាក់កណ្តាលវិជ្ជាជីវៈ អ្នកស្ម័គ្រចិត្តសហគមន៍ ឬអ្នកបម្រើការងារធម្មតាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាឱ្យបាននូវសុវត្ថិភាពរបស់កុមារ ខណៈពេលកំពុងផ្តល់កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូន។ ជាលទ្ធផលនៅក្នុងឆ្នាំ២០១៧-២០២១ អង្គការសង្គមស៊ីវិលនឹងបន្តដើរតួនាទីដ៏សំខាន់ក្នុងការផ្តល់កិច្ចគាំទ្រឯកទេសសម្រាប់ការចិញ្ចឹមកូននៅក្នុងបរិបទនៃកិច្ចការពារកុមារ និងការថែទាំជំនួស។

## ៣.៤. ការធានាគុណភាពក្នុងកិច្ចគាំទ្រចំពោះការចិញ្ចឹមកូនបែបវិជ្ជមាន

ជោគជ័យនៃកម្មវិធីអប់រំស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ឬកម្រងអន្តរាគមន៍ ក្នុងការលើកកម្ពស់***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងការទប់ស្កាត់អំពើហិង្សា ព្រមទាំងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ ត្រូវបានកំណត់តាមរយៈគុណភាពនៃកិច្ចគាំទ្រចំពោះការចិញ្ចឹមកូន។ ជំពូកនេះ រៀបរាប់លម្អិតអំពីយន្តការដែលត្រូវបង្កើត ដើម្បីធានាឱ្យបាននូវគុណភាពក្នុងកិច្ចគាំទ្រចំពោះ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ៖

- កញ្ចប់ឧបករណ៍ស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន***
- ការអភិវឌ្ឍធនធានមនុស្ស និងការផ្តល់នីតិសម្បទា
- ការស្រាវជ្រាវ ការពិនិត្យតាមដាន និងការវាយតម្លៃ

### កញ្ចប់ឧបករណ៍ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន

ក្រសួងកិច្ចការនារីនឹងបង្កើតនូវកញ្ចប់ឧបករណ៍មួយស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ដើម្បីភ្ជាប់ទៅនឹងយុទ្ធសាស្ត្រស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** សំដៅផ្តល់ឱ្យក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗគ្នា អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតនៅមូលដ្ឋាន ដែលជាវិធីសាស្ត្រសម្រាប់អភិវឌ្ឍ អនុវត្ត និងពិនិត្យតាមដានទៅលើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពចំពោះ

***ការចិញ្ចឹមកូនបែបវិជ្ជមាន***។ កញ្ចប់ឧបករណ៍នេះ នឹងអនុញ្ញាតឱ្យមានការប្រាស្រ័យទាក់ទងនូវសារសំខាន់ តែមួយនៅក្នុងចំណោមបណ្ដាញដោយឡែកពីគ្នា ព្រមទាំងកំណត់ បទដ្ឋានអប្បបរមាសម្រាប់កិច្ចគាំទ្រចំពោះ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នៅកម្រិតផ្សេងៗគ្នានៃយុទ្ធសាស្ត្រស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។ កញ្ចប់ឧបករណ៍នេះ គប្បីត្រូវបានប្រើប្រាស់ជាគោលការណ៍ណែនាំ និងកម្រង បទដ្ឋានអប្បបរមា ដែលត្រូវផ្ដល់ជូនដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ក្រុមឪពុកម្ដាយ ព្រមទាំងទម្រង់នៃការផ្ដល់ជូននីមួយៗដែលមានលក្ខណៈពិសេសខុសៗគ្នា។

| មាតិកានៃកញ្ចប់ឧបករណ៍ស្ដីពី ការចិញ្ចឹមកូនបែបវិជ្ជមាន | |
|---|---|
| **កម្រិតទី១** | សារ និងសម្ភារៈសំខាន់ៗសម្រាប់ព័ត៌មានជាមូលដ្ឋាននៃយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនង។<br>កម្មវិធីសិក្សាអំពី***ការចិញ្ចឹមកូនបែបវិជ្ជមាន*** សម្រាប់ការបណ្ដុះបណ្ដាលមុនពេល និងក្នុងអំឡុងពេលបម្រើការងារជូនដល់អ្នកជំនាញវិជ្ជាជីវៈ អ្នកពាក់កណ្ដាលជំនាញវិជ្ជាជីវៈ និងបុគ្គលិកធម្មតាដែលបម្រើការងារក្នុងសហគមន៍ទូទាំងក្រសួង និងវិស័យផ្សេងៗគ្នា ដែលនៅក្នុងនោះ រួមមាន ៖<br>• សៀវភៅផ្នត់ដែលមានព័ត៌មានមូលដ្ឋាន និងសារសំខាន់ សម្រាប់វិស័យស្នូលនីមួយៗ<br>• សម្ភារៈផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនង សម្រាប់កិច្ចគាំទ្រដល់ការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយនៅកម្រិតសហគមន៍។<br>កម្មវិធីសិក្សានឹងមានការរៀបចំមួយដែលមានលក្ខណៈបត់បែនទន់ភ្លន់ សម្រាប់ប្រើប្រាស់ទាំងស្រុង ឬមួយផ្នែក ដោយយោងទៅតាមក្រុមឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ អាយុរបស់កុមារ និងបរិបទ។ |
| **គ្រប់កម្រិតទាំងអស់** | កម្រងបទដ្ឋានអប្បបរមា សម្រាប់កិច្ចគាំទ្រចំពោះ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ទាក់ទងទៅនឹង ៖<br>• មាតិកា (វិស័យស្នូលចំនួន៦)<br>• ដំណើរការនៃការផ្ដល់សេវា (សមាសធាតុសំខាន់ៗ)<br>• ក្រុមដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពិសេសដូចជា ឪពុក ឪពុកម្ដាយដែលមានវ័យក្មេង ឪពុកម្ដាយដែលមានពិការភាព និងជីដូនជីតា<br>បទដ្ឋានអប្បបរមាសម្រាប់កិច្ចគាំទ្រចំពោះ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នឹងមានសង្គតិភាព ឬពង្រឹងបន្ថែមទៅលើបទដ្ឋានអប្បបរមាជាធរមានដទៃទៀត ជាពិសេសបទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ កិច្ចគាំទ្រ និងកិច្ចការពារកុមារកំព្រា និងកុមាររងាយរងគ្រោះ។ |

វិស័យស្នូលទាំង ៦ នៃ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** (សូមមើលតារាងទី១) ត្រូវបានជ្រើសរើសជាមូលដ្ឋាននៃកញ្ចប់ឧបករណ៍។ វិស័យស្នូលទាំងនេះដោះស្រាយហានិភ័យដែលមានលក្ខណៈសំខាន់បំផុត និងកត្តាការពារដែលគេដឹងថា អាចទប់ស្កាត់អំពើហិង្សាលើកុមារបាន និងអាចព្យាករណ៍អំពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។ បញ្ហាយេនឌ័រ ក្រុមកុមារ ពិសេសកុមារីងាយរងគ្រោះ នឹងត្រូវបានយកមកបញ្ចូលទៅក្នុងវិស័យស្នូលទាំង៦ កញ្ចប់ឧបករណ៍នេះ នឹងបញ្ចូលអភិក្រមវដ្ដជីវិតមួយដែលផ្ដល់នូវព័ត៌មានអំពីការចិញ្ចឹមកូនដែលមានភាពជាក់លាក់សម្រាប់កុមារា និងកុមារី ទៅតាមក្រុមអាយុដូចជា អាយុក្រោម ៣ឆ្នាំ អាយុ ៣-៥ឆ្នាំ អាយុ ៦-១២ឆ្នាំ និងអាយុ ១៣-១៨ឆ្នាំ (សូមមើលតារាងទី២)។

មាតិកាដែលត្រូវបានស្នើឡើងសម្រាប់វិស័យស្នូល គប្បីត្រូវបានចាត់ទុកថាជាជំហានដំបូងក្នុងការអភិវឌ្ឍកញ្ចប់ឧបករណ៍ និងអាចមានការប្រែប្រួលក្នុងអំឡុងពេលដំណើរការនៃការអភិវឌ្ឍ ការអនុវត្តសាកល្បង និងការអនុវត្តជាក់ស្ដែង។

**តារាងទី ១. វិស័យស្នូលនៃការចិញ្ចឹមកូនបែបវិជ្ជមាន**

| វិស័យស្នូល | | បរិយាយសង្ខេប |
|---|---|---|
| **១. កាតព្វកិច្ចរបស់ឪពុកម្ដាយ និងភារកិច្ចរបស់កូន** | • តួនាទី និងការទទួលខុសត្រូវ<br>• ភាពជាឪពុក<br>• គុណតម្លៃ និងសីលធម៌<br>• គោលដៅរយៈពេលខ្លី និងរយៈពេលវែង<br>• របៀបនៃការចិញ្ចឹមកូន | ដើម្បីជួយដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំឱ្យយល់អំពីតួនាទីរបស់ពួកគេ សារៈសំខាន់នៃការថែទាំតាមគ្រួសារ និងការទទួលខុសត្រូវក្នុងនាមជាឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។ ដោយការផ្ដោតយកចិត្តទុកដាក់ខ្លាំង ទៅលើការទទួលខុសត្រូវផ្នែកសីលធម៌ ដូច្នេះ តួនាទី និងការទទួលខុសត្រូវរបស់កូនៗ ឬកុមារក៏គប្បីត្រូវលើកយកមកពិភាក្សាផងដែរ។ របៀបនៃការចិញ្ចឹមកូនរបស់មនុស្សម្នាក់ រងឥទ្ធិពលពីសីលធម៌ គុណតម្លៃ និងគោលដៅនៃការចិញ្ចឹមកូន។ ដោយឡែកការចិញ្ចឹមកូនបង្កឱ្យមានផលប៉ះពាល់ ទៅលើសីលធម៌ គុណតម្លៃ និងអនាគតរបស់កូន។ ការយល់ឃើញ និងការឆ្លុះបញ្ចាំងបែបនេះ គាំទ្រដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំឱ្យធ្វើការជ្រើសរើសឱ្យបានច្បាស់លាស់ នៅក្នុងការចិញ្ចឹមកូនរបស់ពួកគេ។ |
| **២. ការអភិវឌ្ឍរបស់កុមារ** | • វិស័យនៃការអភិវឌ្ឍរបស់កុមារ<br>• វឌ្ឍនភាពសំខាន់ៗ និងការចិញ្ចឹមកូនបែបវិជ្ជមាននៅដំណាក់កាលលូតលាស់ និងអភិវឌ្ឍផ្សេងៗគ្នា<br>• ភាពខុសគ្នានៃយេនឌ័រ | ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ យល់ពីវិស័យផ្សេងៗគ្នា នៃការលូតលាស់ និងអភិវឌ្ឍរបស់កុមារ និងដឹងថា ការចិញ្ចឹមកូន មានវិសាលភាពលើសពីការផ្ដល់អាហារូបត្ថម្ភ ការថែទាំ ការព្យាបាល និងការអប់រំ ដោយរាប់បញ្ចូលការផ្ដល់ក្ដីស្រឡាញ់ ការជំរុញលើកទឹកចិត្ត និងអនុវត្តវិន័យបែបវិជ្ជមាន។ ចំណេះដឹងមូលដ្ឋានអំពី ដំណាក់កាលផ្សេងៗគ្នានៃការលូតលាស់ និងអភិវឌ្ឍកុមារនឹងបង្កលក្ខណៈឱ្យឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំមានឥទ្ធិពលវិជ្ជមានទៅលើការអភិវឌ្ឍរបស់កុមារ ឬកូនៗរបស់ពួកគេ និងរួមទាំងធានាបាននូវការរំពឹងទុកសមស្របចំពោះ ឥរិយាបថរបស់កូនៗ ឬកុមារផងដែរ។ |
| **៣. សុខុមាលភាពរបស់ឪពុកម្ដាយ** | • សុខុមាលភាពរបស់ឪពុកម្ដាយមានភាពស្មើគ្នាទៅនឹងសុខុមាលភាពរបស់កូនៗ<br>• ការគ្រប់គ្រងវិបត្តិតប់ប្រមល់ និងកំហឹង | សុខុមាលភាពរបស់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ គឺជាគន្លឹះសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងការទប់ស្កាត់អំពើហិង្សា។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានបញ្ហាសុខភាពផ្លូវចិត្ត ឬរងវិបត្តិតប់ប្រមល់ក្នុងកម្រិតខ្ពស់ ទំនងនឹងអនុវត្តន៍ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ដើម្បីកុំឱ្យមានសង្គតិភាពនៅក្នុងការឆ្លើយតបរបស់ពួកគេចំពោះឥរិយាបថរបស់កូន និងមិនទំនងថានឹងអាចសម្របខ្លួន ឬស្វែងរកប្រព័ន្ធគាំទ្រឡើយ។ ដូច្នេះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីទទួលបានការគាំទ្រ ដើម្បីគ្រប់គ្រងទៅលើវិបត្តិតប់ប្រមល់ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃឱ្យបានកាន់តែប្រសើរ ក្នុងនេះរួមមាន របៀបនៃ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងរបៀបគ្រប់គ្រងកំហឹងក្នុងលក្ខណៈវិជ្ជមាន។ |

| | | |
|---|---|---|
| **៤. ការប្រៀនប្រដៅកូនបែបវិជ្ជមាន** | • ការដាក់ទណ្ឌកម្មធៀបនឹងការអនុវត្តវិន័យ<br>• ការផ្ដល់ភាពកក់ក្ដៅ និងដែនកំណត់<br>• ការសួរដេញដោល<br>• ការដោះស្រាយបញ្ហា | ជាញឹកញាប់បំផុត អំពើហិង្សាតែងប្រព្រឹត្តដោយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងបរិបទនៃការដាក់ទណ្ឌកម្ម។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំត្រូវយល់អំពី ភាពខុសគ្នារវាងការដាក់ទណ្ឌកម្ម និងអនុវត្តវិន័យ ផលប៉ះពាល់ និងគោលការណ៍មូលដ្ឋាននៃអនុវត្តវិន័យបែបវិជ្ជមាន។ ឯកសារព័ត៌មានអំពីការពិត ដែលមានលក្ខណៈជាក់លាក់ទៅតាមអាយុ គួរអាចផ្ដល់ដំណោះស្រាយចំពោះការសួរដេញដោលទូទៅរបស់កុមារា កុមារី និងបច្ចេកទេសដោះស្រាយបញ្ហានានា។ |
| **៥. ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ** | • ទំនាក់ទំនងរវាងកូន ជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ<br>• ទំនាក់ទំនងគ្រួសារ (ទំនាក់ទំនងរវាងកូនជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលមានកូនក្នុងវ័យជំទង់ បញ្ហាផ្លូវភេទ និងការរួមភេទ) | ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំយល់អំពីសារៈសំខាន់នៃការស្ដាប់កូន និងរបៀបផ្ដល់ការពន្យល់ផ្ទាល់មាត់ និងការបង្ហាប់បញ្ហាដើម្បីបង្កើតឱ្យមាននូវចរន្ត សម្រាប់ទំនាក់ទំនង ប្រកបដោយភាពវិជ្ជមាន។ សកម្មភាពនេះរួមមាន ទំនាក់ទំនង និងការផ្ដល់ព័ត៌មាន អំពីបញ្ហាផ្លូវភេទ និងការរួមភេទ ខណៈពេលដែលពួកគេមានវ័យជំទង់ឡើង។ ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព រវាងឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ព្រមទាំងសមាជិកគ្រួសារ មានសារៈសំខាន់ដូចគ្នាសម្រាប់ការចិញ្ចឹមកូនប្រកបដោយសង្គតិភាព ទំនាក់ទំនងគ្រួសារប្រកបដោយភាពវិជ្ជមាន និងការដោះស្រាយបញ្ហា។ |
| **៦. ការការពារកុមារ** | • ការយល់ដឹងអំពី អំពើហិង្សា<br>• ការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សា<br>• ស្វ័យការពារ ឬការសម្របខ្លួនរបស់កុមារ<br>• ការទប់ស្កាត់ចំពោះការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ | សេវាការពារកុមារក្នុងប្រទេសកម្ពុជា នៅតែបន្ត ដោយមិនទាន់មានការអភិវឌ្ឍពេញលេញ។ ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំគប្បីទទួលបានកិច្ចគាំទ្រដើម្បីការពារកូនរបស់ពួកគេពីអំពើហិង្សា ដែលប្រព្រឹត្តដោយអ្នកដទៃទៀតទាំងនៅក្នុងផ្ទះ និងក្រៅផ្ទះ។ គេត្រូវខិតខំធ្វើការងារដើម្បីពង្រឹងចំណេះដឹង ជំនាញ និងទំនុកចិត្តរបស់ពួកគេដើម្បីទប់ស្កាត់ ការពារ និងឆ្លើយតបឱ្យបានគ្រប់គ្រាន់ ចំពោះករណីរំលោភបំពានកុមារនៅពេលដែលមានករណីបែបនេះកើតឡើង។ |

**តារាងទី ២. មេរៀន ឬឯកសារព័ត៌មានអំពីការពិតដែលមានលក្ខណៈជាក់លាក់ទៅតាមក្រុមអាយុដែលត្រូវអភិវឌ្ឍ**

| មេរៀន | មេរៀន ឬឯកសារព័ត៌មាន ដែលមានលក្ខណៈជាក់លាក់ទៅតាមក្រុមអាយុ | | | |
|---|---|---|---|---|
| ១. កាតព្វកិច្ចរបស់ឪពុកម្ដាយ និងភារកិច្ចរបស់កុមារ | | | | |
| ២. ការអភិវឌ្ឍរបស់កុមារ | ក្រោម ៣ឆ្នាំ | ៣-៥ ឆ្នាំ | ៦-១២ ឆ្នាំ | ១៣-១៨ ឆ្នាំ |
| ៣. សុខុមាលភាពរបស់ឪពុកម្ដាយ | | | | |
| ៤. ការប្រៀនប្រដៅកូនបែបវិជ្ជមាន | ក្រោម ៣ឆ្នាំ | ៣-៥ ឆ្នាំ | ៦-១២ ឆ្នាំ | ១៣-១៨ ឆ្នាំ |
| ៥. ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ | ក្រោម ៣ឆ្នាំ | ៣-៥ ឆ្នាំ | ៦-១២ ឆ្នាំ | ១៣-១៨ ឆ្នាំ |
| ៦. ការការពារកុមារ | ក្រោម ៣ឆ្នាំ | ៣-៥ ឆ្នាំ | ៦-១២ ឆ្នាំ | ១៣-១៨ ឆ្នាំ |

## ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស នៅតាមបណ្ដាទីភ្នាក់ងារ និងវិស័យនានា មានសារៈសំខាន់ដើម្បីសម្រេចឱ្យបានទាំងស្រុងនូវគោលបំណងនៃយុទ្ធសាស្ត្រស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន***។ អ្នកដែលធ្វើការងារជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំទាមទារឱ្យមានចំណេះដឹង និងជំនាញជាក់លាក់ ដើម្បីលើកកម្ពស់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ប្រកបដោយប្រសិទ្ធភាព។ ធនធានមនុស្សសម្រាប់អនុវត្តន៍ការចិញ្ចឹមកូន គឺជាក្រុមពហុវិស័យចម្រុះមួយ ដែលរួមមានអ្នកធ្វើការងារជាមួយអ្នកជំនាញវិជ្ជាជីវៈផ្សេងៗគ្នាជាច្រើនដែលមានកម្រិតនៃការទទួលខុសត្រូវ និងគុណវុឌ្ឍិការងារក្នុងកម្រិតផ្សេងៗគ្នាដោយរាប់ចាប់ពីអ្នកស្ម័គ្រចិត្តសហគមន៍រហូតដល់អ្នកជំនាញវិជ្ជាជីវៈ កម្រិតបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា។ បញ្ហានេះមានលក្ខណៈប្រទាក់ក្រឡាជាអន្តរវិស័យទាំងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងមានប្រតិបត្តិការនៅកម្រិតផ្សេងៗគ្នានៃយុទ្ធសាស្ត្រនេះ។ អ្នកអនុវត្តការងារអប់រំអំពីការចិញ្ចឹមកូន អាចមានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការផ្ដល់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនក្នុងលក្ខណៈជាទិដ្ឋភាពមួយនៃតួនាទីដ៏ទូលំទូលាយរបស់ពួកគេ។

ការអភិវឌ្ឍ និងការកសាងសមត្ថភាពធនធានមនុស្ស គប្បីបង្កលក្ខណៈឱ្យអ្នកជំនាញវិជ្ជាជីវៈអាចធ្វើការជាមួយគ្នាដោយជ្រើសរើស និងប្រើប្រាស់ដំណើរការរួមមួយក្នុងការផ្ដល់អន្តរាគមន៍សម្រាប់ការចិញ្ចឹមកូននៅកម្រិតផ្សេងៗគ្នា។ អាទិភាពសម្រាប់កម្រិតផ្សេងៗគ្នា រួមមាន ៖

- **នៅកម្រិតទី១ ៖** ការបណ្ដុះបណ្ដាលមុនពេល និងក្នុងអំឡុងពេលបម្រើការងារសម្រាប់ អ្នកជំនាញវិជ្ជាជីវៈ អ្នកពាក់កណ្ដាលជំនាញវិជ្ជាជីវៈ ឬអ្នកបម្រើការងារធម្មតាក្នុងសហគមន៍ ដែលតាមរយៈតួនាទីរបស់ពួកគេបានចូលរួមធ្វើការងារជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំនៅកម្រិតសហគមន៍។ ពួកគេត្រូវការឱ្យមានការបណ្ដុះបណ្ដាលផ្អែកលើកញ្ចប់ឧបករណ៍ស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ព្រមទាំងមានសង្គតិភាព និងធ្វើសមាហរណកម្មទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សទូលំទូលាយរបស់ក្រសួង។
- **នៅកម្រិតទី២ និងកម្រិតទី៣ ៖** ទាមទារឱ្យមានជំនាញការងារកាន់តែឯកទេសជាងនេះទៀត សម្រាប់អ្នកដែលធ្វើការងារជាមួយឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំដែលប្រឈមទៅនឹងអំពើហិង្សា ឬការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ ឬចំពោះឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំដែលមានសេចក្ដីត្រូវការពិសេស។ ក្រសួងកិច្ចការនារីនឹងសហការជាមួយដៃគូបច្ចេកទេសចំពោះយុទ្ធសាស្ត្រស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នេះ ក្នុងនោះរួមមាន៖ អង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា អង្គការសេវាសង្គមកិច្ចកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងការផ្ដល់ការបណ្ដុះបណ្ដាលនៅកម្រិតទី២ និងកម្រិតទី៣ ហើយស្របពេលជាមួយគ្នានោះ ក៏នឹងកសាងសមត្ថភាពរបស់ខ្លួនដើម្បីផ្ដល់ការបណ្ដុះបណ្ដាលនាពេលអនាគតផងដែរ។

ក្រសួងកិច្ចការនារី នឹងសហការជាមួយដៃគូបច្ចេកទេស ដើម្បីពិនិត្យមើលទៅលើលទ្ធភាពអភិវឌ្ឍប្រព័ន្ធថ្នាក់ជាតិមួយសម្រាប់ផ្ដល់ការបណ្ដុះបណ្ដាល និងផ្ដល់នីតិសម្បទាចំពោះទីភ្នាក់ងារដែលផ្ដល់កិច្ចគាំទ្រ ដោយមានកំណត់គោលដៅ និងកិច្ចគាំទ្រឯកទេសសម្រាប់ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ។ ការផ្ដល់នីតិសម្បទាគឺជាដំណើរការធានាគុណភាព តាមរយៈការផ្ដល់នីតិសម្បទាជូនដល់អ្នកផ្ដល់សេវាគាំទ្រសម្រាប់ការចិញ្ចឹមកូនដែលមានលក្ខខណ្ឌស្របតាមបទដ្ឋានអប្បបរមា សម្រាប់ការផ្ដល់កិច្ចគាំទ្រដែលមានកំណត់គោលដៅ ឬកិច្ចគាំទ្រឯកទេស។

នៅក្នុងបរិបទនៃធនធានដ៏មានកម្រិត ក្រសួងកិច្ចការនារី គប្បីធានាថាអ្នកដែលបានទទួលការបណ្ដុះបណ្ដាលស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** (ឬការអន្តរាគមន៍) បន្តផ្ដល់កិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូនជូនដល់ឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ។ ដូច្នេះគេផ្ដល់អនុសាសន៍ឱ្យកំណត់កម្រងលក្ខណៈវិនិច្ឆ័យមួយសម្រាប់អ្នកអនុវត្តការងារ ដើម្បីឱ្យទទួលបានការបណ្ដុះបណ្ដាលស្ដីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នៅគ្រប់កម្រិតទាំងអស់។

## ការស្រាវជ្រាវ ការពិនិត្យតាមដាន និងការវាយតម្លៃ

យុទ្ធសាស្ត្រស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ពុំមែនចប់ត្រឹមនេះទេ ប៉ុន្តែយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើង ដើម្បីសម្រេចបាននូវលទ្ធផលជាក់លាក់មួយចំនួនសម្រាប់ឪពុកម្ដាយ អាណាព្យាបាល និងអ្នកថែទាំ និងជាពិសេសគឺកុមារ។ ការពិនិត្យតាមដាន និងការវាយតម្លៃ (M&E) មានសារៈសំខាន់ខ្លាំងណាស់ដើម្បីវាស់ស្ទង់ទៅលើវិភាគទាននៃយុទ្ធសាស្ត្រនេះ ចំពោះលទ្ធផលនានាដែលសម្រេចបាន។ ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃសាមញ្ញមួយនឹងត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យទៅលើអន្តរាគមន៍ ធៀបនឹងលទ្ធផលរំពឹងទុក ព្រមទាំងរាយការណ៍អំពីកម្រិតប្រសិទ្ធភាពរបស់វាធៀបនឹងយុទ្ធសាស្ត្រ។

ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ ៖

- ត្រួតពិនិត្យទៅលើភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពនៃយុទ្ធសាស្ត្រ
- មានកម្រងសូចនាករមួយចំនួន
- សម្រាប់អន្តរាគមន៍កម្រិតទី១ ត្រូវបន្សីសូចនាករទៅនឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់របស់ក្រសួងផ្សេងៗគ្នា (ឧ. សូចនាកររបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអប់រំអំពីការចិញ្ចឹមកូនទាក់ទងនឹងការគាំពារ និងអភិវឌ្ឍកុមារតូច "ចំនួនឪពុកម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ដែលចូលរួមនៅក្នុងកម្មវិធីនេះ")។
- សម្រាប់អន្តរាគមន៍កម្រិតទី២ និងកម្រិតទី៣ កំណត់សូចនាករសម្រាប់ការត្រួតពិនិត្យទូទាំងវិស័យ និងតួអង្គផ្សេងៗគ្នា។
- មានយន្តការផ្ដល់មតិយោបល់ត្រឡប់ ដើម្បីធានាថា ព័ត៌មានដែលទទួលបានតាមរយៈការពិនិត្យតាមដាន និងការវាយតម្លៃ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ផ្ដល់ព័ត៌មាន និងកែលម្អការរៀបចំ និងអនុវត្តកម្មវិធី។

បន្ថែមពីលើឧបករណ៍មូលដ្ឋានសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃនេះ គេត្រូវការឱ្យមានការស្រាវជ្រាវដើម្បីជាមូលដ្ឋានព័ត៌មានសម្រាប់ការបង្កើតកម្មវិធី និងដើម្បីកំណត់រកអន្តរាគមន៍សម្រាប់ការចិញ្ចឹមកូនដែលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់អំពើហិង្សា និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ កម្មវិធីអប់រំអំពីការចិញ្ចឹមកូនភាគច្រើនក្នុងប្រទេសកម្ពុជាមិនទាន់ត្រូវបានវាយតម្លៃនៅឡើយផង ចុះទម្រាំតែតម្រូវឱ្យធ្វើការវាយតម្លៃឱ្យបានស៊ីជម្រៅទៅទៀតនោះ ដូច្នេះគេត្រូវកំណត់ឱ្យបាននូវប្រសិទ្ធភាពនៃកម្មវិធី ទាំងនោះមុនពេលពិចារណាពង្រីកកម្មវិធី។ សម្រាប់ឆ្នាំ ២០១៧-២០២១ ក្រសួងកិច្ចការនារី នឹងត្រូវធ្វើការជាមួយភស្តុតាងដែលអាចរកបាននៅពេលបច្ចុប្បន្ននេះ ហើយទន្ទឹមនេះក៏នឹងធ្វើការវិនិយោគបន្ថែមលើការស្រាវជ្រាវដើម្បីរកភស្តុតាងជាមូលដ្ឋាននៃកម្មវិធី ***ចិញ្ចឹមកូនបែបវិជ្ជមាន*** នៅកម្ពុជា។ ថ្មីៗនេះ អង្គការសុខភាពពិភពលោក បានផលិតគោលការណ៍ណែនាំដើម្បីជួយរៀបចំផែនការវាយតម្លៃទៅលើលទ្ធផល សម្រាប់កម្មវិធីអប់រំអំពីការចិញ្ចឹមកូន (សូមមើលចំណុចទី២៥ ក្រោមឯកសារយោង)។

# ផ្នែកទី៤ ៖ ផែនការសកម្មភាព

## ៤.១. ពេលវេលា

| ចំណាត់ការ ឬវឌ្ឍនភាពសំខាន់ៗ | | |
|---|---|---|
| **ដំណាក់កាលទី១ ៖<br>ខែតុលា - ធ្នូ ឆ្នាំ២០១៥** | ❖ ការផ្សព្វផ្សាយអំពីការរៀបចំយុទ្ធសាស្រ្តស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ក្រសួងកិច្ចការនារី |
| | ❖ ការអភិវឌ្ឍយុទ្ធសាស្រ្តស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ឆ្នាំ២០១៧-២០២១ | ក្រសួងកិច្ចការនារី |
| | ❖ ប្រកាស ស្តីពីការបង្កើត និងការប្រព្រឹត្តទៅ នៃក្រុមការងារបច្ចេកទេសស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ក្រសួងកិច្ចការនារី |
| | ❖ ការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** និងដៃគូអភិវឌ្ឍន៍ | ក្រសួងកិច្ចការនារី ដោយមានកិច្ចគាំទ្រពីដៃគូបច្ចេកទេស |
| **ដំណាក់កាលទី២ ៖<br>ខែមករា - ខែធ្នូ ឆ្នាំ២០១៦** | ❖ ការបង្កើត ៖<br>• កញ្ចប់ឧបករណ៍បណ្តុះបណ្តាលស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន***<br>• ឧបករណ៍មូលដ្ឋានសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ<br>• ក្រុមការងារបច្ចេកទេសស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ក្រសួងកិច្ចការនារី ដោយមានកិច្ចគាំទ្រពីដៃគូបច្ចេកទេស |
| **ដំណាក់កាលទី៣ ៖<br>ខែមករា- ខែធ្នូ ឆ្នាំ២០១៧** | ❖ ការបង្កើតធនធានមនុស្សកម្រិតទី១ ៖<br>• គ្រូបង្គោលកម្រិតទី១ (ការបណ្តុះបណ្តាលបុគ្គលិកសំខាន់ៗដល់ស្ថាប័នអនុវត្ត និងក្រសួងពាក់ព័ន្ធដទៃទៀត)<br>• ការអនុវត្តកម្រិតទី១ នៅតាមតំបន់ភូមិសាស្រ្តដែលបានជ្រើសរើស<br>• ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនូវយុទ្ធសាស្រ្តស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ |
| | ❖ អភិវឌ្ឍន៍កញ្ចប់ឧបករណ៍បណ្តុះបណ្តាលកម្រិតទី៣ | |
| **ដំណាក់កាលទី៤ ៖<br>ខែមករា ឆ្នាំ២០១៨ - ខែធ្នូ ឆ្នាំ២០១៩** | ❖ ការបង្កើតនូវធនធានមនុស្ស និងអនុវត្តកញ្ចប់ឧបករណ៍បណ្តុះបណ្តាលស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នៅតាមតំបន់ភូមិសាស្រ្តដែលត្រូវបានជ្រើសរើស<br>• ពង្រីកការអនុវត្តកម្រិតទី១ ដោយក្រសួងកិច្ចការនារី និងក្រសួងពាក់ព័ន្ធ<br>• បង្កើតធនធានមនុស្សកម្រិតទី២<br>• អភិវឌ្ឍន៍កញ្ចប់ឧបករណ៍ផ្សព្វផ្សាយកម្រិតទី៣<br>• បង្កើតធនធានមនុស្សកម្រិតទី៣<br>• អនុវត្តឧបករណ៍បណ្តុះបណ្តាលស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នៅមូលដ្ឋាន | ក្រសួងកិច្ចការនារី<br>ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>និងដៃគូអភិវឌ្ឍន៍ |
| | ❖ យុទ្ធសាស្រ្តប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងទំនាក់ទំនង | |
| | ❖ បង្កើតផែនការសកម្មភាពស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | |
| | ❖ ការវាយតម្លៃលទ្ធផលចំពោះកម្មវិធីអប់រំស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ប្រកបដោយសក្តានុពលក្នុងប្រទេសកម្ពុជា | ដៃគូស្រាវជ្រាវ |
| **ដំណាក់កាលទី៥ ៖<br>ខែមករា ឆ្នាំ២០២០ - ខែធ្នូ ឆ្នាំ២០២១** | ❖ អនុវត្តសកម្មភាពដែលមាននៅក្នុងផែនការសកម្មភាពស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ក្រសួងកិច្ចការនារី និងស្ថាប័នពាក់ព័ន្ធ |
| | ❖ វាយតម្លៃលទ្ធផលចំពោះការអនុវត្តកម្មវិធីស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ដៃគូស្រាវជ្រាវ |
| | ❖ ពង្រីកតំបន់គោលដៅបន្ថែម | ក្រសួងកិច្ចការនារី |
| **ដំណាក់កាលទី៦ ៖<br>ក្រោយឆ្នាំ២០២១** | ❖ ពង្រីក និងដាក់ឱ្យអនុវត្តទូទាំងប្រទេសនូវយុទ្ធសាស្រ្ត និងកញ្ចប់ឧបករណ៍ស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** | ក្រសួងកិច្ចការនារី និងស្ថាប័នពាក់ព័ន្ធ |

## ៤.២. ការពិចារណាចុងក្រោយក្នុងការបោះជំហានទៅមុខ

**១. លើកកម្ពស់ភាពជាដៃគូ និងកិច្ចសហការអន្តរក្រសួង និងអន្តរទីភ្នាក់ងារដើម្បីធានាឱ្យបាននូវវិធីសាស្រ្ត *ការចិញ្ចឹមកូនបែបវិជ្ជមាន* មួយដែលមានសង្គតិភាព និងគ្រប់ជ្រុងជ្រោយ**

យុទ្ធសាស្រ្តស្តីពី ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** ពុំមែនមានវត្តមានដាច់ដោយឡែកតែឯង ហើយក៏មិនមែនជាការទទួលខុសត្រូវរបស់ក្រសួងកិច្ចការនារីតែឯងនោះដែរ។ ស្ថាប័នអនុវត្ត ក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល សុទ្ធសឹងតែមានការទទួលខុសត្រូវ និងរួមចំណែកក្នុងការលើកកម្ពស់***ការចិញ្ចឹមកូនបែបវិជ្ជមាន***។ ការពង្រីកកិច្ចគាំទ្រចំពោះ ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** នៅក្នុងប្រទេសកម្ពុជា នឹងទាមទារឱ្យមានកិច្ចសហការក្នុងចំណោម និងរវាងរាជរដ្ឋាភិបាល ជាមួយអង្គការសង្គមស៊ីវិលដែលផ្តល់អន្តរាគមន៍ចំពោះការចិញ្ចឹមកូន និងគ្រឹះស្ថានអប់រំ ព្រមទាំងអ្នកស្រាវជ្រាវដែលធ្វើការងារនៅក្នុងវិស័យនានាដូចជាការទប់ស្កាត់អំពើហិង្សា និងការផ្តល់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន។

**២. រៀបចំឱ្យមាននូវករណីច្បាស់លាស់មួយសម្រាប់ *ការចិញ្ចឹមកូនបែបវិជ្ជមាន***

អ្នកដទៃទៀតទំនងនឹងចង់ចូលរួមធ្វើការងារសំដៅឆ្ពោះទៅរក ***ការចិញ្ចឹមកូនបែបវិជ្ជមាន*** សម្រាប់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំគ្រប់រូប ប្រសិនបើយើងអាចធ្វើការប្រាស្រ័យទាក់ទងឱ្យពួកគេដឹងថាហេតុអ្វីបានជាវាមានសារៈសំខាន់? តើវាមានលក្ខខណ្ឌស្របគ្នាទៅនឹងការទប់ស្កាត់អំពើហិង្សា និងអាទិភាពជាតិដទៃទៀតយ៉ាងដូចម្តេច?

**៣. ធានាថាបទប្បញ្ញត្តិជាធរមាន ហាមឃាត់ចំពោះគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារ ដោយរាប់បញ្ចូលនូវការអនុវត្តការដាក់ទណ្ឌកម្មលើរាងកាយ និងទណ្ឌកម្មនានា ដែលធ្វើឱ្យកុមារមានភាពអាម៉ាស់**

ក្របខ័ណ្ឌច្បាប់អាចរួមចំណែកចំពោះអំពើហិង្សាលើកុមារ ឬកិច្ចគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើកុមារ។ ទោះបីជាយុទ្ធសាស្រ្តនេះ ពុំមានគោលបំណងធ្វើវិសោធនកម្មដោយផ្ទាល់ទៅលើបទប្បញ្ញត្តិជាធរមាន ក៏ដោយ ប៉ុន្តែជោគជ័យ ឬបរាជ័យរបស់វារងឥទ្ធិពលពីចន្លោះប្រហោងដែលមានស្រាប់នៅក្នុងច្បាប់។ គេមិនអាចមើលស្រាលទៅលើសារៈសំខាន់នៃច្បាប់ក្នុងលក្ខណៈជាឧបករណ៍មួយ សម្រាប់លើកកម្ពស់ការយល់ដឹងជាសាធារណៈ គៀងគរកិច្ចគាំទ្រសាធារណៈធានាឱ្យបាននូវគណនេយ្យភាព និងការបញ្ចប់និទណ្ឌភាពឡើយ។ ច្បាប់ដ៏រឹងមាំដែលការពារកុមារពីអំពើហិង្សា ត្រូវបញ្ជូនសារមួយឱ្យបានច្បាស់លាស់ទៅកាន់សង្គមអំពីឥរិយាបថដែលអាចទទួលយកបានចំពោះកុមារ និងធ្វើនីត្យានុកូលកម្មទៅលើចំណាត់ការនានាដែលចាំបាច់ ដើម្បីធានាឱ្យបាននូវការការពារកុមារគ្រប់ពេលវេលាទាំងអស់។

**៤. ពិនិត្យមើលលទ្ធភាពចំពោះបច្ចេកវិទ្យាតាមប្រព័ន្ធអ៊ីនធឺណែត និងតាមទូរស័ព្ទសម្រាប់ផ្តល់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន**

បច្ចេកវិទ្យា ទូរស័ព្ទចល័ត និងការគ្របដណ្តប់អ៊ីនធឺណែត កំពុងមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជា ដូច្នេះវាបានផ្តល់ឱកាសមួយសម្រាប់ការផ្តល់កិច្ចគាំទ្រចំពោះការចិញ្ចឹមកូនដែលមានថ្លៃចំណាយទាប និងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់អប់រំអំពីការចិញ្ចឹមកូន[៦]។

**៥. លើកកម្ពស់ការចូលរួមរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ ក្នុងការបង្កើតឱ្យមានកិច្ចគាំទ្រសម្រាប់ការចិញ្ចឹមកូន**

ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំមានសិទ្ធិចូលរួមនៅក្នុងការរៀបចំ និងការបង្កើតយុទ្ធសាស្រ្តក្នុងការគាំទ្រការចិញ្ចឹមកូន ហើយការចូលរួមរបស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំក្នុងការរៀបចំអន្តរាគមន៍សម្រាប់ការចិញ្ចឹមកូនបែបនេះនឹងធានាបាននូវភាពពាក់ព័ន្ធរបស់ពួកគេចំពោះក្រុមគោលដៅ។

---

៦. សំដៅចំពោះបុគ្គលគ្រប់រូបដែលធ្វើការងារជាមួយឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ។ អ្នកដែលធ្វើការងារនៅក្នុងជំនាញវិជ្ជាជីវៈជាច្រើនផ្សេងៗគ្នា ដែលមានកម្រិតនៃការទទួលខុសត្រូវ និង គុណវុឌ្ឍិការងារខុសៗគ្នា រាប់ចាប់ពីអ្នកស្ម័គ្រចិត្តសហគមន៍ រហូតដល់អ្នកជំនាញវិជ្ជាជីវៈដែលបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា។

# ឧបសម្ព័ន្ធ១ ៖ អក្សរកាត់

| | | |
|---|---|---|
| CCWC | Commune Committee for Women and Children | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ |
| CSO | Civil Society Organization | អង្គការសង្គមស៊ីវិល |
| CVACS | Cambodia Violence Against Children Survey | ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារ នៅប្រទេសកម្ពុជា |
| ECCD | Early Childhood Care and Development | ការគាំពារ និងអភិវឌ្ឍកុមារតូច |
| ICS-SP | Improving Cambodia's Society through Skillful Parenting | អង្គការបុត្តាភិបាលដើម្បីវឌ្ឍនសង្គមកម្ពុជា |
| M & E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MoCR | Ministry of Cult and Religion | ក្រសួងធម្មការ និងសាសនា |
| MoEYS | Ministry of Education Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoIn | Ministry of Information | ក្រសួងព័ត៌មាន |
| MoLVT | Ministry of Labor and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| PTSD | Post-Traumatic Stress Disorder | ជំងឺបាក់ស្បាត |
| RUPP | Royal University of Phnom Penh | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SC | Save the Children | អង្គការសង្រ្គោះកុមារ |
| SSC | Social Service of Cambodia | អង្គការសេវាសង្គមកិច្ចកម្ពុជា |
| UNCRC | United Nations Convention on the Rights of the Child | អនុសញ្ញាអង្គការសហប្រជាជាតិសិទ្ធិកុមារ |
| UNICEF | United Nations Children's Fund | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# ឧបសម្ព័ន្ធ២ ៖ សន្ទានុក្រម

| | |
|---|---|
| **កុមារ** | បុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ។ |
| **អំពើហិង្សាផ្លូវកាយ** | អំពើហិង្សាដែលប្រព្រឹត្តទៅលើរាងកាយដូចជា ការទះកំផ្លៀង ច្រាន ដាល់ ទាត់ធាក់ វាយនឹងរំពត់ ឬវាយនឹងវត្ថុអ្វីមួយ ធ្វើឱ្យស្លាក់ ធ្វើឱ្យថប់ដង្ហើម ប៉ុនប៉ងធ្វើឱ្យលង់ទឹក ធ្វើឱ្យឆេះ ធ្វើឱ្យរលាកដោយចេតនា ឬគំរាមដោយប្រើប្រាស់អាវុធដូចជា កាំបិត ឬអាវុធដទៃទៀត។ អាចមានហេតុការណ៍បែបនេះកើតឡើងតែម្តង ឬម្តងហើយម្តងទៀត។ |
| **អំពើហិង្សាផ្លូវចិត្ត** | អំពើហិង្សាផ្លូវចិត្តត្រូវបានកំណត់និយមន័យថា ជាទម្រង់មួយនៃការប្រព្រឹត្តតាមរយៈពាក្យសម្តីដែលបានកើតឡើងជាបន្តបន្ទាប់ ឬហេតុការណ៍ដាច់ដោយឡែកមួយដែលពុំមានភាពសមស្រប និងគាំទ្រដល់ការលូតលាស់ និងអភិវឌ្ឍ និងមានលទ្ធភាពខ្ពស់ក្នុងការបំផ្លិចបំផ្លាញសុខភាពផ្លូវចិត្តរបស់កុមារ ឬការលូតលាស់ និងអភិវឌ្ឍ ផ្លូវកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ និងសង្គមរបស់កុមារ។ |
| **ការកេងប្រវ័ញ្ច** | ការកេងប្រវ័ញ្ចផ្នែកអាជីវកម្ម ឬការកេងប្រវ័ញ្ចដទៃទៀតទៅលើកុមារ សំដៅចំពោះការប្រើប្រាស់កុមារនៅក្នុងការងារ ឬសកម្មភាពដទៃទៀតសម្រាប់ប្រយោជន៍របស់អ្នកដទៃ ក្នុងនោះរួមមាន ពលកម្មកុមារ និងពេស្យាចារកុមារ ព្រមទាំងសកម្មភាពដទៃទៀត។ សកម្មភាពទាំងនេះ បំផ្លិចបំផ្លាញចំពោះសុខភាពផ្លូវកាយ ឬផ្លូវចិត្ត ការអប់រំ ឬការលូតលាស់ និងអភិវឌ្ឍផ្នែកស្មារតី សីលធម៌ សង្គម និងអារម្មណ៍របស់កុមារ។ ការកេងប្រវ័ញ្ចកុមារ ក៏រាប់បញ្ចូលផងដែរចំពោះការជ្រើសរើស និងប្រើប្រាស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ អំពើជួញដូរកុមារ និងការលក់កុមារ។ ការកេងប្រវ័ញ្ចអាចពាក់ព័ន្ធទៅនឹងការដាក់សម្ពាធឱ្យកុមារម្នាក់ធ្វើការងារសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនរបស់គ្រូបង្រៀន ឬបុគ្គលិកដទៃទៀតនៅក្នុងសាលារៀន។ វាក៏អាចពាក់ព័ន្ធផងដែរទៅនឹងការប្រមូលប្រាក់ពីកុមារម្នាក់ ដើម្បីឱ្យកុមារបានចូលរៀន ឬក្នុងលក្ខណៈជាការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុស។ |
| **កិច្ចគាំទ្រចំពោះគ្រួសារ** | កម្រងសេវា ឬសកម្មភាពមួយចំនួនដែលផ្តោតលើការកែលម្អ ដំណើរការប្រព្រឹត្តទៅរបស់គ្រួសារ និងការទុកដាក់ការចិញ្ចឹមកូន និងសកម្មភាពផ្សេងទៀតរបស់គ្រួសារនៅក្នុងប្រព័ន្ធមួយដែលមានទំនាក់ទំនង និងធនធានសម្រាប់ផ្តល់កិច្ចគាំទ្រ។ |
| **ការមិនអើពើ** | ការបន្តឱ្យមានភាពខកខានក្នុងការផ្តល់ជូនទៅតាមសេចក្តីត្រូវការមូលដ្ឋានផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ ការការពារកុមារពីគ្រោះថ្នាក់ ឬការទទួលបានសេវាវេជ្ជសាស្ត្រ សេវាចុះបញ្ជីកំណើត ឬសេវាផ្សេងទៀត នៅពេលដែលអ្នកទទួលខុសត្រូវចំពោះការថែទាំកុមារមានមធ្យោបាយ ចំណេះដឹង និងលទ្ធភាពក្នុងការទទួលបានសេវាទាំងនោះ។ ការមិនអើពើ ឬមិនយកចិត្តទុកដាក់អាចកើតឡើងក្នុងអំឡុងពេលមានផ្ទៃពោះ ដោយសារតែម្តាយប្រើប្រាស់គ្រឿងញៀន។ |
| **ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ** | អ្នកថែទាំចម្បងរបស់កុមារ (មិនកំណត់ចំពោះតែសាច់ញាតិបង្កើត) ដូចជា ឪពុកម្តាយ ជីដូនជីតា ឬអ្នកថែទាំដទៃទៀត។ |

| | |
|---|---|
| **ការអប់រំឪពុកម្តាយ** | ព័ត៌មាន និងការអប់រំអំពីកុមារ ការលូតលាស់ និងអភិវឌ្ឍកុមារ និងទិដ្ឋភាពដទៃទៀតនៃការចិញ្ចឹមកូន។ |
| **ការចិញ្ចឹមកូន** | ដំណើរការនៃការលើកកម្ពស់ និងគាំទ្រដល់ការលូតលាស់ និងអភិវឌ្ឍរបស់កុមារ។ |
| **អន្តរាគមន៍ចំពោះការចិញ្ចឹមកូន** | កម្រងកម្មវិធី និងអន្តរាគមន៍ជាច្រើនដ៏ទូលំទូលាយ ដើម្បីគាំទ្រដល់ទិដ្ឋភាពមួយ ឬច្រើន នៃការចិញ្ចឹមកូន។ |
| **កិច្ចគាំទ្រចំពោះការចិញ្ចឹមកូន** | កម្រងសេវា ឬសកម្មភាព ដែលផ្តោតលើការកែលម្អរបៀបដែលឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំយល់ឃើញ និងអនុវត្តតួនាទីរបស់ពួកគេ ដើម្បីផ្តល់ជូនឱ្យស្របទៅនឹងសេចក្តីត្រូវការរបស់កូនពួកគេ (តម្រូវការផ្នែកផ្លូវកាយ ផ្លូវចិត្ត បញ្ញា និងស្មារតី)។ |
| **ការចិញ្ចឹមកូនបែបវិជ្ជមាន** | ការចិញ្ចឹមកូនដោយមិនប្រើទម្រង់ណាមួយនៃអំពើហិង្សា រួមទាំងការមិនអើពើ ដោយផ្តោតទៅលើគោលដៅយូរអង្វែង ភាពកក់ក្តៅ និងដែនកំណត់ យល់ពីការគិត និងអារម្មណ៍ និងដោះស្រាយបញ្ហារបស់កូនៗ។ |
| **កត្តាការពារ** | អ្វីដែលធ្វើឱ្យឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ អនុវត្តការចិញ្ចឹមកូនបែបវិជ្ជមាន ឬអ្វីដែលបង្កើនភាពធន់របស់ឪពុកម្តាយ អាណាព្យាបាល ឬអ្នកថែទាំ នៅពេលដែលពួកគេជួបប្រទះទៅនឹងកត្តាហានិភ័យ។ |
| **កត្តាហានិភ័យ** | អ្វីដែលបង្កើនលទ្ធភាពក្នុងការចិញ្ចឹមកូនបែបអវិជ្ជមាន និងអនុវត្តការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ឬប្រើអំពើហិង្សា និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។ |
| **អំពើហិង្សាផ្លូវភេទ** | គឺជាទង្វើផ្លូវភេទ ការប៉ុនប៉ងធ្វើអំពើផ្លូវភេទ ការផ្តល់យោបល់ ឬសម្តីលែបខាយដែលគេមិនចង់បាន ឬទង្វើជួញដូរមនុស្ស ឬទង្វើផ្សេងទៀតដែលផ្តោតលើលក្ខណៈផ្លូវភេទរបស់មនុស្សម្នាក់ដោយប្រើប្រាស់ការបង្ខិតបង្ខំរបស់មនុស្សណាម្នាក់មិនថាមនុស្សម្នាក់នោះមានទំនាក់ទំនងបែបណាជាមួយជនរងគ្រោះនោះទេ ទោះជាក្នុងបរិបទបែបណាក៏ដោយដូចជាក្នុងផ្ទះ ឬកន្លែងការងារ និងកន្លែងផ្សេងទៀតជាដើម។ |
| **អំពើហិង្សាលើកុមារ** | **គ្រប់ទម្រង់នៃអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្តលើកុមារ** ៖ ការបង្ករបួសស្នាម និងការរំលោភបំពាន ការមិនអើពើ ឬមិនយកចិត្តទុកដាក់ ការធ្វើបាប ឬការកេងប្រវ័ញ្ច រាប់បញ្ចូលការរំលោភបំពានផ្លូវភេទ។ |
| **យេនឌ័រ** | សំដៅលើផ្នត់គំនិត និងការប្រព្រឹត្តិរបស់គ្រួសារ សហគមន៍ និងសង្គមដែលបែងចែកនូវការផ្តល់ឱកាស ធនធាន និងសិទ្ធិអំណាចនានា រវាងបុរស និងស្ត្រី ឬកុមារា និងកុមារី។ ផ្នត់គំនិត និងឥរិយាបថនៃការបែងចែកនេះ បានធ្វើឱ្យមានវិសមភាពយេនឌ័រ ដូចជាគម្លាតនៃការទទួលការសិក្សាអប់រំ និងភាពក្លាហានរវាងបុរស និងស្ត្រី ឬកុមារា និងកុមារីជាដើម។ ការអប់រំតាមបែបវិជ្ជមាន គឺជាមធ្យោបាយដ៏សំខាន់ និងចាំបាច់ ក្នុងការចូលរួមកាត់បន្ថយនូវគម្លាត ឬវិសមភាពយេនឌ័រនៅក្នុងគ្រួសារ សហគមន៍ និងសង្គម។ |
| **អត្តសញ្ញាណយេនឌ័រ** | ជាអត្តសញ្ញាណដែលកើតឡើងដោយសង្គមមកលើបុរស ឬស្ត្រី ដែលមិនសំដៅទៅលើភេទ។ |

| | |
|---|---|
| **និទណ្ឌភាព** | ភាពគ្មានទោស។ |
| **សង្គតិភាព** | ភាពចូលប្រសព្វគ្នា ភាពរួបរួមគំនិតគ្នា។ |
| **នីត្យានុកូលកម្ម** | នីតិវិធីដែលមន្ត្រីរាជការណាម្នាក់បានបញ្ជាក់ទទួលស្គាល់ថាហត្ថលេខាទាំងឡាយលើលិខិតមួយត្រឹមត្រូវតាមច្បាប់។ |
| **អ្នកជំនាញវិជ្ជាជីវៈ** | សំដៅលើអ្នកដែលបានទទួលការបណ្តុះបណ្តាលជំនាញអ្វីមួយពិតប្រាកដពីគ្រឹះស្ថាននានា និងមានសញ្ញាបត្របញ្ជាក់ច្បាស់លាស់។ |
| **អ្នកពាក់កណ្តាលជំនាញវិជ្ជាជីវៈ** | សំដៅលើអ្នកស្ម័គ្រចិត្តសហគមន៍ដែលទទួលការបណ្តុះបណ្តាលពីជំនាញច្បាស់លាស់សម្រាប់បម្រើការងារនៅក្នុងសហគមន៍។ |
| **គុណវុឌ្ឍិ** | សេចក្តីចម្រើនដោយគុណ ដំណើរចម្រើនដោយសេចក្តីល្អ ដោយសេចក្តីរុងរឿងដោយសេចក្តីបរិសុទ្ធ។ |

# ឯកសារយោង


1. Ward, C. & Wessels, I. (2013). *Rising to the challenge: towards effective parenting programmes.*In L Berry et al (eds), South African child gauge, Cape Town: Children's Institute, University of Cape Town, 2013, 64.
2. Child and Family Agency Parenting Support Strategy (2013). *Investing in Families: Supporting parents to improve outcomes for children.* Child and Family Agency Parenting Support Strategy.Dublin: Child and Family Agency Parenting Support Strategy.
3. Daly, M., Bray, R., Bruckauf, Z., Byrne, J., Margaria, A., Pecnik, N. & Samms-Vaughan, M. (2015). *Family and Parenting Support. Policy and Provision in a Global Context.* Innocenti Insight. Florence: UNICEF Office of Research.
4. Ministry of Women's Affairs, UNICEF Cambodia, US Centers for Disease Control and Prevention (2014). *Findings from Cambodia's Violence Against Children Survey 2013.* Phnom Penh: Ministry of Women's Affairs.
5. World Health Organization (2013). Preventing violence: *evaluating outcomes of parenting programmes.* Geneva: World Health Organization.
6. Ministry of Social Affairs, Veterans and Youth Rehabilitation (2011). *Study of Attitudes towards Residential Care for Children in Cambodia.* Phnom Penh: Ministry of Social Affairs, Veterans and Youth Rehabilitation.
7. World Health Organization(2009). *Preventing violence through the development of safe, stable and nurturing relationships between children and their parents and caregivers. Violence prevention:* the evidence. Geneva, Switzerland: World Health Organization.
8. Royal University of Phnom Penh & Sigmund Freud Institute (2015). *Preliminary Findings of the Research Project: "Parenting and Parent-Child Interactions in Three Generations after the Khmer Rouge Regime in Cambodia"* (PPCIC). Phnom Penh: Royal University of Phnom Penh.
9. Fulu, E., Warner, X., Miedema, S., Jewkens, R., Roselli, T. & Lang, J. (2013). *Why do some men use violence against women and how can we prevent it? Quantative findings from the United Nations Multi-Country study on men and violence in Asia and the Pacific.* Bangkok: UNDP, UNFPA, UN Women and UNV.
10. National Scientific Council on the Developing Child (2005). *Excessive stress disrupts the architecture of the developing brain: Working Paper #3*.Cambridge: Centre on the Developing Child, Harvard University.
11. World Health Organization (2010). *Violence prevention: The evidence.* Geneva: World Health Organization.
12. World Health Organization (2015). *Success Factors for Women's and Children's Health*. Geneva: World Health Organization.
13. RUPP Psychology Department (2015). *Parenting Programmes in Cambodia.* Phnom Penh: RUPP Psychology Department.

14. Knerr, W., Gardner, F. & Cluver, L. (2011). *Parenting and the prevention of child maltreatment in low- and middle-income countries. A systematic review of interventions and adiscussion of prevention of the risks of future violent behaviour among boys.* Centre for Evidence-Based Intervention, Dept. of Social Policy and Intervention, University of Oxford.

15. Knerr W., Gardner F. & Cluver, L. (2013). *Improving positive parenting skills and reducing harsh and abusive parenting in low- and middle-income countries: a systematic review.* Prevention Science. Aug;14(4):352-63.

16. Cooper, P.J., Tomlinson, M., Swartz, L., Landman, M., Molteno, C., Stein, A., McPherson,K. & Murray, L. (2009). *Improving quality of mother-infant relationship and infant attachment in socioeconomically deprived community in South Africa: randomised controlled trial.* BMJ. 2009;338:b974.

17. Rahman, A., Iqbal, Z., Roberts, C. & Husain, N. (2008).*Cluster randomized trial of a parent-based intervention to support early development of children in a low-income country.* Child: Care, Health and Development 35: 56–62.

18. Mikton, C. & Butchart, A. (2009). *Child maltreatment prevention: a systematic review of reviews.* Bulletin of the World Health Organization.

19. Sim, A., Annan, J., Puffer, E., Salhi, C. & Betancourt, T. (2014). *Building Happy Families. Impact evaluation of a parenting and family skills intervention for migrant and displaced Burmese families in Thailand.* International Rescue Committee.

20. Literature review. *BCC approaches: Communication sources and channels, evidence, lessons learned,* gaps (unpublished).

21. Wakefield, M.A., Loken, B.&Horn, R.C. (2010). *Use of mass media campaigns to change health behaviour.* Lancet. 76:1261–71.

22. Briscoe, C. &Aboud, F. (2012). *Behaviour change communication targeting four health behaviours in developing countries - a review of change tehcniques.* Social Science & Medicine.75:612-621.

23. McAllister, F.& Burgess, A. (2012). Fatherhood: *Parenting Programmes and Policy. A Critical Review of Best Practice.* London/Washington D.C.: The Fatherhood Institute/Promundo/MenCare.

24. Gourley, S., Kimsan, T. &Soksan, T. (2013). *Voice of the Children Project. Phase Two Mid-Term Evaluation.* Phnom Penh.

25. Mortensen, C.(2015).*Strengthening the Community System for Child Protection (SCSCP) in Peam Ro District, Prey Veng. Positive Parenting Lessons Learnt.* Phnom Penh.

26. Nee, M. (2015). *Evaluation Report. Skillful Parenting Project "Enabling Local Empowerment Action for Child Protection Environment (LEAP)"*.Based in Odor Meanchey Province.

27. Gourley, S. (2009). *The Middle Way. Bridging the Gap Between Cambodian Culture and Children's Rights.* Phnom Penh: NGO Committee on the Rights of the Child.

Richter, L.M. &Naicker, S. (2012). A Review of Published Literature on Supporting and Strengthening Child-Caregiver Relationships (Parenting). Arlington: USAID's AIDS Support and Technical Assis

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

Government of Canada

Gouvernement du Canada

Together for girls
Ending violence against children

Save the Children

unicef
ដើម្បីកុមារគ្រប់រូប